សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et des Sciences Economiques

Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# ហ៊ីប៉ូតែកជម្ងឺតា

ស្រាវជ្រាវពីថ្ងៃទី២៣ មីនា ឆ្នាំ២០២២ ដល់ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២២


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ៖ **ហ៊ី ខេងចូវ**

**សាន សុម៉ានិត**

សាស្ត្រាចារ្យណែនាំ

**លោក ញឹក ឧត្តី**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២២

ឆ្នាំចូលសិក្សា ២០១៨

ឆ្នាំសរសេរសារណា ២០២២

# សេចក្តីថ្លែងអំណរគុណ

ជាកិច្ចចាប់ផ្តើមយើងខ្ញុំទាំងពីរនាក់ដែលមាន ខ្ញុំបាទឈ្មោះ **ហ៊ូ ខេងចូវ** និងនាងខ្ញុំឈ្មោះ **សាន សុម៉ានិត** ជានិស្សិតបញ្ចប់ការសិក្សា ថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ ជំនាន់ទី ២២ ក្នុងឆ្នាំសិក្សា ២០១៨ - ២០២២ នៃសាកលវិទ្យាល័យ ភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

**សូមលំអោនកាយគោរពនិងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុត ជូនចំពោះ៖**

- លោកឪពុក **ហ៊ូ លីសុផាសិត** និង អ្នកម្តាយ **ព្រាប សុខខេង**
- លោកឪពុក **សាន សុផល** និងអ្នកម្តាយ **អៀង ផល្លី**

យើងខ្ញុំទាំងពីរដែលជានិស្សិត និងជាកូន មានវត្តមាននៅថ្ងៃនេះក៏ដោយសារលោកអ្នកមានគុណទាំងពីរ ដែលបានផ្តល់កំណើត ចិញ្ចឹម បីបាច់ថែរក្សា និងបានផ្គត់ផ្គង់គ្រប់សព្វបែបយ៉ាងដល់ការសិក្សារបស់កូនៗតាំងពីថ្នាក់មតេយ្យ រហូតដល់ថ្នាក់មហាវិទ្យាល័យ។ លើសពីនេះ នៅក្នុងការរស់នៅប្រចាំថ្ងៃ លោកទាំងពីរតែងតែ អប់រំ ទូន្មាន ប្រៀនប្រដៅ និងយកចិត្តទុកដាក់ខ្វាយខ្វល់ពីសុខភាពរបស់កូនពោពេញដោយភាពកក់ក្តៅគ្រប់ពេលវេលា និងប្រកប ដោយព្រហ្មវិហារធម៌ទាំងបួនដល់កូនជានិច្ច។ គុណបំណាច់ដ៏ធំធេងរបស់អ្នកមានគុណទាំងពីរនេះហើយ កូនគ្មានថ្ងៃ អាចតបស្នងដល់លោកទាំងពីរបានអស់ឡើយក្នុងមួយជីវិតនេះ ប៉ុន្តែដើម្បីគោរពនិងសម្តែងនូវការដឹងគុណរបស់លោកទាំងពីរកូននឹងព្យាយាមខិតខំសិក្សាប្រកបដោយការយកចិត្តទុកដាក់ និងធ្វើខ្លួនឱ្យក្លាយជាពលរដ្ឋល្អនៅក្នុងសង្គមដើម្បីជាសសរទ្រូងនៃប្រទេសជាតិ។

សូមថ្លែងអំណរគុណចំពោះ **ឯកឧត្តម សារិន វណ្ណា** ជាប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដី រាជធានីភ្នំពេញ ដែលបានអនុញ្ញាតឱ្យយើងខ្ញុំទាំងពីរបានចុះស្រាវជ្រាវឯកសារទាក់ទងនឹងប្រធានបទរបស់យើងខ្ញុំ។ អំឡុងពេលនៃការចុះស្រាវជ្រាវនេះ យើងខ្ញុំបានទទួលមកវិញនូវការកើនឡើងនូវគំនិតច្រើនជាងមុន និងមានឯកសារគ្រប់គ្រាន់ដើម្បីសរសេរសារណា និងការពារបញ្ចប់ការសិក្សារបស់យើងខ្ញុំ។

សូមថ្លែងអំណរគុណចំពោះ **លោកសាស្ត្រចារ្យ ញឹក ឧទ្ធី** ជាប្រធានការិយាល័យស្រាវជ្រាវ និងជាសាស្ត្រចារ្យដឹកនាំក្នុងការសរសេរសារណារបស់ក្រុមយើងខ្ញុំ ដែលតែងតែផ្តល់នូវគំនិតយោបល់ដ៏សម្បូរបែប ការលះបង់នូវពេលវេលាដ៏មានតម្លៃក្នុងការពិនិត្យ កែតម្រូវ គ្រប់ដំណាក់

កាលនៃការសរសេរ និងការផ្តល់នូវពុទ្ធិ ប្រកបដោយភាពហ្មត់ចត់ និងការយកចិត្តទុកដាក់ខ្ពស់ ហើយលោកក៏ជាចំណែកមួយដែលជួយឱ្យការសរសេរនេះ អាចបញ្ចប់ទៅបានដោយរលូនផងដែរ។

ជាទីបញ្ចប់យើងខ្ញុំសូមគោរពជូនពរដល់ លោកឪពុក អ្នកម្តាយ លោកសាស្ត្រាចារ្យ ញឹក វុទ្ធី ព្រមទាំង លោក លោកស្រី សាស្ត្រាចារ្យទាំងអស់គ្រប់មុខវិជ្ជាដែលផ្តល់ចំណេះដល់យើងខ្ញុំទាំងពីរ តាំងពីឆ្នាំដំបូងនៃការសិក្សា រហូតដល់បញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនេះ ឱ្យជួបប្រទះតែសេចក្តីសុខ មានសុខភាពល្អ សុភមង្គល ទទួលបាន ជោគជ័យគ្រប់ការងារ ព្រមទាំងជួបនូវពុទ្ធពរទាំងបួនប្រការគឺ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

ក្នុងនាមយើងខ្ញុំជានិស្សិតដែលកំពុងសិក្សាបរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ ឆ្នាំទី៤ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចអស់រយៈពេលជិត៤ឆ្នាំ យើងខ្ញុំទាំងពីរមានការចាប់អារម្មណ៍យ៉ាងខ្លាំងទៅលើប្រធានមួយដែលនិយាយអំពី ហ៊ីប៉ូតែកធម្មតា ដែលត្រូវបានគេទទួលស្គាល់ថាជាវិធីដាក់បន្ទុកលើអចលនទ្រព្យដែលបានប្រើប្រាស់ជាទូទៅសម្រាប់ធានានូវកាតព្វកិច្ចរបស់អ្នកជាប់បំណុល។ សារណាអំពីប្រធានបទ ហ៊ីប៉ូតែកធម្មតា នេះមិនមែនជារឿងថ្មីនោះទេ។ ហ៊ីប៉ូតែក បានជ្រៀតខ្លួនចូលមកប្រទេសកម្ពុជាចាប់តាំងពីឆ្នាំ១៩២០ មានចែងក្នុងក្រមរដ្ឋប្បវេណីឆ្នាំ១៩២០ ដែលកាលនោះហ៊ីប៉ូតែកគេចែងមានតែ៣មាត្រាតែប៉ុណ្ណោះ។ ក្រោយមក ឃើញមានចែងនៅក្នុងច្បាប់ភូមិបាលឆ្នាំ១៩៩២ មាន៧មាត្រា ហើយក្រោយមកទៀត ក៏មានចែងនៅក្នុងច្បាប់ភូមិបាលឆ្នាំ២០០១ផងដែរ តែមិនបានប៉ុន្មានឆ្នាំ ច្បាប់ភូមិបាលឆ្នាំ២០០១ ត្រូវបានវិសោធនកម្មនូវបទប្បញ្ញត្តិមួយចំនួន ក្នុងនោះហ៊ីប៉ូតែកដែលមានចែងក្នុងច្បាប់ភូមិបាល ក្នុងជំពូកទី១២ ត្រូវបានលុបចោលទាំងស្រុង ហើយត្រូវបានជំនួសដោយក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧វិញ ដែលក្នុងនោះមានបញ្ញត្តិថ្មីមួយចំនួនត្រូវបានបង្កើតឡើងដើម្បីស្របទៅនឹងបរិបទនៃសង្គមខ្មែរយើង។ ដូច្នេះ យើងឃើញថាវិធានក្នុងការអនុវត្តហ៊ីប៉ូតែកនៅមានការខ្វះចន្លោះច្រើន ដែលជាហេតុនៅពេលដែលអនុវត្តជាក់ស្តែងមិនអាចទៅរួច តែក្រោយមករហូតដល់ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ លែងស្ថិតនៅក្រោមឥទ្ធិពលរបស់បារាំងទៀតហើយ លើកនេះគឺមានការជ្រោមជ្រែង ការគាំទ្រ និងការតាក់តែងលើវិស័យយុត្តិធម៌ដោយហៅថា សហប្រតិបត្តិការអន្តរជាតិប្រទេសជប៉ុន ដែលហៅថា ចៃកា។ ដោយបានជួយសម្រួលក្នុងការរៀបចំវិធានហ៊ីប៉ូតែកនេះឱ្យមានលក្ខណៈសម្បូរបែប និងទំនើប ហើយមានលក្ខណៈអាចអនុវត្តទៅបាន។

សារណាមួយនេះ ដែលផ្តោតទៅលើប្រធានបទ ហ៊ីប៉ូតែកធម្មតា ដែលជាផ្នែកមួយនៃសិទ្ធិប្រាតិភោគប្រត្យក្ស ជាសិទ្ធិដែលត្រូវបានប្រើប្រាស់ច្រើនជាងគេក្នុងចំណោមសិទ្ធិទាំង៥ ទាំងក្នុងធនាគារ និងគ្រឹស្ថានមីក្រូហិរញ្ញវត្ថុ។ ហើយបើយើងងាកមកមើលទិដ្ឋភាពជាក់ស្តែងនៅក្នុងការរស់នៅប្រចាំថ្ងៃ ប្រជាពលរដ្ឋខ្មែរមួយចំនួនគឺគេចមិនផុតឡើយពីការយកវត្ថុដែលជាអចលនទ្រព្យរបស់ខ្លួន ឬតតិយជន ទៅធានាជាមួយម្ចាស់បំណុលណាម្នាក់ ដើម្បីទទួលបានមកវិញពីអត្ថប្រយោជន៍លើអចលទ្រព្យរបស់ខ្លួនយកមកប្រើប្រាស់ឱ្យអស់ពីលទ្ធភាពតាមត្រូវការរបស់ខ្លួន ប៉ុន្តែពេលខ្លះគាត់នៅ

មានការខ្វះខាតទៅលើការយល់ដឹងអំពីការរៀបចំឯកសារ បែបបទ ក៏ដូចជានីតិវិធីក្នុងការចុះបញ្ជី ដែលជាមូលហេតុមិនអាចឱ្យពួកគាត់ជ្រើសរើសយកហ៊ីប៉ូតែកមកប្រើប្រាស់បាន ហេតុដូចនេះ ដោយយល់ឃើញពីសារៈសំខាន់នៃហ៊ីប៉ូតែក និងដើម្បីចែករំលែកនូវចំណេះដឹងដែលពួកយើងបាន ខិតខំធ្វើការសិក្សាស្រាវជ្រាវមកនេះ ដែលជាហេតុជម្រុញឱ្យពួកខ្ញុំសម្រេចចិត្តជ្រើសរើសយកប្រធានបទមួយនេះមកធ្វើការចែករំលែក។

គោលបំណងនៃសារណានេះ យើងខ្ញុំសង្ឃឹមយ៉ាងមុតមាំថារបាយការណ៍បញ្ចប់ការសិក្សាមួយនេះនឹងជាជំនួយដល់និស្សិត អ្នកសិក្សាស្រាវជ្រាវ ឱ្យបានយល់ដឹងកាន់តែច្បាស់ និងស៊ីជម្រៅអំពីប្រធានបទនេះ ដោយយើងខ្ញុំនឹងធ្វើការបកស្រាយលម្អិតអំពីហ៊ីប៉ូតែកធម្មតាតែប៉ុណ្ណោះ ចំណែកឯហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត ដែលជាប្រភេទមួយនៃហ៊ីប៉ូតែកផងដែរយើងខ្ញុំសុំមិនលើកយកមកនិយាយ។ នៅក្នុងសារណានេះ យើងខ្ញុំបានពឹងផ្អែកទៅលើក្រមរដ្ឋប្បវេណីជាគោល និងឯកសារច្បាប់ជាច្រើនបន្ថែមទៀត ក៏ដូចជាការពន្យល់បន្ថែមពីមេធាវីផងដែរ ដោយផ្សារភ្ជាប់ទាំងទ្រឹស្តីការរៀបចំឯកសារក្នុងការចុះបញ្ជី ក៏ដូចជានីតិវិធីក្នុងការចុះបញ្ជី។

ជាចុងបញ្ចប់ យើងខ្ញុំទាំងពីរពិតជាមានមានមោទនភាពយ៉ាងក្រៃលែងដែលបានចំណាយពេលវេលាដ៏មានតម្លៃ សិក្សាស្រាវជ្រាវទៅលើប្រធានបទ ហ៊ីប៉ូតែកធម្មតានេះ។ ហើយយើងខ្ញុំសង្ឃឹមថាយ៉ាងមុតមាំថា សារណាមួយនេះ នឹងក្លាយទៅជាចំណេះដឹងថ្មីរបស់អ្នកអានទាំងឡាយ។ ទន្ទឹមនឹងនេះ យើងខ្ញុំក៏សូមធ្វើការអភ័យទោសទុកជាមុនផងដែរប្រសិនបើមានលេចចេញនូវចន្លោះខ្វះខាតដោយប្រការណាមួយ ហើយរីករាយទទួលយកនូវមតិរិះគន់ក្នុងន័យស្ថាបនា ពីសំណាក់ឯកឧត្តម អស់លោក លោកស្រី សាស្ត្រាចារ្យ និងមិត្តអ្នកអាន ដោយក្តីសោមនស្ស។

# មាតិកា

ទំព័រ

**សេចក្តីផ្តើម** ....................................................................................... ១

## ជំពូកទី១
## របបគតិយុត្តនៃការបង្កើតហ៊ីប៉ូតែកធម្មតា

**ផ្នែកទី១. និយមន័យ និងលក្ខខណ្ឌនៃការបង្កើតហ៊ីប៉ូតែកធម្មតា**.................. ៣

**កថាភាគទី១. និយមន័យ** ........................................................................ ៣

**កថាភាគទី២. លក្ខខណ្ឌគ្រឹះ** ......................................................................៤

២.១. លក្ខខណ្ឌសុពលភាពនៃការបង្កើតហ៊ីប៉ូតែក.............................................៤

២.១.១. ការព្រមព្រៀង.................................................................................៤

២.១.២. សមត្ថភាពជាភាគី ...........................................................................៥

២.២. កម្មវត្ថុនៃការបង្កើតហ៊ីប៉ូតែក .............................................................៦

២.២.១. អចលនវត្ថុ.......................................................................................៦

២.២.២. សិទ្ធិជួលអចិន្ត្រៃយ៍ និងផលុបភោគ ............................................... ៧

២.២.៣. ទ្រព្យផ្សេងទៀតកំណត់ដោយច្បាប់ពិសេស ........................................១១

**កថាភាគទី៣. លក្ខខណ្ឌទម្រង់នៃកិច្ចសន្យាហ៊ីប៉ូតែក**............................ ១២

៣.១. លក្ខខណ្ឌតាំងនៃកិច្ចសន្យា ............................................................ ១២

៣.១.១. ការតាក់តែងជាលិខិតយថាភូត..................................................... ១៣

៣.១.២. ការចុះបញ្ជីសុរិយោដី .................................................................១៤

**ផ្នែកទី២. អានុភាពនៃហ៊ីប៉ូតែក** ............................................................ ១៤

**កថាភាគទី១. ទំហំនៃអានុភាពហ៊ីប៉ូតែក** .............................................. ១៥

១.១. លើអាគារដែលភ្ជាប់ទៅនឹងដី ..................................................... ១៥
១.២. អានុភាពលើផល ..................................................................... ១៦
១.៣. អានុភាពលើអាគារដែលជាកម្មសិទ្ធិរបស់តតិយជន .................................. ១៦
**កថាភាគទី២. ឧបាទេសកម្មលើវត្ថុ** ..................................................... ១៦
**កថាភាគទី៣. សិទ្ធិទាមទារសំណងរបស់អ្នកធានាដោយវត្ថុ** .................... ១៧
**កថាភាគទី៤. លំដាប់នៃហ៊ីប៉ូតែក** ..................................................... ១៩
**កថាភាគទី៥. ទំហំនៃសិទ្ធិលើបំណុលដែលត្រូវបានធានា** ........................ ២០

## ជំពូកទី២

## ការអនុវត្ត ការចាត់ចែង និងការរលត់ហ៊ីប៉ូតែកធម្មតា

**ផ្នែកទី១. យន្តការនៃការអនុវត្តសិទ្ធិហ៊ីប៉ូតែក** .......................................... ២២
**កថាភាគទី១. ការលក់ដោយបង្ខំនូវអចលនវត្ថុ** .......................................... ២៣
១.១. ការរឹបអូស ............................................................................ ២៣
១.២. ការលក់ ............................................................................... ២៤
១.៣. ការចែកចំណែក ....................................................................... ២៥
**កថាភាគទី២. ភាគីដែលអាចក្លាយជាអ្នកទិញនៅពេលអនុវត្ត** ....................... ២៦
២.១. ម្ចាស់បំណុលហ៊ីប៉ូតែក ឬអ្នកធានាដោយវត្ថុ .......................................... ២៦
២.២. កូនបំណុលហ៊ីប៉ូតែក ................................................................ ២៦
២.៣. តតិយជនដែលបានធ្វើលទ្ធកម្ម ...................................................... ២៧
**កថាភាគទី៣. ការលក់ដោយបង្ខំនូវអាគារដែលជាកម្មសិទ្ធិរបស់តតិយជន** ............................................................................................ ២៨
៣.១. ករណីមិនអាចលក់ដោយបង្ខំបាន ................................................... ២៨
៣.២. ករណីអាចលក់ដោយបង្ខំបាន ....................................................... ២៩
**កថាភាគទី៤. សិទ្ធិរបស់តតិយជនដែលបានធ្វើលទ្ធកម្ម** ............................. ២៩
**កថាភាគទី៥. ការអនុវត្តដោយបង្ខំករណីម្ចាស់បំណុលហ៊ីប៉ូតែកច្រើននាក់** ៣០
**កថាភាគទី៦. ហ៊ីប៉ូតែករួម** ............................................................... ៣៣

៦.១. ករណីនៃការចែកចំណែកព្រមគ្នា ........................................................ ៣៣
៦.២. ករណីនៃការចែកចំណែកមិនព្រមគ្នា .................................................. ៣៥
**ផ្នែកទី២. ការចាត់ចែងហ៊ីប៉ូតែកធម្មតា** ........................................................ ៣៧
**កថាភាគទី១. ប្រភេទនៃការចាត់ចែងហ៊ីប៉ូតែក** ................................................ ៣៧
១.១. ហ៊ីប៉ូតែកបន្ត ........................................................................ ៣៨
១.២. អនុប្បទាន ឬការបោះបង់ហ៊ីប៉ូតែក .................................................. ៣៨
១.៣. អនុប្បទាន ឬការបោះបង់ និងការផ្លាស់ប្តូរនូវលំដាប់ហ៊ីប៉ូតែក ........................ ៤០
**កថាភាគទី២. លក្ខខណ្ឌដើម្បីបង្កើតអានុភាព** ................................................ ៤០
**កថាភាគទី៣. ការរលត់នៃហ៊ីប៉ូតែក** ........................................................ ៤១
៣.១. ការរលត់នៃកិច្ចសន្យាបង្កើតហ៊ីប៉ូតែកដោយការទាមទារ ................................ ៤២
៣.២. ការរលត់ដោយអាជ្ញាយុកាល ........................................................ ៤២

## ជំពូកទី៣

## ការរៀបចំឯកសារ និងការចុះបញ្ជីអំពីការបង្កើតសិទ្ធិលើហ៊ីប៉ូតែកធម្មតា

**ផ្នែកទី១. ការរៀបចំឯកសារនៅក្នុងការបង្កើតសិទ្ធិលើហ៊ីប៉ូតែក** ............................ ៤៤
**កថាភាគទី១. ហ៊ីប៉ូតែកលើកម្មសិទ្ធិ** ........................................................ ៤៤
១.១. កិច្ចសន្យាខ្ចីបរិភោគ ........................................................ ៤៤
១.១.១. និយមន័យ ........................................................ ៤៤
១.១.២. ចំណុចដែលត្រូវសរសេរក្នុងកិច្ចសន្យាខ្ចីបរិភោគ ........................................ ៤៥
១.២. កិច្ចសន្យាបង្កើតសិទ្ធិហ៊ីប៉ូតែក ........................................................ ៤៦
១.២.១. និយមន័យ ........................................................ ៤៦
១.២.២. ចំណុចដែលត្រូវសរសេរ ........................................................ ៤៧
១.៣. ពាក្យសុំចុះបញ្ជីអំពីការបង្កើតហ៊ីប៉ូតែក ................................................ ៤៧
១.៣.១. ទម្រង់នៃពាក្យសុំចុះបញ្ជី ........................................................ ៤៨
១.៣.២. ចំណុចដែលត្រូវសរសេរ ........................................................ ៤៨
១.៤. ឯកសារភ្ជាប់សម្រាប់ការចុះបញ្ជី ........................................................ ៤៩

**ផ្នែកទី២. ដំណាក់កាលនៃការចុះបញ្ជី** .................... ៥០

**កថាភាគទី១. ដំណាក់កាលព្រមព្រៀងជាលាយលក្ខណ៍អក្សរ** .................... ៥១

**កថាភាគទី២. ការបញ្ជាក់ពីភាពត្រឹមត្រូវនៃកិច្ចសន្យា** .................... ៥១

**កថាភាគទី៣. ដំណាក់កាលនៅរដ្ឋបាលសុរិយោដី** .................... ៥២

**សេចក្តីសន្និដ្ឋាន** .................... ៥៣

**អនុសាសន៍** .................... ៥៥

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហា

ហ៊ីប៉ូតែក គឺជាប្រភេទមួយនៃសិទ្ធិប្រាតិភោគប្រត្យក្សដែលក្នុងនោះម្ចាស់បំណុល មានសិទ្ធិអាទិភាពក្នុងការទទួលបានការសងមុនម្ចាស់បំណុលផ្សេងទៀត ហើយកូនបំណុលដែលយកអចលនទ្រព្យ ឬអាចជាសិទ្ធិលើអចលនទ្រព្យ ដូចជាសិទ្ធិជួលអចិន្ត្រៃយ៍ ផលុបភោគ របស់គាត់មកធ្វើជាការធានាកាតព្វកិច្ច ប៉ុន្តែវាអាចជាទ្រព្យរបស់តតិយជនផងដែរ មានន័យថា ការធានាដោយវត្ថុដោយតតិយជន។ ដូច្នេះ ក្រៅពីកូនបំណុលដែលមានកាតព្វកិច្ចចម្បងនឹងក៏អាចមានតតិយជនផ្សេងទៀតដែលគាត់ស្ម័គ្រចិត្តចូលមកធានាកាតព្វកិច្ចជំនួសឱ្យកូនបំណុល នឹងបានដែរ ប៉ុន្តែគាត់យកទ្រព្យរបស់គាត់ខ្លួនឯងមកធានាឱ្យកូនបំណុល ដោយហេតុថា កូនបំណុលគាត់ អត់មានទ្រព្យដើម្បីយកមកធានាកាតព្វកិច្ច។ ជារួមមកវិញ យើងឃើញថា សញ្ញាណមួយនេះអត់ថ្មីនោះទេ ឃើញថាប្រជាពលរដ្ឋទាំងអស់ភាគច្រើនក្នុងសង្គមកម្ពុជារបស់យើងមានប្រើប្រាស់ហើយ ប៉ុន្តែប្រើប្រាស់ពេលខ្លះទាំងមិនដឹងខ្លួនថាវាជាហ៊ីប៉ូតែកទៀតផង។

កន្លងទៅមានការប្រើប្រាស់ជាការដាក់ធានា ការបញ្ចាំ នៅក្នុងអំឡុងពេលនៃការអនុវត្តច្បាប់ភូមិបាលឆ្នាំ២០០១ ឆ្នាំ១៩៩២ ជាដើម គឺមានការអនុវត្តការដាក់ធានា និងការបញ្ចាំ គឺពេញនិយមបំផុត ប៉ុន្តែហ៊ីប៉ូតែកពុំមានការអនុវត្តទេដោយសារវាមានភាពរាំងស្ទះមួយចំនួន ដែលជាឧបសគ្គក្នុងការមិនអាចអនុវត្តបាន។ ប៉ុន្តែនាពេលបច្ចុប្បន្ន ហ៊ីប៉ូតែក គឺត្រូវបានយកមកប្រើប្រាស់ច្រើនជាងគេគឺទាំង ធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។

## ២. ចំណោទបញ្ហា

ស្របពេលដែលកំណើនសេវាកម្មផ្តល់កម្ចីឥណទានដោយមានការធានាដោយវត្ថុ ហ៊ីប៉ូតែកមានការកើនឡើងផងនោះ ក៏នៅមានប្រជាជនជាច្រើននៅមិនទាន់យល់ និងស្គាល់ច្បាស់នៅឡើយថាតើហ៊ីប៉ូតែកជាអ្វី។ ដោយមើលឃើញពីសក្តានុពលធនាគារ ក៏ដូចជាស្ថាប័នផ្តល់ប្រាក់កម្ចី ព្រមទាំងតម្រូវការហិរញ្ញវត្ថុក្នុងជីវភាព និងការពង្រីកអាជីវកម្មពីសំណាក់ប្រជាជនដែលមានបំណងចង់ប្រើប្រាស់ប្រតិបត្តិប្រាតិភោគហ៊ីប៉ូតែក។ ដូច្នេះ ចំណោទបញ្ហានៃសារណាមួយនេះយើងនឹងផ្តោតទៅលើ៖

- ដូចម្តេចដែលហៅថាហ៊ីប៉ូតែក?
- តើគេអនុវត្តហ៊ីប៉ូតែកដោយរបៀបណាខ្លះ?

- ដំណាក់កាលនៃការចុះបញ្ជីបង្កើតសិទ្ធិលើហ៊ីប៉ូតែកត្រូវធ្វើដូចម្តេច?

## ៣. គោលបំណង

ការសិក្សាស្រាវជ្រាវនេះ គឺមានគោលបំណងនៅក្នុងការចូលរួមចំណែក ផ្តល់គំនិត និង ចំណេះដឹងដែលយើងទាំងពីរបានទទួលបាននៅក្នុងរយៈពេល៤ឆ្នាំនេះ និងចំណេះដឹងខ្លះៗដែល បានមកពីការស្រាវជ្រាវបន្ថែមក្នុងអំឡុងពេលតាក់តែងសារណានេះទៅដល់ប្អូនៗនិស្សិតដែលមាន ចំណាប់អារម្មណ៍ក្នុងការសិក្សាអំពី ហ៊ីប៉ូតែក។ តាមរយៈការសិក្សាស្រាវជ្រាវនេះ ក្រុមយើងខ្ញុំនឹង មានការបកស្រាយ ការពន្យល់យ៉ាងជ្រាលជ្រៅបំផុតពីយើងពួកខ្ញុំទៅលើចំណុលសំខាន់ៗដូចដែល បានរៀបរាប់ខាងលើ។

## ៤. ដែនកំណត់ និងវិសាលភាព

យើងឃើញថាបច្ចុប្បន្ន ហ៊ីប៉ូតែក គឺប្រជាជនកម្ពុជាស្ទើរតែគ្រប់តំបន់បានស្គាល់អំពី ហ៊ីប៉ូតែក។ ម្យ៉ាងវិញទៀតវាបានកកើតឡើងតាំងពីក្រមរដ្ឋប្បវេណីឆ្នាំ១៩២០ មកដល់ក្រមរដ្ឋ ប្បវេណី២០០៧ ក៏ប៉ុន្តែដែនកំណត់នៃសារណាមួយនេះគឺយើងបរិយាយ ទាក់ទងតែជាមួយក្រមរដ្ឋ ប្បវេណីឆ្នាំ២០០៧ តែប៉ុណ្ណោះ។ ដូច្នេះដើម្បីឱ្យសារណាមួយនេះអាចទុកធ្វើជាឯកសារមួយដែលមាន ប្រយោជន៍ និងអាចយកមកប្រើប្រាស់ជាឯកសារជំនួយបាន យើងទាំងពីរនាក់ក៏បានកំណត់វិសាល ភាពត្រឹមបរិបទនៃ "ប្រទេសកម្ពុជា និងហ៊ីប៉ូតែកធម្មតា"។

## ៥. សារសំខាន់នៃការសិក្សា

ការយល់ដឹងអំពី ហ៊ីប៉ូតែកធម្មតា គឺជារឿងមួយដែលចាំបាច់ និងសំខាន់បំផុត ដោយផ្អែក តាមកំណត់ ការអនុវត្តជាក់ស្តែង។ យើងឃើញថា ប្រតិបត្តិការបង្កើតសិទ្ធិប្រាតិភោគដែលធានា កាតព្វកិច្ចដោយហ៊ីប៉ូតែក គឺត្រូវបង្កើតជាច្រើនស្របតាមតម្រូវការសេដ្ឋកិច្ចរបស់ប្រជាពលរដ្ឋ ហើយ ពិសេសទៅទៀត គឺកូនបំណុលមិនចាំបាច់ធ្វើការផ្ទេរការកាន់កាប់ទ្រព្យដែលជាកម្មវត្ថុនៃហ៊ីប៉ូតែក ទៅឱ្យម្ចាស់បំណុលឡើយ។

## ៦. រចនាសម្ព័ន្ធ៖

ការសិក្សាស្រាវជ្រាវនេះត្រូវបានបែងចែកជាបីជំពូកមានដូចខាងក្រោម៖

ជំពូកទី១៖ របបគតិយុត្តនៃការបង្កើតហ៊ីប៉ូតែកធម្មតា

ជំពូកទី២៖ ការអនុវត្ត ការចាត់ចែង និងការរលត់ហ៊ីប៉ូតែកធម្មតា

ជំពូកទី៣៖ ការរៀបចំឯកសារ និងការចុះបញ្ជីអំពីការបង្កើតសិទ្ធិលើហ៊ីប៉ូតែកធម្មតា

# ជំពូកទី១

# របបគតិយុត្តនៃការបង្កើត
# ហ៊ីប៉ូតែកធម្មតា

# ជំពូកទី១
# របបគតិយុត្តនៃការបង្កើតហ៊ីប៉ូតែកធម្មតា

របបគតិយុត្តហ៊ីប៉ូតែក ត្រូវបានបង្កើតឡើងសម្រាប់ជាមធ្យោបាយធានាបំណុល ដែលមានលក្ខណៈជាសិទ្ធិប្រាតិភោគប្រត្យក្សតាមការព្រមព្រមព្រៀង ដោយម្ចាស់បំណុលហ៊ីប៉ូតែកមានសិទ្ធិទទួលបានការសងចំពោះសិទ្ធិលើបំណុលរបស់ខ្លួនដោយមានអាទិភាពជាងម្ចាស់បំណុលផ្សេងទៀត ចំពោះអចលនវត្ថុដែលបានដាក់ធានាប្រាតិភោគនៃកាតព្វកិច្ច ដោយកូនបំណុល ឬតតិយជនដែលមានលក្ខណៈជាការមិនផ្ទេរការកាន់កាប់ ដោយរាប់បញ្ចូលទាំងសិទ្ធិជួលអចិន្ត្រៃយ៍ ផលុបភោគលើកលែងតែមានច្បាប់ពិសេសដោយឡែក ទើបអាចយកទ្រព្យសម្បត្តិផ្សេងក្រៅពីនេះ មកធ្វើជាកម្មវត្ថុនៃហ៊ីប៉ូតែក។

## ផ្នែកទី១. និយមន័យ និងលក្ខខណ្ឌនៃការបង្កើតហ៊ីប៉ូតែក

### កថាភាគទី១. និយមន័យ

ចំពោះការកំណត់អំពីនិយមន័យ ហ៊ីប៉ូតែកធម្មតា គឺជាប្រភេទមួយនៃសិទ្ធិប្រាតិភោគប្រត្យក្សដែលកូនបំណុល ឬ តតិយជនដែលបានយកទ្រព្យសម្បត្តិមកដាក់ហ៊ីប៉ូតែក និងម្ចាស់បំណុលបានព្រមព្រៀងគ្នាបង្កើតជាបន្ទុកមួយនៅលើទ្រព្យរបស់ខ្លួន ដើម្បីធានាកាតព្វកិច្ចមានកំណត់ដែលមានចំពោះម្ចាស់បំណុលដោយមិនមានការផ្ទេរនូវការកាន់កាប់ទ្រព្យនោះទៅឱ្យម្ចាស់បំណុលឡើយ[1]។

ក្នុងន័យនេះយើងឃើញថា ហ៊ីប៉ូតែកគឺជារបបគតិយុត្តមួយដែលបង្កើតឡើងដើម្បីការពារផលប្រយោជន៍របស់ម្ចាស់បំណុល បានន័យថា គឺផ្តល់ឱ្យម្ចាស់បំណុលនូវសិទ្ធិទទួលការសងចំពោះសិទ្ធិលើបំណុលរបស់ខ្លួន ដោយមានអាទិភាពជាងម្ចាស់បំណុលផ្សេងទៀត ចំពោះអចលនវត្ថុដែលបានដាក់ជាប្រាតិភោគធានាកាតព្វកិច្ច ដោយកូនបំណុល ឬតតិយជនដោយមិនផ្ទេរការកាន់កាប់[2]។ លក្ខណៈពិសេសរបស់ហ៊ីប៉ូតែក គឺត្រង់ថា ហ៊ីប៉ូតែកអាចធ្វើបានច្រើនដងបន្តបន្ទាប់គ្នាលើទ្រព្យតែមួយបាន។ ម្ចាស់បំណុលម្នាក់ៗប្រើសិទ្ធិតាមលំដាប់អាទិភាពនៃការចុះហត្ថលេខាចារិកលើហ៊ីប៉ូតែករបស់ខ្លួន។ ជាករណីលើកលែង ទ្រព្យដែលត្រូវបានជាប់បញ្ចាំ មិនអាចយកមកដាក់ហ៊ីប៉ូតែកបាន

[1] មាត្រា ៨៤៣ ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

[2] មាត្រា ៨៤៣ សេចក្តីកំណត់ចំពោះមាត្រានីមួយៗ ឆ្នាំ ២០១០ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

ទេ។ ក្រៅពីគោលបំណងនៃការការពារម្ចាស់បំណុល ការធានាតាមរយៈហ៊ីប៉ូតែកក៏ការពារកូនបំណុលផងដែរ តាមរយៈការអនុញ្ញាតឱ្យកូនបំណុលប្រើប្រាស់ឱ្យអស់ពីលទ្ធភាពពីតម្លៃនៃវត្ថុ ដូចជាការបង្កើតហ៊ីប៉ូតែកច្រើនដងលើវត្ថុតែមួយ ហើយលំដាប់អាទិភាពត្រូវបានកំណត់យកពេលវេលានៃការចុះបញ្ជីហ៊ីប៉ូតែក ដោយមិនតម្រូវឱ្យផ្ទេរនូវប័ណ្ណកម្មសិទ្ធិរបស់ខ្លួនឡើយ[3]។

**ឧទាហរណ៍៖** លោក A គឺជាម្ចាស់បំណុលរបស់លោក B ចំនួន ៣០ ០០០ ដុល្លារ។ លោក B បានយកអចលនវត្ថុ L ទៅដាក់ហ៊ីប៉ូតែកឱ្យលោក A ដើម្បីធានាបំណុល។ ក្នុងពេលនោះផងដែរ លោក B ក៏មានម្ចាស់បំណុលផ្សេងទៀតគឺ លោក C លោក D និងលោក E ។ បើដល់ពេលកំណត់សងហើយ លោក B មិនមានប្រាក់សងទេនោះ លោក A ដែលជាម្ចាស់បំណុល អាចអនុវត្តសិទ្ធិហ៊ីប៉ូតែករបស់ខ្លួនចំពោះដី L របស់លោក B ។ សន្មត់ថា អចលនវត្ថុ L នោះលក់បានតម្លៃ ១២០ ០០០ ដុល្លារ ។ ដូច្នេះ ប្រាក់ដែលបានមកពីការលក់អចលនវត្ថុលើដី L ត្រូវយកមកសងលោក A ចំនួន ៣០ ០០០ ដុល្លារ តែប៉ុណ្ណោះ ។ ម្ចាស់បំណុលផ្សេងទៀត នឹងមិនទទួលបាននូវសំណងដែលកើតចេញមកពីការលក់អចលនវត្ថុ L នោះទេ។ ប៉ុន្តែលោក C លោក D និងលោក E នៅតែអាចទាមទារសំណងពីលោក B ។

## កថាភាគទី២. លក្ខខណ្ឌគ្រឹះ

### ២.១. លក្ខខណ្ឌសុពលភាពនៃការបង្កើតហ៊ីប៉ូតែក

លក្ខខណ្ឌសុពលភាព គឺជាលក្ខខណ្ឌដែលមានខ្លឹមសារដែលថា តើហ៊ីប៉ូតែកត្រូវបំពេញលក្ខខណ្ឌ ឬតាមទម្រង់បែបណាទើបការបង្កើតហ៊ីប៉ូតែកមានសុពលភាព ឬអាចនិយាយបានថាមានអានុភាពរវាងម្ចាស់សិទ្ធិ អ្នកបង្កើត ឬតតិយជន។

#### ២.១.១. ការព្រមព្រៀង

ហ៊ីប៉ូតែក ត្រូវបានបង្កើតឡើងដោយការព្រមព្រៀងរវាងម្ចាស់បំណុល និងកូនបំណុល ឬតតិយជនដែលយកអចលនវត្ថុរបស់ខ្លួនមកដាក់ជាប្រាតិភោគ[4]។ បានន័យថា ការរៀបចំបង្កើតជាហ៊ីប៉ូតែក ត្រូវបំពេញលក្ខខណ្ឌដូចគ្នាទៅនឹងកិច្ចសន្យាផ្សេងៗទៀតផងដែរ គឺត្រូវមានការព្រមព្រៀង

[3] សៀវភៅមេរៀននីតិរដ្ឋប្បវេណី លោកអ៊ីវ ប៉ូលី។

[4] មាត្រា ៨៤៤ ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

ដោយពិតប្រាកដ និងដោយសេរី រវាងម្ចាស់បំណុល និងកូនបំណុល។ ផ្ទុយមកវិញ ប្រសិនបើមានវិការៈនៃការព្រមព្រៀងណាមួយ ដែលបានស្តែងឡើងនៅពេលរៀបចំកិច្ចសន្យានោះ កិច្ចសន្យាហ៊ីប៉ូតែក គឺមិនអាចអនុវត្តបានឡើយ។ ហេតុនេះ ការព្រមព្រៀងរវាងគូភាគីនៅក្នុងការបង្កើតកិច្ចសន្យាហ៊ីប៉ូតែក គឺជារឿងដ៏សំខាន់ដើម្បីឱ្យកិច្ចសន្យាហ៊ីប៉ូតែកមានអានុភាពចំពោះម្ចាស់សិទ្ធិ កូនបំណុល ឬតតិយជន។

លក្ខខណ្ឌសុពលភាពក្នុងការបង្កើតហ៊ីប៉ូតែក គឺចាំបាច់ទាល់តែបង្កើតជាលិខិតយថាភូត។ ហើយដើម្បីបង្កើតឱ្យមានសុពលភាពនៃកិច្ចសន្យាបង្កើតហ៊ីប៉ូតែក ការព្រមព្រៀងគ្នារវាងគូភាគី គឺកិច្ចសន្យាហ៊ីប៉ូតែកនៅមិនទាន់មានអានុភាពនៅឡើយទេ។ តួយ៉ាង លិខិតយថាភូត និងការចុះបញ្ជី គឺជាលក្ខខណ្ឌដែលមិនអាចខ្វះបានក្នុងការបង្កើតហ៊ីប៉ូតែក ដើម្បីឱ្យកិច្ចសន្យាហ៊ីប៉ូតែកមានសុពលភាព និងអាចយកមកតតាំងបានជាមួយតតិយជន។ តាមក្រមរដ្ឋប្បវេណី ហ៊ីប៉ូតែកត្រូវធ្វើតាមលិខិតយថាភូត ដែលលិខិតនេះត្រូវធ្វើតាមសារការី ឬ មន្ត្រីសាធារណៈដែលដាក់ឱ្យដំណើរការនូវការចុះបញ្ជី[5]។ ប៉ុន្តែនេះសម្រាប់ដីដែលមានប័ណ្ណកម្មសិទ្ធិតែប៉ុណ្ណោះ ដែលត្រូវបានចុះបញ្ជីហ៊ីប៉ូតែកនៅមន្ទីររៀបចំដែនដី នគរូបនីយកម្មសំណង់ និងសុរិយោដីរាជធានី/ខេត្ត។

### ២.១.២. សមត្ថភាពជាភាគី

បុគ្គលម្នាក់ៗមានសេរីភាព ក្នុងការបង្ហាញឆន្ទៈក៏ប៉ុន្តែ ដើម្បីឱ្យការបង្ហាញឆន្ទៈនេះប្រព្រឹត្តទៅបានប្រកបដោយប្រសិទ្ធិភាពមានភាពចាំបាច់ណាស់ ដែលគាត់ត្រូវមានសមត្ថភាពដែលអាចយល់ដឹង និងវិនិច្ឆ័យលើលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពដែលខ្លួនធ្វើ។ ដើម្បីដឹងថា តើបុគ្គលម្នាក់ៗមានសមត្ថភាពខាងឆន្ទៈ ឬក៏ខ្វះសមត្ថភាពខាងឆន្ទៈនោះ គឺត្រូវពិនិត្យមើលនូវលក្ខខណ្ឌក្នុងការវិនិច្ឆ័យដូចខាងក្រោម៖

តើបុគ្គលនោះអាចដឹងពីអត្ថន័យតាមផ្លូវច្បាប់នូវសកម្មភាពដែលខ្លួនបានធ្វើដែរឬទេ?

តើបុគ្គលនោះ អាចវិនិច្ឆ័យពីលទ្ធផលតាមផ្លូវច្បាប់នូវសកម្មភាពដែលខ្លួនបានធ្វើដែរឬទេ?

**ឧទាហរណ៍៖**

[5] មាត្រា ៩ ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី។

បុគ្គលដែលអសមត្ថភាពក្នុងការយល់ដឹងពីអត្ថន័យ និងអានុភាពនៃសកម្មភាពរបស់ខ្លួន ដោយសារការប្រើជាតិស្រវឹងឬសកម្រិត អាចចាត់ទុកថាគ្មានសមត្ថភាពខាងឆន្ទៈបាន។

ម្យ៉ាងទៀតកិច្ចសន្យាត្រូវធ្វើឡើងដោយជនមានសមត្ថកិច្ច។ ជនមានសមត្ថកិច្ច គឺជាជន ដែលមិនត្រូវបានគេកម្រិតសមត្ថភាពនោះមានដូចជា អនីតិជន[6] ( លើកលែងអនីតិជនដែលទទួលបានអត្តាធីនភាព ) ជននៅក្រោមអាណាព្យាបាលទូទៅ[7] ជននៅក្រោមរបបហិតូបត្ថម្ភ[8]ជាដើម។ ការកម្រិតអំពីសមត្ថភាពរបស់ភាគីនេះ គឺមានគោលបំណងដើម្បីការពារកុំឱ្យមានការខូចខាតដែលកើតឡើងដោយសារការី ធ្វើជំនួញរបស់អ្នកដែលពុំមានសមត្ថភាពគ្រប់គ្រាន់ក្នុងការធ្វើសកម្មភាព។

ជាលទ្ធផល វាមានភាពចាំបាច់ណាស់ក្នុងការចាត់ចំណាត់ថ្នាក់បុគ្គលដែលមិនមានសមត្ថភាពខាងឆន្ទៈ និងកម្រិតនូវសមត្ថភាពរបស់ពួកគាត់ក្នុងការធ្វើសកម្មភាពដើម្បីការពារសិទ្ធិរបស់ពួកគាត់ និងដើម្បីរក្សាស្ថិរភាពនៃប្រតិបត្តិការជំនួញ។

## ២.២. កម្មវត្ថុនៃការបង្កើតហ៊ីប៉ូតែកធម្មតា

តាមក្រមរដ្ឋប្បវេណី វត្ថុដែលអាចដាក់ហ៊ីប៉ូតែកបានគឺមាន អចលនវត្ថុ សិទ្ធិជួលអចិន្ត្រៃយ៍ ផលុបភោគ និងទ្រព្យផ្សេងទៀតដែលមានចែងក្នុងច្បាប់ពិសេស[9]។

### ២.២.១. អចលនវត្ថុ

កម្មវត្ថុនៃហ៊ីប៉ូតែក ត្រូវតែជាអចលនវត្ថុ ដែលជាកម្មសិទ្ធិ ឬ ចំណែកនៃកម្មសិទ្ធិអវិភាគរបស់កូនបំណុល ឬ តតិយជន[10]។ អចលនវត្ថុដែលគេស្គាល់ក្រោមច្បាប់ជាមូលដ្ឋានថាជាដីធ្លី និងវត្ថុជាប់នៅលើដី ហើយមិនអាចផ្លាស់ប្តូរទីកន្លែងបាន ដូចជាអាគារ សំណង់ ដំណាំ រុក្ខជាតិ ជាអាទិ៍[11]។

យោងតាមក្រមរដ្ឋប្បវេណី អចលនវត្ថុដែលជាកម្មវត្ថុនៃហ៊ីប៉ូតែក ជាគោលការណ៍វត្ថុដែលជាប់នឹងដី ឬវត្ថុដែលក្លាយជាភាគមួយនៃដី ជាពិសេស អាគារ ឬ សំណង់ដែលសង់នៅលើដី ហើយមិនអាចប្តូរកន្លែងបាន ឬពូជដែលសាបនៅលើដីដំណាំដែលបានដុះ រុក្ខជាតិដែលរស់នៅលើដី គឺ

[6] មាត្រា ១៧ ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។
[7] មាត្រា ២៤-២៧ ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។
[8] មាត្រា ២៨-៣១ ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។
[9] មាត្រា ៨៤៣.២ ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។
[10] មាត្រា ៨៤៣.១ ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។
[11] មាត្រា ១២០.២ ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

ជាសមាសភាគនៃដីនោះ លុះត្រាតែមិនបំបែកចេញពីដី ហើយមិនអាចក្លាយជាកម្មវត្ថុនៃសិទ្ធិឯករាជ្យបានឡើយ លើកលែងតែមានបញ្ញត្តិផ្សេង។ ពឹងផ្អែកទៅលើមាត្រាខាងលើនេះ បានន័យថា អាគារដែលជាកម្មវត្ថុនៃហ៊ីប៉ូតែក ពុំត្រូវបានចាត់ទុកអាគារនោះជាអចលនវត្ថុឯករាជ្យពីដីឡើយ។ ហេតុដូច្នេះ ប្រសិនបើហ៊ីប៉ូតែកត្រូវបានបង្កើតនៅលើដីមួយហើយ ជាគោលការណ៍ហ៊ីប៉ូតែក ត្រូវតែមានអានុភាពទៅលើដីដែលអាគារនោះស្ថិតនៅដោយស្វ័យប្រវត្តិ[12]។

លើសពីនេះទៅទៀត ដើម្បីបញ្ជាក់ថាអ្នកបង្កើតហ៊ីប៉ូតែកពិតជាម្ចាស់ទ្រព្យដែលដាក់ហ៊ីប៉ូតែក នីតិជាធរមានបានរំលេចចេញជាមាត្រាយ៉ាងច្បាស់ដោយបានចែងថា " មានតែអចលនវត្ថុដែលបានចុះបញ្ជីសុរិយោដីទេ ទើបអាចជាកម្មវត្ថុនៃហ៊ីប៉ូតែក " តាមអត្ថន័យនៃមាត្រានេះមានន័យថា ទ្រព្យដែលអាចយកធ្វើជាកម្មវត្ថុត្រូវតែជាអចលនវត្ថុ និងបានចុះបញ្ជីសុរិយោដីរួចហើយ។ ដូចនេះ ទ្រព្យសម្បត្តិទាំងឡាយណាជាអចលនវត្ថុដែលមិនទាន់បានចុះបញ្ជី មិនអាចយកមកធ្វើជាកម្មវត្ថុនៃហ៊ីប៉ូតែកបានឡើយ។ អចលនវត្ថុដែលបានចុះបញ្ជីនៅសុរិយោដីក្នុងន័យនេះ គឺជាអចលនវត្ថុដែលមានប័ណ្ណកម្មសិទ្ធិដែលចេញដោយ មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់និងសុរិយោដីរាជធានី/ខេត្ត។

ឧទាហរណ៍៖ ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលវត្ថុ , ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី ( ជាអចលនទ្រព្យដែលមិនបានចុះបញ្ជី ) ។ វិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុ ឬវិញ្ញាបនបត្រសម្គាល់ម្ចាស់ចំណែកឯកជន[13]។ ( ជាអចលនទ្រព្យដែលបានចុះបញ្ជី )

### ២.២.២. សិទ្ធិជួលអចិន្ត្រៃយ៍ និងផលុបភោគ

ក្រៅពីអចលនវត្ថុ ហ៊ីប៉ូតែកត្រូវបានទទួលស្គាល់ផងដែរឱ្យបង្កើតលើសិទ្ធិលើអចលនវត្ថុដែលកម្រិតត្រឹម សិទ្ធិជួលអចិន្ត្រៃយ៍ និងផលុបភោគ។ ហេតុផលដែលអនុញ្ញាតឱ្យអ្នកប្រើប្រាស់សិទ្ធិជួលអចិន្ត្រៃយ៍ ឬសិទ្ធិផលុបភោគ ដែលជាសិទ្ធិដែលមានលើដីរបស់អ្នកដទៃ មកធ្វើជាកម្មវត្ថុនៃសិទ្ធិហ៊ីប៉ូតែក គឺដោយសារតែបញ្ញត្តិក្នុងក្រមរដ្ឋប្បវេណីបានចែងថា ប្រសិនបើអ្នកដែលមានសិទ្ធិជួលអចិន្ត្រៃយ៍ ឬសិទ្ធិផលុបភោគបានសង់សំណង់នៅលើដី ឬដាំរុក្ខជាតិ ឬដំណាំជាអាទិ៍ ដែលជាការអនុវត្តសិទ្ធិលើដីអ្នកដទៃ វត្ថុទាំងនេះមិនត្រូវបានក្លាយជាសមាសភាគនៃដីទេ ដែលមានន័យថា

[12] មាត្រា ១២២ ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

[13] សូមមើលឧបសម្ព័ន្ធទី១ អំពីគំរូប័ណ្ណសម្គាល់កម្មសិទ្ធិ។

ចំពោះអ្នកមានសិទ្ធិជួលអចិន្ត្រៃយ៍ ឬសិទ្ធិផលុបភោគ អាចប្រើប្រាស់អាគារ ដែលជាអចលនវត្ថុ បង្កើតសិទ្ធិហ៊ីប៉ូតែកបាន[14]។

**សិទ្ធិជួលអចិន្ត្រៃយ៍** គឺជាសិទ្ធិដែលកើតឡើងដោយដោយកិច្ចសន្យាជួលអចិន្ត្រៃយ៍។ អនុលោមតាមក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា សិទ្ធិជួលអចិន្ត្រៃយ៍ សំដៅទៅលើសិទ្ធិជួលអចលនវត្ថុរយៈពេលវែង ចាប់ពី(១៥ឆ្នាំទៅដល់ ៥០ឆ្នាំ)[15]។ សិទ្ធិនេះមានអានុភាពតាមផ្លូវច្បាប់លុះត្រាតែត្រូវបានធ្វើឡើងជាលាយលក្ខណ៍អក្សររវាងគូភាគី។ សិទ្ធិជួលអចិន្ត្រៃយ៍ មិនអាចយកសិទ្ធិជួលរបស់ខ្លួនទៅតតាំងចំពោះតតិយជនបានឡើយ បើមិនបានចុះបញ្ជី។ ករណីដែលបានចុះបញ្ជីរួចហើយអាចធ្វើការតតាំងនឹងអនុប្បទានិក។ អនុប្បទានិក គឺសំដៅទៅលើ ជនម្នាក់ដែលគេធ្វើអនុប្បទានឱ្យ ឬក៏គេផ្ទេរកម្មសិទ្ធិដីធ្លីឱ្យ។ នៃកម្មសិទ្ធិដីដែលជាកម្មវត្ថុនៃសិទ្ធិជួលអចិន្ត្រៃយ៍បានទោះ បីជាកម្មសិទ្ធិលើដីនោះត្រូវបានធ្វើអនុប្បទានក៏ដោយ។ អនុប្បទាន គឺការផ្ទេរសិទ្ធិ ឬទ្រព្យសម្បត្តិរបស់បុគ្គលណាម្នាក់ ដែលជាអនុប្បទាយី ទៅឱ្យបុគ្គលម្នាក់ទៀត ដែលជា អនុប្បទានិក។

អ្នកជួលអចិន្ត្រៃយ៍អាចធ្វើអនុប្បទាន (ផ្ទេរ) នូវសិទ្ធិជួលអចិន្ត្រៃយ៍នោះទៅឱ្យបុគ្គលដ៏ទៃបាន។ ជាការពិតណាស់ សិទ្ធិជួលអចិន្ត្រៃយ៍ គឺជាប្រភេទមួយនៃសិទ្ធិប្រាតិភោគប្រត្យក្សដែលសិទ្ធិនេះក្លាយជាកម្មវត្ថុនៃការធ្វើអនុប្បទានដោយផ្អែកទៅលើគោលការណ៍នេះ អ្នកជួលអចិន្ត្រៃយ៍អាចធ្វើអនុប្បទានសិទ្ធិជួលអចន្ត្រៃយ៍របស់ខ្លួនតាមរយៈ ការជួលបន្តឱ្យអ្នកដ៏ទៃ ការដូរ ការធ្វើអំណោយ ឬសន្តតិកម្ម។ (ចំពោះសិទ្ធិជួលអចន្ត្រៃយ៍ដែលមិនបានចុះបញ្ជីនៃមាត្រា៥៩៨ នៃក្រមរដ្ឋប្បវេណីនេះត្រូវយកមកអនុវត្តរហូតដល់គ្រប់អំឡុងពេល១៥ឆ្នាំ)[16]។

ការបង្កើតហ៊ីប៉ូតែត លើសិទ្ធិជួលអចិន្ត្រៃយ៍ មានសារប្រយោជន៍ដូចជា៖

**ចំពោះម្ចាស់បំណុល**

- គ្មានបន្ទុកក្នុងការគ្រប់គ្រងសិទ្ធិជួលអចិន្ត្រៃយ៍ បានន័យថា ម្ចាស់បំណុលមិនត្រូវបានទទួលនូវការផ្ទេរសិទ្ធិជួលអចិន្ត្រៃយ៍ឱ្យកាន់កាប់ឡើយ។

---

[14] ម៉ៅសិលា"ជំនួយស្មារតី៖ និយមន័យ និងការចុះបញ្ជីហ៊ីប៉ូតែកនៅកម្ពុជា"ការផ្សព្វផ្សាយរបស់សមាគមសាលាត្រាជូ ខែមករា ឆ្នាំ២០១៨, http://salatraju.com/post/349 ទំព័រ៣, ថ្ងៃ១៤ ខែមិថុនា ឆ្នាំ២០២១។

[15] មាត្រា ២៤៤ ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

[16] មាត្រា ៥៩៨ ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

- មានសិទ្ធិទទួលសំណងជាអាទិភាព។

**ចំពោះអ្នកបង្កើតហ៊ីប៉ូតែក**

- អាចបន្តនូវការកាន់កាប់ ប្រើប្រាស់ អាស្រ័យផល នូវសិទ្ធិជួលអចិន្ត្រៃយ៍នោះ ហើយអាចបង្កើតចំណូលដើម្បីសងបំណុល ដោយហេតុថា ការធានាតាមរយៈហ៊ីប៉ូតែកក៏ការពារកូនបំណុលផងដែរ តាមរយៈការអនុញ្ញាតឱ្យកូនបំណុលប្រើប្រាស់ឱ្យអស់ពីលទ្ធភាពពីតម្លៃនៃវត្ថុ ដូចជា ការបង្កើតហ៊ីប៉ូតែកច្រើនដងលើវត្ថុតែមួយ ហើយលំដាប់អាទិភាពត្រូវបានកំណត់យកពេលវេលានៃការចុះបញ្ជី។

__**ឧទាហរណ៍៖**__ A មានសិទ្ធិជួលអចិន្ត្រៃយ៍នៅលើដី B ហើយបានដាំដំណាំនៅលើដីនោះដើម្បីជីវភាពរស់នៅរបស់ខ្លួន។ A មានគម្រោងខ្ចីលុយពីធនាគារ C ចំនួន ១០០០ ដុល្លារ ក្នុងគោលបំណងទិញសម្ភារៈសម្រាប់ប្រើប្រាស់ក្នុងការដាំដុះ ដើម្បីបង្កើនបរិមាណទិន្នផល ក៏ប៉ុន្តែគាត់មិនមានទ្រព្យសម្បត្តិអ្វីទេ ក្រៅពីសិទ្ធិជួលអចិន្ត្រៃយ៍ ដែលមានតម្លៃខ្ពស់ជាង ១០០០ ដុល្លារ។

នៅក្នុងករណីនេះ ប្រសិនបើ A លក់សិទ្ធិជួលអចិន្ត្រៃយ៍នេះទៅឱ្យអ្នកដទៃ នោះ A អាចទទួលបានប្រាក់ច្រើនជាង ១០០០ ដុល្លារ ហើយគាត់អាចទិញសម្ភារៈបាន ប៉ុន្តែគាត់មិនអាចធ្វើការដាំដុះនៅលើដី B ទៀតបានទេ ព្រោះ A បាត់បង់សិទ្ធិជួលអចិន្ត្រៃយ៍នៅលើដី B ។ ផ្ទុយទៅវិញ ប្រសិនបើ A យកសិទ្ធិជួលអចិន្ត្រៃយ៍ទៅបង្កើតហ៊ីប៉ូតែកឱ្យ C ដើម្បីធានាបំណុលនោះ C អាចឱ្យ A ខ្ចីលុយចំនួន ១០០០ ដុល្លារ ហើយ A អាចទិញសម្ភារៈទាំងនោះបាន។ ជាងនេះទៅទៀត A អាចដាំដំណាំនៅលើដីនោះបាន ព្រោះអ្នកបង្កើតហ៊ីប៉ូតែក នៅតែអាចកាន់កាប់ដី B បានដដែល។ ជាការពិត C មិនចាំបាច់ហត់នឿយក្នុងការមើលថែទាំដី A នោះទេ។ ប្រសិនបើ A មិនអាចសងបំណុលបាននៅពេលដល់កាលកំណត់ត្រូវសង នោះ C អាចដាក់ពាក្យសុំលក់ដោយបង្ខំចំពោះសិទ្ធិជួលអអចិន្ត្រៃយ៍ដែលមាននៅលើដី B ហើយអាចទទួលបានការសងតាមរយៈការចែកចំណែករហូតដល់ ១០០០ ដុល្លារ និងការប្រាក់ ជាអាទិ៍ផងដែរ[17] ។

បន្ថែមពីនេះទៅទៀត ហ៊ីប៉ូតែក មានអត្ថិភាព ( អត្ថិភាព គឺភាពកើតមាន ភាពស្ថិតនៅ ភាពនៃអ្វីៗដែលមាន ) ដរាបណាសិទ្ធិលើបំណុលដែលត្រូវបានធានា នៅតែមានអត្ថិភាព ( មាត្រា ៧៦៩ នៃក្រមរដ្ឋប្បវេណី) លើកលែង គន្ថីទី ៦ ជំពូក ៥ ផ្នែកទី ៦ នៃក្រមរដ្ឋប្បវេណី។ ដូច្នេះ ហ៊ីប៉ូតែកលើសិទ្ធិជួលអចិន្ត្រៃយ៍ គឺមានអានុភាពត្រឹមរយៈពេលនៃសិទ្ធិជួលអចិន្ត្រៃយ៍ប៉ុណ្ណោះ។ តាមមាត្រា ២៤៤

[17] មាត្រា ៨៥២ ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

និងមាត្រា ២៤៧ នៃក្រមរដ្ឋប្បវេណី៖ សិទ្ធិជួលអចិន្ត្រៃយ៍ ជាសិទ្ធិជួលអចលនវត្ថុ ដែលមានរយៈពេលវែងចាប់ពី ១៥ឆ្នាំ ឡើងទៅ ហើយមិនអាចឱ្យលើសពី៥០ឆ្នាំបានឡើយ។

ឧទាហរណ៍៖ កិច្ចសន្យាជួលអចលនវត្ថុមួយ ដែលមានសិទ្ធិជួលអចិន្ត្រៃយ៍រយៈពេល ២០ ឆ្នាំ។ ករណីផុតអំឡុងពេលជួលនេះ ហ៊ីប៉ូតែកត្រូវរលត់។

**ផលុបភោគ**

ផលុបភោគ គឺជាសិទ្ធិមួយប្រភេទនៃសិទ្ធិប្រត្យក្សប្រើប្រាស់ និងអាស្រ័យផល។ ផលុបភោគ គឺជាសិទ្ធិប្រើប្រាស់ និងអាស្រ័យផលលើអចលនវត្ថុដែលជាកម្មសិទ្ធិរបស់អ្នកដ៏ទៃ ក្នុងអំឡុងពេលកំណត់ណាមួយដែលមិនអាចលើសពីមួយជីវិតរបស់ផលុបភោគី ( អ្នកទទួលបានផលុបភោគ )។ យោងតាមក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ កម្មវត្ថុនៃកិច្ចសន្យាហ៊ីប៉ូតែកមិនត្រឹមតែកម្រិតត្រឹមអចលនវត្ថុតែប៉ុណ្ណោះទេ។ ក្រមនេះបានពង្រីកវិសាលភាពកម្មវត្ថុនៃហ៊ីប៉ូតែកដែលអាចឱ្យ ផលុបភោគ ក្លាយជាកម្មវត្ថុនៃហ៊ីប៉ូតែក បានដោយពេញលេញនិងត្រឹមត្រូវតាមច្បាប់។

<u>ឧទាហរណ៍៖</u> លោក ក ជាកម្មសិទ្ធករ នៃដី L មួយកន្លែង។ លោក ក ដែលជាកម្មសិទ្ធិករ មានសិទ្ធិប្រើប្រាស់ ចាត់ចែង និងអាស្រ័យផល លើដីរបស់ខ្លួន។ ថ្ងៃមួយ លោក ក បានប្រគល់សិទ្ធិផលុបភោគ ទៅឱ្យលោក ខ។ ដូច្នេះ លោក ខ ត្រូវបានគេឱ្យឈ្មោះថា ផលុបភោគី។ ផលុបភោគីគាត់មានតែសិទ្ធិប្រើប្រាស់ និងសិទ្ធិអាស្រ័យផល តែគាត់អត់មានសិទ្ធិចាត់ចែងនោះទេ។ បានន័យថា លោក ខ ដែលទទួលបានសិទ្ធិផលុបភោគពីលោក ក គាត់អាចប្រើប្រាស់ដីនោះឱ្យអស់ពីលទ្ធភាពរបស់ខ្លួនទៅតាមតម្រូវការជាក់ស្តែង ដូចជា បង្កើតអាជីវកម្ម លក់ដូរ បើកហាង ដាំដំណាំ បង្កបង្កើនផលនៅលើដីនោះបាន ប៉ុន្តែគាត់មិនអាចចាត់ចែងដីនោះ តាមរយៈ ការជួល ការលក់ បាននោះទេ។

ផលុបភោគ អាចបង្កើតបានតាមលិខិតលាយលក្ខណ៍អក្សរ ឬមិនតាមលិខិតលាយលក្ខណ៍អក្សរបាន( ផ្ទាល់មាត់ ) ហើយចំពោះរយៈពេលនៃការបង្កើតផលុបភោគ អាចបង្កើតក្នុងរយៈពេលកំណត់ណាមួយ ដែលមិនឱ្យលើសពីមួយជីវិតរបស់ផលុបភោគី។ បន្ទាប់ពីការបង្កើតផលុបភោគរួចដើម្បីមានសិទ្ធិតតាំងចំពោះបុគ្គលផ្សេងដែលអះអាងលើអចលនវត្ថុ ( ដី,អាគារ/ផ្ទះ ) ផលុបភោគត្រូវចុះបញ្ជីនៅមន្ទីររៀបចំដែនដី នគររូបនីយកម្ម និង សំណង់។

ផលុបភោគី មានសិទ្ធិអាស្រ័យផលធម្មជាតិ (ផលិតផលដែលកើតអំពីដីធ្លី ឬកូនសត្វស្រុកដែលកើតចេញពី មេបាវាមក ) និងផលស៊ីវិល ( ប្រាក់ ឬវត្ថុផ្សេងៗដែលទទួលជាថ្នូរចំពោះការប្រើប្រាស់វត្ថុណាមួយ )។ ផលុបភោគី មិនអាចយកផលុបភោគរបស់ខ្លួនទៅតតាំងចំពោះតតិយជន

បានឡើយ ប្រសិនបើមិនបានចុះបញ្ជី ហើយចំពោះផលុបភោគដែលបានចុះបញ្ជីហើយ អាចតតាំងចំពោះអនុប្បទានិកនៃអចលនវត្ថុដែលជាកម្មវត្ថុនៃផលុបភោគបាន ទោះបីជាកម្មសិទ្ធិលើអចលនវត្ថុនោះត្រូវបានធ្វើអនុប្បទានក៏ដោយ។ មានន័យថា ក្នុងករណីដែលផលុបភោគីមិនបានយកផលុបភោគរបស់ខ្លួនទៅចុះបញ្ជីនោះទេ នៅពេលដែលកម្មសិទ្ធិករធ្វើអនុប្បទាននូវវត្ថុដែលជាកម្មវត្ថុនៃផលុបភោគ ផលុបភោគីមិនអាចតតាំង ឬទាមទារសិទ្ធិរបស់ខ្លួនដែលមានលើវត្ថុដែលជាកម្មវត្ថុនៃផលុបភោគជាមួយតតិយជនដែលជាអនុប្បទានិកបានឡើយ។

ឧទាហរណ៍ ៖ បុគ្គល ក មានដី១កន្លែង ចឹងបុគ្គល ក គឺជាអនុប្បទាយី។ ក បានប្រគល់សិទ្ធិផលុបភោគទៅឱ្យឈ្មោះ ខ អញ្ចឹង ខ ត្រូវបានគេហៅគាត់ថា ផលុបភោគី។ ស្រាប់តែថ្ងៃក្រោយមក ក បានធ្វើអនុប្បទានដីនេះ តាមរយៈការលក់ដូរ ទៅឱ្យឈ្មោះ គ ចឹងឈ្មោះ គ គឺជាអនុប្បទានិក ចឹងគាត់បានទទួលការធ្វើអនុប្បទានពី ក ។ អញ្ចឹង នៅករណីនេះ ផលុបភោគីឈ្មោះ ខ បើសិនគាត់បានចុះបញ្ជីទាក់ទងទៅនឹងសិទ្ធិផលុបភោគរបស់គាត់នេះ អញ្ចឹងគឺគាត់អាចធ្វើការតតាំងជាមួយអ្នកទិញដីរបស់ ក គឺបុគ្គល គ គឺអនុប្បទានិក គ ។ អញ្ចឹងបានន័យថា ជាធម្មតាយើងអ្នកទិញត្រូវមើលថាដីនឹងវាជាប់ទៅដោយផលុបភោគឬអត់ ចឹងមានន័យថា បើយើងយល់ព្រមទិញ ដីដែលជាប់ទៅដោយផលុបភោគ ចឹងយើងត្រូវទទួលយកនូវផលចឹងដូចគ្នា ចឹងបានន័យថាផលុបភោគីគាត់អាចតតាំងជាមួយនឹងអនុប្បទានិកបាន ប្រសិនបើគាត់ បានចុះបញ្ជីត្រឹមត្រូវតាមផ្លូវច្បាប់ ចឹងនេះគឺជាសិទ្ធិនៅក្នុងការតតាំងរបស់ផលុបភោគីទៅលើការ ធ្វើអនុប្បទាននៃកម្មសិទ្ធិណាមួយរបស់កម្មសិទ្ធិករ។

### ២.២.៣. ទ្រព្យផ្សេងទៀតកំណត់ដោយច្បាប់ពិសេស

ជាគោលការណ៍ ក្រមរដ្ឋប្បវេណីទទួលស្គាល់ការបង្កើតហ៊ីប៉ូតែកចំពោះអចលនវត្ថុ សិទ្ធិជួលអចិន្ត្រៃយ៍ និងផលុបភោគតែប៉ុណ្ណោះ បន្ថែមលើនេះច្បាប់ពិសេសទទួលស្គាល់ការយកទ្រព្យសម្បត្តិផ្សេងក្រៅពីអចលនវត្ថុមកធ្វើជាកម្មវត្ថុនៃហ៊ីប៉ូតែក យើងត្រូវទទួលស្គាល់ការបង្កើតហ៊ីប៉ូតែកតាមប្រភេទផ្សេងនោះដែរ។ ចំពោះពាក្យថាទ្រព្យផ្សេងទៀតដែលមានចែងក្នុងច្បាប់ពិសេសមានដូចជារថយន្ត និងនាវាជាអាទិ៍ ដែលមានប្រព័ន្ធចុះបញ្ជី។ គួរបញ្ជាក់ផងដែរ ដោយហេតុថាហ៊ីប៉ូតែកអាចនាំទៅដល់ការរលត់ទ្រព្យហ៊ីប៉ូតែកដោយបង្ខំ ហេតុនេះមានតែទ្រព្យដែលអាចផ្ទេរបានតែប៉ុណ្ណោះដែលអាចយកមកដាក់ហ៊ីប៉ូតែកបាន។ ចំពោះទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ឬទ្រព្យដែលត្រូវបានរឹបអូសឃាត់ទុក ពុំអាចដាក់ហ៊ីប៉ូតែកបានឡើយ។

## កថាភាគទី៣. លក្ខខណ្ឌទម្រង់នៃកិច្ចសន្យាហ៊ីប៉ូតែក

### ៣.១. លក្ខខណ្ឌតតាំងនៃកិច្ចសន្យា

ទំនាក់ទំនងគតិយុត្តនៃកិច្ចសន្យាហ៊ីប៉ូតែកមាន ២លក្ខខណ្ឌផ្សេងគ្នា ដែលលក្ខខណ្ឌទី១ គឺជាលក្ខខណ្ឌសុពលភាពរបស់គូភាគី ដែលលក្ខខណ្ឌទី១ នេះបកស្រាយនៅក្នុងកថាខណ្ឌខាងលើរួចហើយដែលនិយាយអំពីលក្ខខណ្ឌសុពលភាពនៃការបង្កើតកិច្ចសន្យាហ៊ីប៉ូតែករវាងគូភាគី។ ងាកមកលក្ខខណ្ឌទម្រង់វិញ ដែលជាលក្ខខណ្ឌទី២ គឺជាលក្ខខណ្ឌតតាំងនៃកិច្ចសន្យាហ៊ីប៉ូតែកចំពោះតតិយជនដែលមិនមែនជាគូភាគី។ លក្ខខណ្ឌតតាំងគឺ សំដៅទៅលើលក្ខខណ្ឌសម្រាប់ធ្វើការអះអាងអំពីអានុភាពចំពោះតតិយជនទាក់ទងទៅនឹងការបង្កើត ការផ្ទេរ និងការកែប្រែនូវសិទ្ធិប្រត្យក្ស ឬនិយាយមួយបែបទៀតថា ជាលក្ខខណ្ឌដែលធ្វើឱ្យការបង្កើត ការផ្ទេរ និងការកែប្រែនូវសិទ្ធិប្រត្យក្សមានអានុភាពចំពោះតតិយជន[18]។

ហ៊ីប៉ូតែក ជាសិទ្ធិមួយដែលកើតឡើងតាមកិច្ចសន្យារបស់គូភាគីនោះ ប៉ុន្តែក៏មានលក្ខខណ្ឌដោយឡែក សម្រាប់តតាំងជាមួយតតិយជនផងដែរ។ អនុលោមតាមមាត្រា ៨៤៤ នៃក្រមរដ្ឋប្បវេណី ស្តីពី ការតតាំងនៃហ៊ីប៉ូតែក ម្ចាស់បំណុលហ៊ីប៉ូតែក មិនអាចយកហ៊ីប៉ូតែកនោះមកតតាំងចំពោះតតិយជន ក្រៅពីអ្នកដែលអ្នកបង្កើត ហ៊ីប៉ូតែកបានឡើយ ប្រសិនបើមិនបានធ្វើកិច្ចសន្យាហ៊ីប៉ូតែកដោយលិខិតយថាភូត និងមិនបានចុះបញ្ជីនៅក្នុងសៀវភៅបញ្ជីដីធ្លីទេ[19]។ ហ៊ីប៉ូតែក ជាសិទ្ធិដែលមិនមែនមានឥទ្ធិពលចំពោះតែម្ចាស់បំណុល និងកូនបំណុលប៉ុណ្ណោះនោះទេ ប៉ុន្តែថែមទាំងមានឥទ្ធិពលចំពោះតតិយជនផ្សេងទៀត ដូចជាជនដែលទិញដីជាប់ហ៊ីប៉ូតែកនោះ និងម្ចាស់បំណុលផ្សេងទៀត ដែលមិនមែនជាម្ចាស់បំណុលហ៊ីប៉ូតែក[20]។ ហេតុនេះ ការយល់ដឹងអំពីលក្ខខណ្ឌតម្រូវតាមច្បាប់សម្រាប់ឱ្យម្ចាស់សិទ្ធិហ៊ីប៉ូតែក អាចតតាំងនូវសិទ្ធិហ៊ីប៉ូតែករបស់ខ្លួនជាមួយតតិយជនបានជាប្រការមួយដែលចាំបាច់។ សរុបមកវិញ នៅក្នុងចំណុចនេះបានបញ្ជាក់ឱ្យឃើញថាក្នុងការតតាំងនៃ ហ៊ីប៉ូតែក គឺមានលក្ខខណ្ឌចំនួន ០២ (ពីរ)៖

- កិច្ចសន្យាហ៊ីប៉ូតែកដោយលិខិតយថាភូត
- ការចុះបញ្ជីហ៊ីប៉ូតែក។

[18] "សញ្ញាណទូទៅនៃហ៊ីប៉ូតែក" រៀបរៀងដោយក្រុមការងារ៖ The Share ខែមករា ឆ្នាំ២០១៨ ទំព័រ ៣។

[19] មាត្រា ៨៤៤ ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

[20] មាត្រា៨៤៥ សេចក្តីកំណត់ចំពោះមាត្រានីមួយៗ ឆ្នាំ ២០១០ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

### ៣.១.១. ការតាក់តែងជាលិខិតយថាភូត

ការតាក់តែងលិខិតយថាភូត គឺសំដៅលើឯកសារដែលចាំបាច់សម្រាប់ធ្វើការចុះបញ្ជី។ លិខិតនេះត្រូវធ្វើឡើងដោយសារការី ឬលិខិតឯកជនដែលសារការីបានចុះនិទ្ទេសថា លិខិតនោះមានភាពត្រឹមត្រូវតាមច្បាប់ដោយមានការចុះកាលបរិច្ឆេទ និងចុះហត្ថលេខាបញ្ជាក់ថាលិខិតនោះមានភាពច្បាស់លាស់។ ហើយការធ្វើកិច្ចសន្យាតាមលិខិតយថាភូតនោះ គឺដាច់ខាតត្រូវតែមានមន្ត្រីដែលមានសមត្ថកិច្ចចូលរួម។ នៅពេលនោះហើយទើបកិច្ចសន្យាផ្ទេរកម្មសិទ្ធិ និងការចាត់ចែងហ៊ីប៉ូតែកនឹងបង្កើតអានុភាពតាមច្បាប់។

លិខិតយថាភូត ដែលកំណត់ក្នុងក្រមរដ្ឋប្បវេណី ជាពិសេសពាក់ព័ន្ធជាមួយលិខិតយថាភូតដែលមានចែងក្នុងហ៊ីប៉ូតែក មានអត្ថន័យផ្សេងៗគ្នាៈ

លិខិតយថាភូតដែលកំណត់ក្នុងមាត្រា ៨៦២ ចែងអំពី អានុភាពនៃការចាត់ចែងហ៊ីប៉ូតែក នៃក្រមរដ្ឋប្បវេណី សំដៅទៅលើលិខិតដែលត្រូវធ្វើឡើងដោយសារការី ឬ លិខិតឯកជន ដែលសារការីចុះនិទ្ទេសថា លិខិតនោះមានភាពត្រឹមត្រូវតាមច្បាប់ និងចុះកាលបរិច្ឆេទ និងហត្ថលេខា ក្រោយពេលខ្លួនបញ្ជាក់ថាលិខិតនោះ មានភាពត្រឹមត្រូវតាមច្បាប់។ ក្នុងមាត្រានេះដដែល លិខិតដែលមន្ត្រីមានសមត្ថកិច្ចធ្វើឡើង ដើម្បីធ្វើនីតិវិធីនៃការចុះបញ្ជី ក៏ជាលិខិតយថាភូតដែរ។

លិខិតយថាភូតដែលកំណត់ក្នុងមាត្រា ៨៤៥ ចែងអំពី ការតតាំងនៃហ៊ីប៉ូតែក នៃក្រមរដ្ឋប្បវេណី សំដៅទៅលើលិខិតដែលមន្ត្រីមានសមត្ថកិច្ចធ្វើឡើងដើម្បីធ្វើនីតិវិធីនៃការចុះបញ្ជី[21]។

យើងអាចនិយាយម្យ៉ាងទៀតថា លិខិតយថាភូតគឺជា ឯកសារដែលសរសេរឈ្មោះអត្តសញ្ញាណដីដែលជាកម្មវត្ថុនៃការចុះបញ្ជី និងចំណុចផ្សេងទៀតដែលត្រូវសរសេរចូលទៅក្នុងទម្រង់ជាក់លាក់មួយ ហើយមាន អនុប្បទាយី អនុប្បទានិក សាក្សីពីររូប ផ្តិតស្នាមមេដៃ និងមេឃុំចៅសង្កាត់ ឬចៅហ្វាយស្រុក ខណ្ឌ ចុះហត្ថលេខា និងប្រថាប់ត្រាផ្លូវការផងដែរ ចំពោះមុខការិយាល័យចុះបញ្ជី។ តាមការអនុវត្តបច្ចុប្បន្ន ទម្រង់លិខិតយថាភូត គឺជាលក្ខខណ្ឌមួយចម្បងសម្រាប់ការចុះបញ្ជីហ៊ីប៉ូតែកនៅមន្ទីសុរិយោដី ព្រោះថាបើកិច្ចសន្យាមិនមានទម្រង់ជាលិខិតយថាភូតទេ មន្ត្រីសុរិយោដី នឹងមិនចុះបញ្ជីហ៊ីប៉ូតែកឱ្យនោះទេ។

[21] មាត្រា ៩ ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណីឆ្នាំ ២០១១។

### ៣.១.២. ការចុះបញ្ជីសុរិយោដី

ការចុះបញ្ជីនៅក្នុងសៀវភៅដីធ្លី ទោះបីជាក្នុងនោះមានកិច្ចសន្យាបង្កើតហ៊ីប៉ូតែករវាងគូរភាគី បានធ្វើជាទម្រង់លិខិតយថាភូតហើយក៏ដោយ ក៏នៅមិនទាន់គ្រប់លក្ខខណ្ឌដើម្បីតតាំងជាមួយ តតិយជនបាននោះឡើយ ពោលគឺច្បាប់បានតម្រូវឱ្យមានការចុះបញ្ជីនៅអាជ្ញាធរមានសមត្ថកិច្ច។ ការណ៍ដែលតម្រូវឱ្យចុះបញ្ជីនោះគឺដើម្បីជូនដំណឹងដល់សាធារណជនឱ្យបានដឹង ពីព្រោះនៅពេល ដែលអចលនវត្ថុមួយចំនួនត្រូវបានដាក់ហ៊ីប៉ូតែក ម្ចាស់បំណុលនឹងទទួលបានការសងសិទ្ធិលើ បំណុលរបស់ខ្លួនពីអចលនវត្ថុហ៊ីប៉ូតែកនោះ ដោយអាទិភាពជាងម្ចាស់បំណុលផ្សេងទៀត។ ហេតុ នេះ វាទាមទារឱ្យមានការប្រកាសជាសាធារណៈនូវសិទ្ធិនោះតាមរយៈការចុះបញ្ជីសុរិយាដី ដើម្បីឱ្យ តតិយជនក្រៅពីគូភាគីនៃកិច្ចសន្យាអាចមើលឃើញនិងបានដឹងអំពីសិទ្ធិនោះ។ នៅពេលដែលមាន ការចុះបញ្ជីហ៊ីប៉ូតែកនោះហើយ សូម្បីតែអ្នកដែលទិញអចលនវត្ថុដែលជាប់ហ៊ីប៉ូតែកដោយការចុះ បញ្ជី មិនអាចបដិសេធនូវអានុភាពនៃហ៊ីប៉ូតែកនោះបានទេ។ ចំពោះនីតិវិធីនៃការចុះបញ្ជី គឺមានចែង នៅក្នុងប្រកាសអន្តរក្រសួងស្តីពីនីតិវិធីនៃការចុះបញ្ជីអំពីសិទ្ធិប្រត្យក្សទាក់ទងនឹងក្រមរដ្ឋប្បវេណី[22]។

សរុបមក ដើម្បីតតាំងហ៊ីប៉ូតែកចំពោះតតិយជន កិច្ចសន្យាត្រូវគោរពតាមលក្ខខណ្ឌពីរគឺ៖

- ត្រូវធ្វើជាទម្រង់យថាភូត
- ត្រូវយកកិច្ចសន្យាហ៊ីប៉ូតែកនោះទៅចុះបញ្ជីសុរិយាដី។

## ផ្នែកទី២. អានុភាពនៃហ៊ីប៉ូតែក

ការកំណត់ អំពីអានុភាពនៃហ៊ីប៉ូតែកគឺជាចំណុចសំខាន់មួយដើម្បីពិនិត្យលើលក្ខណៈនៃការ អនុវត្ត មុននឹងបង្ហាញអំពីការរលត់នៃហ៊ីប៉ូតែក។ នៅពេលដែលបានបង្កើតសិទ្ធិហ៊ីប៉ូតែកតាម លក្ខខណ្ឌដែលច្បាប់តម្រូវរួចហើយ ហ៊ីប៉ូតែកនឹងកើតឡើងនូវអានុភាពរបស់ខ្លួន ទៅលើវត្ថុដែល ភ្ជាប់ទៅនឹងដីដែលជាកម្មវត្ថុនៃហ៊ីប៉ូតែក នៅពេលបង្កើតហ៊ីប៉ូតែក ដោយរាប់បញ្ចូលនូវវត្ថុដែលភ្ជាប់ នៅពេលបង្កើតហ៊ីប៉ូតែក ផងដែរ។ យោងតាមក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ អានុភាពនៃហ៊ីប៉ូតែក មាន ចែងនៅក្នុងជំពូកទី៥ ផ្នែកទី៣ ពីមាត្រា ៨៤៦ ដល់មាត្រា ៨៥២ មានដូចជា ទំហំនៃអានុភាពហ៊ីប៉ូ តែក ( **កថាខណ្ឌទី១** ) ឧបាទេសកម្មលើវត្ថុ ( **កថាខណ្ឌទី២** ) សិទ្ធិទាមទារសំណងរបស់អ្នកធានា

[22] ប្រកាសអន្តរក្រសួងស្តីពីនីតិវិធីនៃការចុះបញ្ជី អំពីសិទ្ធិប្រត្យក្សទាក់ទងនិងក្រមរដ្ឋប្បវេណី។

ដោយវត្ថុ ( **កថាខណ្ឌទី៣** ) លំដាប់នៃហ៊ីប៉ូតែក ( **កថាខណ្ឌទី៤** ) និង ទំហំនៃសិទ្ធិលើបំណុលដែលត្រូវបានធានា ( **កថាខណ្ឌទី៥** )។

## កថាភាគទី១. ទំហំអានុភាពនៃហ៊ីប៉ូតែក

ទំហំនៃអានុភាពហ៊ីប៉ូតែក គឺសំដៅទៅលើអានុភាពដែលគ្របដណ្តប់លើវត្ថុដែលភ្ជាប់ទៅនឹងដីមួយកន្លែង ហ៊ីប៉ូតែកមានអានុភាពលើវត្ថុដែលភ្ជាប់និងដីនោះរួមទាំងអាគារ ដែលមាននៅលើដីដែលជាប់ហ៊ីប៉ូតែកនោះផងដែរ។ ទោះបីជាអាគារនោះត្រូវសង់នៅមុនពេល ឬក្រោយពេលបង្កើតហ៊ីប៉ូតែកក៏ដោយ ហើយដែលភាគីមិនកំណត់នូវលក្ខខណ្ឌផ្សេងពីនេះ នៅក្នុងកិច្ចសន្យាហ៊ីប៉ូតែករបស់ខ្លួនបានឡើយ[23]។

**ឧទាហរណ៍១៖** លោក A គឺជាម្ចាស់ដីមួយកន្លែង។ លោក A បានសាងសង់អាគារមួយនៅលើដីនោះមុនការបង្កើតសិទ្ធិលើហ៊ីប៉ូតែក។ ក្រោយមក លោក A បានបង្កើតសិទ្ធិហ៊ីប៉ូតែកនៅលើដីនេះទៅឱ្យលោក B ពេលនោះអានុភាពនៃហ៊ីប៉ូតែករបស់លោក B គឺមាននៅលើដី និងអាគារផង។ ( **ករណីអាគារត្រូវបានសាងសង់មុនពេលបង្កើតហ៊ីប៉ូតែក** )។

**ឧទាហរណ៍២៖** លោក A ជាម្ចាស់ដីមួយកន្លែង។ លោក A បានយកដីនោះទៅបង្កើតសិទ្ធិហ៊ីប៉ូតែកឱ្យលោក B ដែលជាម្ចាស់បំណុល។ ក្រោយពេលបង្កើតហ៊ីប៉ូតែកឱ្យលោក B ដែលជាម្ចាស់បំណុល លោក A បានយកដីនោះទៅបង្កើតសិទ្ធិជួលអចិន្ត្រៃយ៍ឱ្យលោក គ ដែលជាតតិយជន។ ក្នុងករណីនេះប្រសិនបើលោក គ បានធ្វើការចុះបញ្ជីដែលជាលក្ខខណ្ឌតតាំង ដូច្នេះ លោក គ ដែលជាតតិយជនក្រៅពីកម្មសិទ្ធិករនៃដី អាចតតាំងសិទ្ធិរបស់ខ្លួនចំពោះម្ចាស់បំណុលហ៊ីប៉ូតែកបានយ៉ាងពេញលេញដោយផ្អែកលើសិទ្ធិដែលនាំឱ្យមានមូលហេតុគតិយុត្ត ដូចជា សិទ្ធិជួលអចិន្ត្រៃយ៍ និងផលុបភោគ។ ដូចនេះ ហ៊ីប៉ូតែកមិនមានអានុភាពលើអាគារនោះឡើយ។ ( **ករណីអាគារត្រូវបានសាងសង់ក្រោយពេលបង្កើតហ៊ីប៉ូតែក** )។

### ១.១. លើអាគារដែលភ្ជាប់ទៅនឹងដី

នៅពេលដែលហ៊ីប៉ូតែកមួយត្រូវបានបង្កើតឡើងនៅលើដីមួយកន្លែង ហ៊ីប៉ូតែកនោះនិងមានអានុភាពទៅលើវត្ថុដែលភ្ជាប់នឹងដីនោះរួមទាំងអាគារ។ ទោះបីជាអាគារនោះត្រូវបានសង់នៅមុន

[23] មាត្រា ៨៤៦ ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

ពេល ឬក្រោយពេលបង្កើតហ៊ីប៉ូតែកក៏ដោយក៏កិច្ចសន្យាបង្កើតហ៊ីប៉ូតែមានអានុភាពលើដែរ។ យោងតាមមាត្រា ១២២ នៃក្រមរដ្ឋប្បវេណី បានចែងថា វត្ថុដែលនៅជាប់នឹងដី ឬវត្ថុដែលក្លាយជាភាគមួយនៃដី ជាពិសេសអាគារ ឬសំណង់នៅលើដី ហើយមិនអាចប្តូរកន្លែងបាន ព្រោះវាជាសមាសភាពនៃដីពោលគឺថាភាគនៃវត្ថុដែលរួមចូលជាវត្ថុតែមួយមិនអាចបំបែកបានទេ[24]។

## ១.២. អានុភាពលើផល

យោងតាមមាត្រា ៨៤៦ (ទំហំនៃអានុភាពហ៊ីប៉ូតែក) ខាងលើមិនត្រូវយកមកអនុវត្តចំពោះផលបានឡើយ[25]។ ប៉ុន្តែបញ្ញត្តិនៃវាក្យខណ្ឌទី១ នេះមិនត្រូវយកមកអនុវត្តឡើយនៅក្រោយពេលដែលអចលនវត្ថុហ៊ីប៉ូតែកនោះត្រូវបានរឹបអូស។ សិទ្ធិហ៊ីប៉ូតែក នៅលើអលចនវត្ថុមួយកន្លែងមិនមានអានុភាពទៅលើផលដែលកើតចេញពីរអចលនវត្ថុនោះទេ មិនថាផលស៊ីវិល ឬផលធម្មជាតិឡើយ។ ដោយសារតែហ៊ីប៉ូតែកត្រូវបានបង្កើតជាការធានាទៅនឹងតម្លៃនៃសិទ្ធិលើបំណុលមួយ ប៉ុន្តែអ្នកបង្កើតហ៊ីប៉ូតែកនៅលើអលចនវត្ថុមួយ គឺនៅមានសិទ្ធិប្រើប្រាស់ និងអាស្រ័យផលលើអលចនវត្ថុនោះដែរ។

## ១.៣. អានុភាពលើអាគារដែលជាកម្មសិទ្ធិរបស់តតិយជន

ក្នុងករណីដែលតតិយជនមានកម្មសិទ្ធិលើអាគារនៅលើអចលនវត្ថុ ដែលបានដាក់ហ៊ីប៉ូតែកដោយផ្អែកលើសិទ្ធិជួលអចិន្ត្រៃយ៍ ផលុបភាព ឬសិទ្ធិជួល ហ៊ីប៉ូតែកនោះពុំមានអានុភាពលើអាគារនោះឡើយ។ ករណីលើកលែង ចំពោះអាគារ ឬសំណង់ផ្សេងទៀតដែលម្ចាស់កម្មសិទ្ធិបានសង់លើដី ឬរុក្ខជាតិ ឬដំណាំដែលម្ចាស់សិទ្ធិបានដាំ ដែលជាការអនុវត្តសិទ្ធិចំពាះដីរបស់អ្នកដទៃមិនត្រូវក្លាយជាសមាសភាពនៃដីឡើយ[26]។ ដូចនេះ អានុភាពរបស់ហ៊ីប៉ូតែកគឺមិនគ្របដណ្តប់ទៅលើអាគារដែលជាកម្មសិទ្ធិរបស់តតិយជនដែលជាអ្នកជួលអចិន្ត្រៃយ៍ ផលុបភាគ ឬអ្នកជួលអាគារនោះទេ។

## កថាភាគទី២. ឧបាទេសកម្មលើវត្ថុ

យោងតាមសន្ទានុក្រម ពាក្យច្បាប់ផ្នែករដ្ឋប្បវេណីឆ្នាំ២០០៧ បានផ្តល់និយមន័យនៃពាក្យឧបាទេសកម្មថា គឺជា ឋានៈមួយដែលបុគ្គលម្នាក់ទទួលជំនួសបុគ្គលណាមួយតាមផ្លូវច្បាប់។ ដូច

[24] មាត្រា ១២២ ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

[25] មាត្រា ៨៤៦.១ ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

[26] មាត្រា ១២៣ ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។

បានលើកឡើងខាងលើរួមមកហើយថា ហ៊ីប៉ូតែក គឺជាសិទ្ធិដើម្បីប្តូរនឹងតម្លៃនៃកម្មវត្ថុជាក់លាក់ណាមួយ។ ដូច្នេះ ម្ចាស់សិទ្ធិហ៊ីប៉ូតែក អាចអនុវត្តនូវសិទ្ធិហ៊ីប៉ូតែករបស់ខ្លួនចំពោះប្រាក់ ឬវត្ថុផ្សេងទៀតដែលចេញមកអំពីមូលហេតុនៃការលក់ ការបាត់បង់ ការខូចខាត កម្មវត្ថុហ៊ីប៉ូតែកនោះ ពីព្រោះថាហេតុទាំងនោះត្រូវបានចាត់ទុកជាការទទួលស្គាល់ ឬបំផ្លែងនូវតម្លៃនៃអចលនវត្ថុដែលជាប់ហ៊ីប៉ូតែកនោះ។ ប៉ុន្តែម្ចាស់សិទ្ធិហ៊ីប៉ូតែកមិនអាចអនុវត្តហ៊ីប៉ូតែករបស់ខ្លួនបានឡើយ នៅក្រោយពេលដែលប្រាក់ត្រូវបានបង់ ឬវត្ថុផ្សេងទៀតត្រូវបានប្រគល់ទៅអាចអ្នកបង្កើត។ ហេតុផលដែលមានការចែងយ៉ាងដូច្នេះ ដោយសារតែហ៊ីប៉ូតែកត្រូវបានបង្កើតឡើង និងអាចអនុវត្តបានតែចំពោះកម្មវត្ថុណាមួយជាក់លាក់តែប៉ុណ្ណោះ ប៉ុន្តែនៅក្រោយពេលដែលតម្លៃដែលបានបំផ្លែង ឬកើតចេញពីរការលក់ ឬបាត់បង់វត្ថុជាក់លាក់នោះត្រូវបានប្រគល់ទៅឱ្យអ្នកបង្កើតហ៊ីប៉ូតែកនោះហើយ ចាប់តាំងពីរពេលនោះមកវា មិនអាចបែងចែកទ្រព្យសម្បត្តិផ្សេងទៀតបានទេ។ ដូចនេះ បើសិនជាម្ចាស់បំណុលចង់អនុវត្តសិទ្ធិហ៊ីប៉ូតែកតាមរយៈឧបាទេសកម្មលើវត្ថុ ម្ចាស់បំណុលហ៊ីប៉ូតែកត្រូវអនុវត្តឧបាទេសកម្មលើហ៊ីប៉ូតែករបស់ខ្លួនឱ្យបានមុនការប្រគល់ប្រាក់ ឬវត្ថុដែលកើតចេញពីរមូលហេតុនៃការលក់ ការបាត់បង់ ឬការខូចខាតចំពោះកម្មវត្ថុនោះទៅឱ្យកូនបំណុលហ៊ីប៉ូតែក។

**ឧទាហរណ៍៖** លោក A បានបង្កើតសិទ្ធិហ៊ីប៉ូតែកនៅលើអាគារមួយកន្លែងរបស់ខ្លួនទៅឱ្យលោក B ដើម្បីធានាបំណុលរបស់ខ្លួនចំនួន ២០០០០ ដុល្លារ។ ប៉ុន្តែ លោក C បានធ្វើឱ្យអាគារនោះឆេះ។ ដូចនេះ លោក B ដែលជាម្ចាស់បំណុលហ៊ីប៉ូតែកអាចប្តឹងទាមទារប្រាក់ដែលជាថ្លៃសំណងខូចខាតអាគារពីរលោក C បានតាមរយៈឧបាទេសកម្មលើវត្ថុនៃម្ចាស់សិទ្ធិហ៊ីប៉ូតែកលើវត្ថុនោះ។ តែបើលោក C បានផ្តល់ប្រាក់សំណងខូចខាតនៃអាគារនោះទៅឱ្យលោក A រួចហើយ លោក B មិនអាចប្តឹងទាមទារប្រាក់ពីលោក A តាមរយៈឧបាទេសកម្មលើវត្ថុបានទៀតទេពីព្រោះថាប្រាក់ដែលជាសំណងថ្លៃខូចខាតអាគារដែលលោក A ទទួលបាននោះក្លាយទៅជាទ្រព្យទូទៅរបស់លោក A ហើយ។ តែលោក B នៅអាចទាមទារប្រាក់ជំពាក់ពីលោក A ជាម្ចាស់បំណុលធម្មតាបាន។

### កថាភាគទី៣. សិទ្ធិទាមទារសំណងរបស់អ្នកធានាដោយវត្ថុ

ប្រសិនបើអ្នកដែលបានបង្កើតហ៊ីប៉ូតែកដើម្បីធានាកាតព្វកិច្ចរបស់អ្នកដទៃ បានសងចំពោះកាតព្វកិច្ចនោះ ឬបានបាត់បង់នូវកម្មសិទ្ធិលើដីហ៊ីប៉ូតែកដោយសារការអនុវត្តហ៊ីប៉ូតែកនោះ អ្នកនោះត្រូវមានសិទ្ធិទាមទារសំណងពីកូនបំណុលដោយយោងទៅតាមបញ្ញត្តិស្តីពីការធានា (មាត្រា ៨៥០

នៃក្រមរដ្ឋប្បវេណី)[27]។ បញ្ញត្តិនេះ ឆ្លើយតបទៅនឹងមាត្រា៩១១ និងបញ្ញត្តិមាត្រាដែលទាក់ទងមួយចំនួនទៀតនៃក្រមរដ្ឋប្បវេណី[28]។

**ឧទាហរណ៍៖** X គឺជាកូនរបស់ម្ចាស់បំណុលដែលបានជំពាក់ប្រាក់គេចំនួន ១ 000 ដុល្លារ។ Y គឺជាម្ចាស់បំណុលហ៊ីប៉ូតែក ហើយ Z គឺជាអ្នកធានាដោយវត្ថុដែលបានធានាបំណុលចំនួន ១ 000 ដុល្លារ។ Y អនុវត្តហ៊ីប៉ូតែករបស់ខ្លួន ហើយបានទទួលនូវការសងគ្រប់ចំនួនហើយ Z បានបាត់បង់នូវកម្មសិទ្ធិរបស់ខ្លួន ( អ្នកផ្សេងទទួលកម្មសិទ្ធិនោះ )។ នៅក្នុងករណីនេះ Z ទទួលនូវសិទ្ធិទាមទារសំណងចំនួន ១ 000 ដុល្លារ ពី X ។

## ចំណុចខុសប្លែកគ្នារវាង អ្នកធានាដោយវត្ថុ និង អ្នកធានាធម្មតា

ភាពខុសប្លែកគ្នាដ៏សំខាន់រវាងសិទ្ធិ និង កាតព្វកិច្ចរបស់អ្នកធានាដោយវត្ថុ និងអ្នកធានាមានពីរ។ ទី១ គឺ អ្នកធានាមានករណីយកិច្ច រីឯអ្នកធានាដោយវត្ថុមិនមានករណីយកិច្ចទេ ហើយមួយទៀតគឺ អ្នកធានាទទួលខុសត្រូវចំពោះរាល់ចំនួនប្រាក់ធានា ចំណែកឯការទទួលខុសត្រូវរបស់អ្នកធានាដោយវត្ថុវិញ ត្រូវបានកម្រិតត្រឹមតែការបាត់បង់នូវវត្ថុដែលបានដាក់ធានាតែប៉ុណ្ណោះ សូមពិនិត្យមើលឧទាហរណ៍ដូចខាងក្រោមនេះ៖

លោក ក ជាម្ចាស់បំណុល ហើយលោក ខ ជាកូនបំណុល។ លោក គ មានអចលនវត្ថុមួយកន្លែងហើយបានយកអចលនវត្ថុនោះទៅដាក់ហ៊ីប៉ូតែកដើម្បីធានាបំណុលឱ្យលោក ខ ។ នៅក្នុងករណីនេះ គេហៅលោក គ ថាជាអ្នកធានាដោយវត្ថុ។ លោក គ មានឋានៈស្រដៀងគ្នានឹងអ្នកធានាដែរ តែខុសគ្នាត្រង់ថា លោក ក ដែលជាម្ចាស់បំណុលហ៊ីប៉ូតែក មានសិទ្ធិត្រឹមតែទាមទារឱ្យលោក ខ ដែលជាកូនបំណុលសងបំណុលមកខ្លួន មិនមែនទាមទារឱ្យលោក គ សងទេ។ បើលោក ខ សងបំណុលទៅលោក ក ហើយ លោក ក មិនអាចអនុវត្តសិទ្ធិហ៊ីប៉ូតែករបស់ខ្លួនបានទៀតទេ។ តែបើលោក ខ មិនអាចសងបំណុលទៅលោក ក បានទេ អចលនវត្ថុរបស់លោក គ នឹងត្រូវបានរឹបអូសដោយលោក ក។

[27] មាត្រា៨៥០ ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។

[28] មាត្រា៩១១ ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។

ចំណុចដែលខុសគ្នាពី កិច្ចធានា គឺនៅត្រង់ថា បើសិនជាលោក គ គឺជាអ្នកធានា លោក ក ដែលជាម្ចាស់បំណុល មានសិទ្ធិលើបំណុលចំពោះលោក ខ ផង និង លោក គ ផង មានន័យថា លោក ក មានសិទ្ធិទាមទារឱ្យលោក ខ សងក៏បាន លោក គ សងក៏បាន។

## កថាភាគទី៤. លំដាប់នៃហ៊ីប៉ូតែក

កូនបំណុលអាចបង្កើតហ៊ីប៉ូតែកលើទ្រព្យតែមួយទៅឱ្យម្ចាស់បំណុលច្រើនគ្នា ដែលនេះជាចំណុចមួយដែលមានប្រយោជន៍បំផុតនៅក្នុងចំណោមចំណុចជាច្រើនបើប្រៀបធៀបទៅនឹងការធានា។

យោងតាមមាត្រា ៨៥១ នៃក្រមរដ្ឋប្បវេណី បានចែងថាក្នុងករណីដែលបានបង្កើតហ៊ីប៉ូតែកនៅលើអចលនវត្ថុតែមួយដើម្បីធានាសិទ្ធិលើបំណុលច្រើន លំដាប់នៃហ៊ីប៉ូតែកនោះ ត្រូវអនុលោមតាមពេលវេលាដែលបានចុះបញ្ជី[29]។ ក្នុងការអនុវត្តហ៊ីប៉ូតែកចំពោះអចលវត្ថុនេះដែរ មានបញ្ញត្តិមួយចំនួនដែលមានចែងនៅក្នុងក្រមរដ្ឋប្បវេណី ដែលមានការពាក់ពន្ធ័យ៉ាងជិតស្និតទៅនឹងប្រធានបទនេះដែលនិងត្រូវលើកយកមកអធិប្បាយនៅពេលនេះទោះបីជាយើងកំពុងសិក្សាពីរច្បាប់សារធាតុក៏ដោយ។ នីតិវិធីនៃការអនុវត្តនេះដើម្បីដោះស្រាយនូវវិវាទរវាងហ៊ីប៉ូតែកច្រើន ឬ វិវាទនាមារវាងហ៊ីប៉ូតែកជាមួយនឹងម្ចាស់សិទ្ធិប្រត្យក្ស ឬសិទ្ធិប្រាតិភោគប្រតក្សផ្សេងទៀតនៅលើអចលនវត្ថុតែមួយដែលកម្មវត្ថុនៃអនុវត្តហ៊ីប៉ូតែកនោះ។ ចំនុចទាំងនេះនឹងត្រូវលើកយកមកបង្ហាញដូចខាងក្រោមនេះ

ជាគោលការណ៍ការអនុវត្តសិទ្ធិប្រាតិភោគប្រត្យក្ស គឺធ្វើឡើងតាមវិធីលក់ដោយបង្ខំដើម្បីទទួលសំណងជាអាទិភាពពីប្រាក់ដែលបានមកពីការលក់នេះ។ តើសិទ្ធិប្រាតិភោគប្រត្យក្សផ្សេងដទៃទៀតក្រៅពីសិទ្ធិប្រាតិភោគប្រត្យក្សដែលត្រូវបានអនុវត្តលើអចលនវត្ថុនោះ ដូចជាហ៊ីប៉ូតែក នឹងត្រូវរលត់ក្រោយការលក់ ឬយ៉ាងណា? យោងតាមមាត្រា៥៦០ កថាខណ្ឌទី១ និង ទី២ នៃក្រមរដ្ឋប្បវេណី សិទ្ធិប្រាតិភោគប្រត្យក្សលើអចលនវត្ថុ សិទ្ធិប្រត្យក្សប្រើប្រាស់និងអាស្រ័យផលលើអចលនវត្ថុ និងសិទ្ធិជួបអចលនវត្ថុដែលអាចតតាំងនឹងសិទ្ធិប្រាតិភោគរបស់ម្ចាស់បំណុលនៃការអនុវត្តត្រូវបានបន្តអត្ថិភាពក្រោយការរលត់ដោយបង្ខំដែលជាការអនុវត្តសិទ្ធិប្រាតិភោគ[30]។ ក្រៅពីសិទ្ធិដែលបានកំណត់ខាងលើនេះ សិទ្ធិលើអចលនវត្ថុត្រូវបានរលត់ ដោយការលក់។

[29] មាត្រា៨៥១ ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។

[30] មាត្រា៥៦០ ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។

តាមរយៈមាត្រានេះយើងបានឃើញថា បើពាក្យសុំឱ្យចាប់ផ្ដើមនីតិវិធីអនុវត្តសិទ្ធិប្រាតិភោគប្រត្យក្ស ត្រូវធ្វើឡើងដោយម្ចាស់បំណុល ដែលមានសិទ្ធិប្រាតិប្រត្យក្សណាមួយមុននោះ សិទ្ធិប្រត្យក្សផ្សេងៗទៀតរួមទាំងសិទ្ធិប្រាតិភោគប្រត្យក្សផងដែរ ដែលឋិតនៅក្នុងលំដាប់អាទិភាពខ្ពស់ជាងម្ចាស់សិទ្ធិប្រាតិភោគប្រត្យក្សដែលដាក់ពាក្យសុំអនុវត្តមុននោះ មិនរលត់ដោយនីតិវិធីអនុវត្តទេ (មាត្រា ៥១០ កថាខណ្ឌទី១) ផ្ទុយទៅវិញបើសិទ្ធិប្រត្យក្ស ឬ សិទ្ធិប្រាតិភោគប្រត្យក្សផ្សេងៗនោញមានលំដាប់អាទិភាពទាបជាងសិទ្ធិប្រាតិភោគប្រត្យក្សដែលដាក់ពាក្យអនុវត្តមុននោះ ពេលនោះសិទ្ធិប្រត្យក្ស ឬសិទ្ធិប្រាតិភោគប្រត្យក្សលើអចលនវត្ថុនោះត្រូវរលត់ដោយការអនុវត្ត (មាត្រា៥១០ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី)[31]។

**ឧទាហរណ៍:** លោក X លោក Y និងលោក Z សុទ្ធតែជាម្ចាស់បំណុលហ៊ីប៉ូតែកនៅលើដីមួយកន្លែង។ លោក X ជាម្ចាស់បំណុលហ៊ីប៉ូតែកលំដាប់ទី១។ លោក Y ជាម្ចាស់បំណុលហ៊ីប៉ូតែកលំដាប់ទី២។ លោក Z ជាម្ចាស់បំណុលហ៊ីប៉ូតែកលំដាប់ទី៣។ បើសិនជា លោក X ដាក់ពាក្យសុំអនុតវត្តហ៊ីប៉ូតែករបស់ខ្លួនមុន ពេលនោះលោក Y និងលោក Z អាចចូលរួមចែកចំណែកដែរ។ តែបើសិនជាលោក Y ឬលោក Z ដាក់ពាក្យសុំអនុវត្តមុននោះ ពេលនោះលោក X មិនអាចចូលរួមក្នុងការចែកចំណែកទេ។ ព្រោះសិទ្ធិហ៊ីប៉ូតែករបស់លោក X មិនរលតទេ។លោក X នៅតែអាចដាក់ពាក្យសុំអនុវត្តហ៊ីប៉ូតែករបស់ខ្លួនពីរតតិយជនដែលបានធ្វើលទ្ធកម្មលើដីនោះតាមរយៈការលក់ដោយបង្ខំដដែល ។

ដូច្នេះយោងតាមមាត្រា៨៤៩ កថាខណ្ឌទី១ បានចែងថាអ្នកទិញត្រូវទទួលខុសត្រូវសងនូវសិទ្ធិលើបំណុលដែលត្រូវបានធានាដោយសិទ្ធិប្រាតិភោគដែលអ្នកទិញបានទទួលបន្ត។ ហើយអ្វីដែលគួរឱ្យកត់សំគាល់នោះ គឺថាម្ចាស់សិទ្ធិហ៊ីប៉ូតែកដែលចិតក្នុងលំដាប់ទី១ អាចទទួលនូវការសងដោយមានអាទិភាពជាងម្ចាស់បំណុលហ៊ីប៉ូតែកដែលចិតក្នុងលំដាប់បន្ទាប់។ ជាទូទៅ ម្ចាស់បំណុលផ្សេងៗទៀតគឺមិនទទួលបានសូម្បីតែសំណង។

## កថាភាគទី៥. ទំហំនៃសិទ្ធិលើបំណុលដែលត្រូវបានធានា

ក្នុងករណីដែលម្ចាស់បំណុលហ៊ីប៉ូតែកមានសិទ្ធិទាមទារការប្រាក់ ឬធនលាភផ្សេងទៀត ម្ចាស់បំណុលហ៊ីប៉ូតែកអាចអនុវត្តហ៊ីប៉ូតែកនោះបានតែចំពោះចំនួននៃការសងដែលដល់កំណត់ពេលសម្រាប់អំឡុងពេល២(ពីរ) ឆ្នាំចុងក្រោយតែប៉ុណ្ណោះ[32]។ ប៉ុន្តែចំពោះធនលាភបានចាប់ពីពេល

---

[31] មាត្រា ៥១០ ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។

[32] មាត្រា ៨៥២ ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។

ដែលបានចុះបញ្ជីនោះ មាត្រា៨៥២ កថាខណ្ឌទី១ ក៏ត្រូវបានយកមកអនុវត្តដូចគ្នាផងដែរចំពោះប្រាប់ដែលត្រូវបង់សម្រាប់អំឡុងពេល២(ពីរ) ឆ្នាំចុងក្រោយ ក្នុងករណីដែលម្ចាស់បំណុលហ៊ីប៉ូតែកមានសិទ្ធិមានសិទ្ធិទាមទារឱ្យសងសំណងនៃការខូចខាត ដែលបានកើតឡើងដោយការមិនអនុវត្តកាតព្វកិច្ច[33]។ ប៉ុន្តែក្នុងករណីនេះចំនួនសរុបនៃសំណងការខូចខាតព្រមទាំងការប្រាក់ និងធនលាភផ្សេងទៀតមិនអាចលើសចំនួនសរុបសម្រាប់អំឡុងពេល២(ពីរ) ឆ្នាំបានឡើយ។

បានជាច្បាប់មានការកំណត់ដូច្នេះ ពីរព្រោះវាមានភាពចាំបាច់សំរាប់ការពារម្ចាស់បំណុលហ៊ីប៉ូតែកដទៃផ្សេងទៀតដែលស្ថិតនៅក្នុងលំដាប់ទាបជាងដើម្បីឱ្យដឹងថាតើតម្លៃនៃអចលនវត្ថុដែលត្រូវបានយកមកដាក់ជាប្រាតិភោគនោះមានចំនួនប៉ុន្មាន។

**ឧទាហរណ៍៖** លោក A បានយកដីរបស់ខ្លួនមួយកន្លែងដែលមានតម្លៃចំនួន 2000 ដុល្លារទៅដាក់ហ៊ីប៉ូតែកឱ្យលោក B ដើម្បីធានាបំណុលចំនួន 1000 ដុល្លារ នៅថ្ងៃទី០៦ ខែ ០៧ ឆ្នាំ ២០០៦ ដោយយកការប្រាក់១០ភាគរយក្នុងមួយឆ្នាំ។ ការប្រាក់នៃការយឺតយ៉ាវគឺ ២០ភាគរយ។ កាលបរិច្ឆេទដែលត្រូវសងនៅថ្ងៃទី០៦ ខែ០៧ ឆ្នាំ២០១១។ លោក A ចង់ខ្ចីប្រាក់ពីរលោក C បន្ថែមទៀត។ ឧទាហរណ៍ថ្ងៃនេះ គឺជាថ្ងៃទី០៦ ខែ០៧ ឆ្នាំ២០១៥ ដូច្នេះរយៈពេល២ឆ្នាំ ចុងក្រោយដែលត្រូវយកមកគណនាគឺនៅឆ្នាំ២០១៣។ ហេតុដូច្នេះ B អាចទទួលបានប្រាប់ចំនួនច្រើនបំផុត 1400 ដុល្លារពីរហ៊ីប៉ូតែក ដូចនេះ C ត្រូវឱ្យខ្ចីច្រើនបំផុតនោះចំនួន 600 ដុល្លារ(ករណីប្រសិនបើ C គិតការប្រាក់ C ត្រូវឱ្យខ្ចីតិចជាងចំនួន 600 ដុល្លារ។

[33] មាត្រា៨៥២.១ ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

# ជំពូកទី២

# ការអនុវត្ត ការចាត់ចែង
# និងការរលត់
# នៃហ៊ីប៉ូតែកចម្លា

# ជំពូកទី២

# ការអនុវត្ត ការចាត់ចែង និងការរលត់ នៃហ៊ីប៉ូតែកធម្មតា

ជាទូទៅ ដើម្បីអាចអនុវត្ត ធ្វើការចាត់ចែង និងធ្វើឱ្យហ៊ីប៉ូតែករលត់បាន យើងត្រូវយល់ដឹងឱ្យបានលម្អិតអំពី របបគតិយុត្តនៃការបង្កើតហ៊ីប៉ូតែកជាមុនសិនដែលមានបកស្រាយនៅក្នុងជំពូកទី១ ជាមុនសិន ដើម្បីបង្ការហានិភ័យដែលអាចកើតមានចំពោះម្ចាស់បំណុលហ៊ីប៉ូតែក។ ដោយហេតុថា ហ៊ីប៉ូតែក មិនបានកម្រិតអំពីលក្ខខណ្ឌទម្រង់ក្នុងការបង្កើតកិច្ចសន្យាហ៊ីប៉ូតែករបស់គូភាគីនោះទេ គឺបានន័យថា កិច្ចសន្យាហ៊ីប៉ូតែកមាន សុពលភាពត្រឹមតែការព្រមព្រៀង ដែលការព្រមព្រៀងអាចត្រូវបានធ្វើឡើង តាមទម្រង់ផ្ទាល់មាត់ក៏បាន ឬតាមទម្រង់ជាលាយលក្ខណ៍អក្សរក៏បាន គឺកិច្ចសន្យាហ៊ីប៉ូតែកមានអានុភាពតែម្តង។ ដែលនេះជាបញ្ហា និងជាហានិភ័យដែលអាចកើតមានចំពោះម្ចាស់បំណុល ព្រោះប្រសិនបើកិច្ចសន្យាហ៊ីប៉ូតែក មិនបានតាក់តែងជា លិខិតយថាភូត និងធ្វើការចុះបញ្ជី ឱ្យបានត្រឹមត្រូវនោះទេ ម្ចាស់បំណុលហ៊ីប៉ូតែកមិនអាចយកសិទ្ធិហ៊ីប៉ូតែករបស់ខ្លួនទៅតតាំងជាមួយ កូនបំណុល ឬតតិយជន បានឡើយ។ ផ្ទុយមកវិញ ប្រសិនបើលក្ខខណ្ឌទម្រង់នៃកិច្ចសន្យាហ៊ីប៉ូតែកបានបង្កើតឡើង ម្ចាស់បំណុលអាចអនុវត្តសិទ្ធិរបស់ខ្លួនបានយ៉ាងពេញលេញ។ ហេតុដូចនេះនៅក្នុងជំពូកទី២នេះ យើងនឹងធ្វើការសិក្សាអំពី សិទ្ធិរបស់ម្ចាស់បំណុលហ៊ីប៉ូតែក ក្នុងការអនុវត្តចាត់ចែង និងការរលត់នៃហ៊ីប៉ូតែក។

## ផ្នែកទី១. យន្តការនៃការអនុវត្តសិទ្ធិហ៊ីប៉ូតែក

យោងតាមបញ្ញត្តិដែលកំណត់នៅក្នុងក្រមរដ្ឋប្បវេណី ការអនុវត្តហ៊ីប៉ូតែក គឺជាការទាមទាររបស់ម្ចាស់បំណុលហ៊ីប៉ូតែក[34] បានន័យថា ប្រសិនបើកូនបំណុលហ៊ីប៉ូតែកមិនអនុវត្តកាតព្វកិច្ចរបស់ខ្លួនទេ ម្ចាស់បំណុលហ៊ីប៉ូតែកអាចអនុវត្តហ៊ីប៉ូតែករបស់ខ្លួនតាមរយៈការដាក់ពាក្យសុំឱ្យលក់ដោយបង្ខំនូវវត្ថុដែលជាកម្មវត្ថុនៃហ៊ីប៉ូតែក បានតាមរយៈផ្លូវតុលាការ។ ផ្ទុយមកវិញ ម្ចាស់បំណុលហ៊ីប៉ូតែកមិនអាចអនុវត្តសិទ្ធិហ៊ីប៉ូតែករបស់ខ្លួនបានឡើយ ក្នុងករណីប្រសិនបើកាតព្វកិច្ចត្រូវបានអនុវត្ត[35]។ ការអនុវត្តហ៊ីប៉ូតែក គឺជាការអនុវត្តដោយភាគីម្ចាស់បំណុលតាមរយៈការដាក់ពាក្យសុំដូចបានបញ្ជាក់ខាងលើ ហើយមិនចាំបាច់ឆ្លងកាត់នីតិវិធីបណ្តឹង គឺបានន័យថា ភាគីម្ចាស់បំណុល

[34] មាត្រា ៨៥៣ ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

[35] មាត្រា ៨៥៣ ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

អាចដាក់ពាក្យសុំទៅស្ថាប័នអនុវត្ត (តុលាការអនុវត្ត)[36]។ ការអនុវត្តហ៊ីប៉ូតែកចំពោះ អចលនវត្ថុ គឺជាការអនុវត្តសិទ្ធិប្រាតិភោគដែលជាការអនុវត្តដោយបង្ខំមួយប្រភេទ ដែលជាគោលការណ៍ត្រូវអនុលោម ទៅតាមបញ្ញត្តិស្ដីពីការអនុវត្តដោយបង្ខំដែលមានគោលបំណងឱ្យសងជាប្រាក់ចំពោះអចលនវត្ថុ ដោយបន្ថែមនូវបញ្ញត្តិ ពិសេសដែលមានចែងនៅក្នុងមាត្រា ៥០៩ ដល់មាត្រា ៥២០ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

<u>**ឧទាហរណ៍៖**</u>

លោក **ខ** គឺជាម្ចាស់បំណុលហ៊ីប៉ូតែកចំនួន ២ ០០០ ដុល្លារ នៅលើដី A មួយកន្លែងរបស់លោក **ក** ។ បើដល់ពេលកំណត់ត្រូវសង លោក **ក** មិនមានប្រាក់សងទេនោះ លោក **ខ** អាចដាក់ពាក្យសុំឱ្យលក់ដោយបង្ខំ។ សន្មត់ថា អចលនវត្ថុ A នោះលក់បានតម្លៃ ២ ៦០០ ដុល្លារ ។ ដូចនេះ ថ្លៃដែលលក់បានចំនួន ២ ០០០ ដុល្លារ ត្រូវយកទៅសងម្ចាស់បំណុលដែលជាលោក **ខ** ។ តែបើដីនៅនោះលក់បានតែ ១ ៦០០ ដុល្លារ នោះ លោក **ក** នៅជំពាក់លោក **ខ** ចំនួន ៤០០ ដុល្លារទៀត។ បំណុលដែលនៅសល់ចំនួន ៤០០ ដុល្លារនេះ លោក **ខ** នៅតែមានសិទ្ធិទាមទារពីលោក **ក** ដដែល តែមិនមែនទាមទារក្នុងនាមជាម្ចាស់បំណុលហ៊ីប៉ូតែកទៀតទេ ព្រោះសិទ្ធិហ៊ីប៉ូតែករបស់លោក **ខ** ត្រូវបានរលត់ដោយការលក់អចលនវត្ថុហ៊ីប៉ូតែកនោះទៅតាមនីតិវិធីអនុវត្តដោយបង្ខំរបស់តុលាការហើយ។ ដូចនេះ សិទ្ធិទាមទារបំណុលដែលនៅសល់របស់លោក ខ គឺជាសិទ្ធិទាមទារបំណុលធម្មតា។

តាមរយៈឧទាហរណ៍ខាងលើ លោក ខ អាចដាក់ពាក្យសុំឱ្យលក់ដោយបង្ខំនូវដីមួយកន្លែងនោះ ដែលជាអលចនវត្ថុហ៊ីប៉ូតែក ចំណោទបញ្ហាសួរថា តើលោក ខ ត្រូវដាក់ពាក្យសុំនេះតាមរបៀបណា? ហើយនីតិវិធីនៃការអនុវត្តដោយបង្ខំនេះមានប៉ុន្មានដំណាក់កាល?

## កថាភាគទី១. ការលក់ដោយបង្ខំនូវអចលនវត្ថុ

### ១.១. ការរឹបអូស

នៅពេលដែលកូនបំណុលមិនអាចអនុវត្តកាតព្វកិច្ចរបស់ខ្លួនដល់ពេលកំណត់ដែលត្រូវសង។ ដំណាក់កាលដំបូង គឺជាការរឹបអូសនូវអចលនវត្ថុដែលជាកម្មវត្ថុនៃហ៊ីប៉ូតែក ហើយតុលារការដែលមានសមត្ថកិច្ចចំពោះករណីនេះ គឺតុលាការអនុវត្តដែលជាសាលាដំបូងនៃទីតាំង

[36] មាត្រា ៤១៨ ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦។

អចលនវត្ថុនោះស្ថិតនៅ[37] ដោយនីតិវិធីត្រូវធ្វើឡើងតាមរយៈពាក្យសុំឱ្យអនុវត្តសិទ្ធិប្រាតិភោគចំពោះអចលនវត្ថុ[38] ដោយត្រូវបំពេញនូវចំណុចចាំបាច់មួយចំនួន[39]ដូចជា៖

ក- សញ្ញាណម្ចាស់បំណុលនៃការអនុវត្ត សញ្ញាណកូនបំណុលនៃការអនុវត្ត កូនបំណុលនៃសិទ្ធិលើបំណុលដែលត្រូវបានធានា និងអ្នកតំណាង

ខ- សញ្ញាណនៃសិទ្ធិប្រាតិភោគ និងសិទ្ធិលើបំណុលដែលត្រូវបានធានា

គ- សញ្ញាណនៃសិទ្ធិអចលនវត្ថុដែលជាកម្មវត្ថុនៃហ៊ីប៉ូតែក

ឃ- ហេតុការណ៍ និងទំហំនៃសិទ្ធិលើបំណុលដែលត្រូវបានធានា

ពាក្យសុំនេះក្រៅពីឯកសារចម្លងយថាភូតនៃលិខិតអនុវត្តដែលមានកំណត់នៅក្នុងមាត្រា ៤៩៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី ម្ចាស់បំណុលនៃការអនុវត្ត ត្រូវភ្ជាប់មកជាមួយនឹងពាក្យសុំនូវឯកសារចម្លងដែលមានសេចក្តីបញ្ជាក់នៃសៀវភៅចុះបញ្ជី[40]។

ការអនុវត្តហ៊ីប៉ូតែកចំពោះអចលនវត្ថុ ត្រូវចាប់ផ្តើមដោយតុលាការអនុវត្ត ចេញដីការសម្រេចចាប់ផ្តើមលក់ដោយបង្ខំ ប្រកាសរឹបអូសអចលនវត្ថុតាមពាក្យសុំរបស់ម្ចាស់អចលនវត្ថុនៃការអនុវត្តដែលជាម្ចាស់បំណុលហ៊ីប៉ូតែក[41] ដោយអានុភាពនៃការរឹបអូសនឹងកើតឡើងនៅពេលដែលដីការសម្រេចចាប់ផ្តើមការលក់ដោយបង្ខំត្រូវបានបញ្ជូនទៅកូនបំណុលនៃការអនុវត្ត ប៉ុន្តែការចុះបញ្ជីអំពីការរឹបអូសនឹង មានអានុភាព នៅពេលដែលបានចុះបញ្ជី[42] ។

## ១.២ ការលក់

បន្ទាប់ពីរឹបអូស គឺដំណាក់កាលប្តូរជាសាច់ប្រាក់ តាមនីតិវិធីលក់ដោយបង្ខំ និងសងទៅម្ចាស់បំណុលតាមវិធីចែកចំណែក ហេតុនេះ នីតិវិធីអនុវត្តដោយបង្ខំមានគោលបំណងឱ្យសងជាប្រាក់ចំពោះអចលនវត្ថុត្រូវយកមកអនុវត្តដូចជា៖

ការចេញដីការសម្រេចចាត់តាំងអ្នកវាយតម្លៃ ដីកាបង្គាប់ឱ្យវាយតម្លៃអចលនវត្ថុ[43] ដីកាសម្រេច

---

[37] មាត្រា ៤១៨ ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦។
[38] មាត្រា ៣៤៩.១ ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦។
[39] មាត្រា ៥០៩.១ ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦។
[40] មាត្រា ៥០៩.២ ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦។
[41] មាត្រា ៤១៩.១ ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦។
[42] មាត្រា ៤២១.២ ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦។
[43] មាត្រា ៤៣០.១ ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦។

បង្គាប់ឱ្យស្រាវជ្រាវស្ថានភាពបច្ចុប្បន្ននៃវត្ថុ ការធ្វើឯកសារលម្អិតអំពីវត្ថុ ការកំណត់តម្លៃអប្បរមា[44] ការកំណត់ពេលវេលាចុងក្រោយសម្រាប់ការចែកចំណែក ដីការសម្រេចបង្គាប់ឱ្យអនុវត្តការលក់[45] ការផ្សាយជាសាធារណៈអំពីកាលបរិច្ឆេទនៃការលក់ កាលបរិច្ឆេទនៃការលក់ឡាយឡុង កាលបរិច្ឆេទដើម្បីចេញដីការសម្រេចអនុញ្ញាតឱ្យលក់ ការចេញដីកាសម្រេចអនុញ្ញាតឱ្យលក់ និងការកំណត់អំឡុងពេលបង់ថ្លៃលក់ ជាអាទិ៍។

## ១.៣ ការចែកចំណែក

នៅពេលដែលនីតិវិធីនៃការលក់ត្រូវបានបញ្ចប់ តាមរយៈការចេញដីកាសម្រេចអនុញ្ញាតឱ្យលក់ ហើយដីកានេះបានចូលជាស្ថាពរ តុលាការអនុវត្តត្រូវបន្តនីតិវិធីតាមរយៈការចែកចំណែក[46] ដោយកំណត់កាលបរិច្ឆេទចែកចំណែក និងជូនដំណឹងអំពីកាលបរិច្ឆេទនោះ បន្ទាប់កោះហៅម្ចាស់បំណុល និងកំណត់កាលបរិច្ឆេទចែកចំណែក និងធ្វើតារាងបែងចែកចំណែក[47] ហើយអនុវត្តការចែកចំណែកនោះ[48]។

ក្នុងករណីដែលអចលនវត្ថុដែលជាប់ហ៊ីប៉ូតែកនោះត្រូវបានលក់ ដោយការអនុវត្តហ៊ីប៉ូតែក អ្នកទិញនឹងធ្វើនូវលទ្ធកម្មកម្មសិទ្ធិពេញលេញ ហើយអ្នកបង្កើតហ៊ីប៉ូតែកនឹងត្រូវបាត់បង់កម្មសិទ្ធិលើអលចនវត្ថុដែលជាកម្មវត្ថុនៃហ៊ីប៉ូតែកនេះដែរ។ សិទ្ធិប្រើប្រាស់ និងអាស្រ័យផលលើអចលនវត្ថុ របស់អ្នកបង្កើតហ៊ីប៉ូតែកនោះក៏ត្រូវរលត់ដែរ។ ហេតុដូច្នេះ ហើយបានជាមាត្រា ៨៤៨ និងមាត្រា ៨៤៩ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីចែងថា ហ៊ីប៉ូតែកនឹងមានអានុភាពចំពោះផលតែនៅពេលដែលអចលនវត្ថុជាប់ហ៊ីប៉ូតែកនោះត្រូវបានរឹបអូសហើយ ម្ចាស់បំណុលហ៊ីប៉ូតែកអាចរឹបអូសផលនោះបាន។

---

44 មាត្រា ៤៣២.១ ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦។

45 មាត្រា ៤៣៦.៣ ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦។

46 មាត្រា ៤៨៨.១ ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦។

47 មាត្រា ៤៩០.១.២ ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦។

48 មាត្រា ៤៨៩ ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦។

## កថាភាគទី២. ភាគីដែលអាចក្លាយជាអ្នកទិញនៅពេលអនុវត្ត

### ២.១. ម្ចាស់បំណុលហ៊ីប៉ូតែក ឬអ្នកធានាដោយវត្ថុ

បើទោះបីជាម្ចាស់បំណុលហ៊ីប៉ូតែក ជាអ្នកមានសិទ្ធិហ៊ីប៉ូតែកលើដីដែលជាកម្មវត្ថុនៃហ៊ីប៉ូតែក ហើយអ្នកធានាដោយវត្ថុ ជាអ្នកធានាកាតព្វកិច្ចឱ្យកូនបំណុល ក៏ពិតមែន ប៉ុន្តែគាត់នៅតែអាចមានសិទ្ធិក្នុងការទិញអចលនវត្ថុដែលដាក់ហ៊ីប៉ូតែកនោះបានផងដែរ ពីព្រោះពុំមានបទប្បញ្ញត្តិណាមួយដែលហាមឃាត់ម្ចាស់បំណុល ឬអ្នកធានាដោយវត្ថុ មិនឱ្យធ្វើការទិញអចលនវត្ថុដែលជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំនោះបានទេ។ បន្ថែមពីនេះទៅទៀត ប្រសិនបើតម្លៃ ដែលបានមកពីការលក់អចលនវត្ថុនោះ មិនគ្រប់គ្រាន់សម្រាប់សោហ៊ុយនីតិវិធីនៃការអនុវត្តទេ នីតិវិធីបែបនេះ ត្រូវបានចាត់ទុកថា មិនត្រឹមត្រូវ និងគ្មានប្រយោជន៍។ ហេតុដូច្នេះ មាត្រា ៤៣៥ តម្រូវឱ្យម្ចាស់បំណុលនៃការអនុវត្តធ្វើសំណើថា ខ្លួននឹងទិញអចលនវត្ថុក្នុងតម្លៃស្មើសុំក្នុងអំឡុងពេល មួយសប្តាហ៍ ក្រោយពេលជូនដំណឹងទៅម្ចាស់បំណុលនៃការអនុវត្ត ក្នុងករណីដែលគ្មានលទ្ធភាពសល់ទេនោះ ក្រោយពីបានសងសោហ៊ុយសម្រាប់នីតិវិធីហើយ។ ក្នុងករណីដែលម្ចាស់បំណុលនៃការអនុវត្ត មិនបានធ្វើសកម្មភាពដូច្នោះទេ តុលាការត្រូវលុបចោលពាក្យសុំការអនុវត្តនោះ។ ដូចនេះមុននឹងអនុវត្តហ៊ីប៉ូតែក តុលាការអនុវត្តត្រូវជ្រើសរើសអ្នកវាយតម្លៃ និងបង្គាប់ឱ្យវាយតម្លៃអចលនវត្ថុ ដោយផ្អែកលើការស្រាវជ្រាវអំពីសណ្ឋាននៃអលចនវត្ថុ ទំនាក់ទំនងនៃការកាន់កាប់ និងស្ថានភាពបច្ចុប្បន្នឯទៀត[49]។

### ២.២. កូនបំណុលហ៊ីប៉ូតែក

កូនបំណុលមិនអាចក្លាយជាអ្នកទិញអចលនវត្ថុដែលខ្លួនបានដាក់ហ៊ីប៉ូតែកនោះបានទេ ពីព្រោះថាបើកូនបំណុលមានលុយដល់ទៅទិញអចលនវត្ថុដែលជាប់ហ៊ីប៉ូតែកនោះ គាត់គួរតែសងបំណុលទៅម្ចាស់បំណុលវិញ ហើយវាប្រសើរជាងការខាតបង់ពេលវេលា និងសោហ៊ុយចំណាយទៅលើការអនុវត្តហ៊ីប៉ូតែកនោះ[50]។

[49] សេចក្តីកំណត់ចំពោះមាត្រានីមួយៗ ឆ្នាំ២០១០ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

[50] សេចក្តីកំណត់ចំពោះមាត្រានីមួយៗ ឆ្នាំ២០១០ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

## ២.៣. តតិយជនដែលបានធ្វើលទ្ធកម្ម

តតិយជនដែលបានធ្វើលទ្ធកម្មនូវអចលនវត្ថុហ៊ីប៉ូតែក អាចក្លាយជាអ្នកទិញក្នុងការលក់ដោយបង្ខំបាន[51]។ ជាធម្មតា កម្មសិទ្ធិករនៃវត្ថុណាមួយ មិនអាចក្លាយជាអ្នកទិញវត្ថុនោះបានឡើយ។ ប៉ុន្តែ ក្នុងករណីនៃការលក់ដោយបង្ខំ សិទ្ធិរបស់តតិយជនដែលបានធ្វើលទ្ធកម្ម ដែលមិនអាចតតាំងចំពោះម្ចាស់បំណុលហ៊ីប៉ូតែក ត្រូវរលត់ ដូច្នេះ តតិយជនដែលបានធ្វើលទ្ធកម្ម មានផលប្រយោជន៍ក្នុងការទិញវត្ថុនោះ ហើយធ្វើលទ្ធកម្មកម្មសិទ្ធិ តាមស្ថានភាពមុនការបង្កើតហ៊ីប៉ូតែក[52]។ បន្ថែមពីនេះ តតិយជនដែលទិញកម្មសិទ្ធិ សិទ្ធិជួលអចិន្ត្រៃយ៍ ឬផលុបភោគ ចំពោះអចលនវត្ថុហ៊ីប៉ូតែក បានសងថ្លៃលក់នោះទៅម្ចាស់បំណុលហ៊ីប៉ូតែក តាមការទាមទាររបស់ម្ចាស់បំណុលហ៊ីប៉ូតែកហើយ ហ៊ីប៉ូតែកត្រូវរលត់សម្រាប់តតិយជននោះ។ ហ៊ីប៉ូតែកមិនត្រូវរលត់ដោយអាជ្ញាយុកាលចំពោះកូនបំណុល និងអ្នកដែលបានបង្កើតហ៊ីប៉ូតែកឡើយ ប្រសិនបើសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែកនោះមិនរលត់ព្រមគ្នាទេ។ ពេលដែលបុគ្គលក្រៅពីកូនបំណុល ឬក្រៅពីអ្នកដែលបានបង្កើតហ៊ីប៉ូតែក បានកាន់កាប់អចលនវត្ថុហ៊ីប៉ូតែក ដោយមានលក្ខខណ្ឌចាំបាច់សម្រាប់អាជ្ញាយុកាលនៃការទទួលសិទ្ធិហ៊ីប៉ូតែកនោះត្រូវរលត់។ ប៉ុន្តែបញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយចំពោះករណីដែលតតិយជនដែលបានធ្វើលទ្ធកម្មនូវអចលនវត្ថុ ហ៊ីប៉ូតែកនោះ បានដឹងនៅពេលដែលខ្លួនបានធ្វើលទ្ធកម្មថា ហ៊ីប៉ូតែកត្រូវបានបង្កើតលើអចលនវត្ថុនោះ[53]។

<u>ឧទាហរណ៍៖</u> លោក ក ជាតតិយជនដែលបានធ្វើលទ្ធកម្មកម្មសិទ្ធិលើដីមួយកន្លែងរបស់លោក ខ ។ ក្រោយមក ទើបដឹងថាលោក គ ជាម្ចាស់បំណុលហ៊ីប៉ូតែកលើដីនោះ។ ជាគោលការណ៍ លោក ក មិនអាចតតាំងជាមួយម្ចាស់បំណុល ( លោក គ ) បាននោះទេ។ ប៉ុន្តែនៅពេលដែលម្ចាស់បំណុលហ៊ីប៉ូតែក ( លោក គ ) ធ្វើការអនុវត្តដោយបង្ខំនូវដីដែលជាកម្មវត្ថុនៃហ៊ីប៉ូតែក លោក ក ក៏នូវតែមានសិទ្ធិឡើងវិញក្នុងការទិញនូវអចលនវត្ថុនៃការលក់ដោយបង្ខំនោះ។

---

[51] មាត្រា ៨៥៥ ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

[52] មាត្រា៨៥៥ សេចក្តីកំណត់ចំពោះមាត្រានីមួយៗ ភាគទី៤ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

[53] ដកស្រង់ចេញពីគេហទំព័រ CONSTRUCTION PROPERTY ផ្នែកព័ត៌មានអចលនទ្រព្យ https://construction-property.com/km/hypotec-in-cambodia-under-the-civil-code/។

## កថាភាគទី៣. ការលក់ដោយបង្ខំនូវអាគារដែលជាកម្មសិទ្ធិរបស់តតិយជន

ជាទូទៅនៅពេលដែលកូនបំណុលមិនបំពេញកាតព្វកិច្ច ម្ចាស់បំណុលអាចដាក់ពាក្យសុំឱ្យលក់ដោយបង្ខំ។ និយាយម្យ៉ាងទៀតថា ម្ចាស់បំណុលត្រូវប្រើប្រាស់វិធីសាស្ត្រនេះ ដើម្បីទទួលបាននូវការសងកាតព្វកិច្ចរបស់ខ្លួន ។ ដូចគ្នានេះដែរ នៅក្នុងកិច្ចសន្យាបង្កើតហ៊ីប៉ូតែក បើកាតព្វកិច្ចពុំត្រូវបានអនុវត្តន៍ ម្ចាស់បំណុលហ៊ីប៉ូតែកអាចដាក់ពាក្យសុំឱ្យលក់ដោយបង្ខំនូវអចលនវត្ថុទៅតុលាការ។ ប៉ុន្តែដោយសារកម្មវត្ថុនៃហ៊ីប៉ូតែក មានអានុភាពរហូតដល់ក្រោយពេលបង្កើតហ៊ីប៉ូតែកផងដែរនោះ ការលក់ដោយបង្ខំនូវអចលនវត្ថុដែលជាកម្មវត្ថុនៃហ៊ីប៉ូតែកអាចប៉ះពាល់ដល់កម្មសិទ្ធិរបស់តតិយជនដែលបានសង់អាគារលើអចលនវត្ថុនោះបាន[54]។ ដោយសារហេតុនេះហើយទើបមានចំណោទបញ្ហាកើតឡើង ក្នុងករណីដែលអ្នកបង្កើតហ៊ីប៉ូតែក ឬតតិយជនបានសាងសង់អាគារពីលើដីហ៊ីប៉ូតែកនោះ តើម្ចាស់បំណុលអាចធ្វើការលក់ដោយបង្ខំ នូវដីដែលមានអាគារពីលើនោះបានដែរឬទេ ក្នុងករណីបើអាគារត្រូវបានសាងសង់មុន ឬ ក្រោយនៅលើដីហ៊ីប៉ូតែកនោះ ?

### ៣.១. ករណីមិនអាចលក់ដោយបង្ខំបាន

បើទោះបីជាម្ចាស់បំណុលមានអាទិភាពក្នុងការទទួលបាននូវសំណងតាមរយៈការលក់ដោយបង្ខំក៏ពិតមែន ប៉ុន្តែការលក់ដោយបង្ខំនោះក៏ត្រូវពិនិត្យមើលជាមុនផងដែរនូវលទ្ធភាពដែលអាចទៅរួច។ ហើយប្រសិនបើតតិយជន បានធ្វើការចុះបញ្ជីដែលជាលក្ខខណ្ឌតតាំង ក្នុងករណីនេះតតិយជន ក្រៅពីកម្មសិទ្ធិករនៃដី អាចតតាំងសិទ្ធិរបស់ខ្លួនចំពោះម្ចាស់បំណុលហ៊ីប៉ូតែកបានយ៉ាងពេញលេញ ដោយផ្អែកលើសិទ្ធិដែលនាំឱ្យមានមូលហេតុគតិយុត្ត ដូចជាសិទ្ធិជួលអចិន្ត្រៃយ៍ ផលុបភោគ ហ៊ីប៉ូតែកមិនត្រូវមានអានុភាពលើអាគារនោះឡើយ[55]។ តតិយជនមុននឹងធ្វើការតតាំងជាមួយម្ចាស់បំណុល តតិយជនត្រូវយកសិទ្ធិស្របច្បាប់របស់ខ្លួនមកអះអាងផងដែរ ដែលមានដូចជា សិទ្ធិជួលអចិន្ត្រៃយ៍ ផលុបភោគ ឬ សិទ្ធិជួលរបស់ខ្លួនមកបង្ហាញ ទើបអាចធ្វើការតតាំងជាមួយម្ចាស់បំណុលបាន បើមិនដូច្នោះទេ តតិយជនពុំមានហេតុផលណាមួយអាចមកហាមឃាត់ចំពោះការរុះរើ ឬ ការដាក់លក់ដោយបង្ខំនូវអាគារ និងដីហ៊ីប៉ូតែកនោះបានឡើយ។ បន្ថែមពីនេះទៅទៀតម្ចាស់បំណុលមិនអាចធ្វើការលក់ដោយបង្ខំទាំងដី និងអាគារ បានឡើយ ដោយផ្អែកលើមាត្រា ១២៣ នៃក្រមរដ្ឋប្បវេណី ជាករណីលើកលែងចំពោះអាគារ ឬសំណង់ផ្សេងទៀត ដែលម្ចាស់សិទ្ធិបានសង់

---

[54] មាត្រា ៨៤៦ ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

[55] មាត្រា ៨៥៤.២ ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

នៅលើដី ឬ រុក្ខជាតិ ឬដំណាំដែលម្ចាស់សិទ្ធិបានដាំ ជាអាទិ៍ ដែលជាការអនុវត្តសិទ្ធិចំពោះអ្នកដ៏ទៃមិនត្រូវក្លាយជាសមាសភាគនៃដីឡើយ[56] ។

## ៣.២. ករណីអាចលក់ដោយបង្ខំបាន

ក្នុងករណីដែលអ្នកបង្កើតហ៊ីប៉ូតែក ឬ តតិយជនបានសាងសង់អាគារ នៅលើដីហ៊ីប៉ូតែកនៅក្រោយពេលហ៊ីប៉ូតែកត្រូវបានបង្កើត ហើយអ្នកបង្កើតមានកម្មសិទ្ធិលើអាគារនោះ បើទោះបីជាអាគារត្រូវបានសាង់សង់មុន ឬក្រោយក៏ដោយ ក៏ម្ចាស់បំណុលអាចលក់ដោយបង្ខំនូវអាគារ ព្រមជាមួយនឹងដីហ៊ីប៉ូតែកបានផងដែរ[57] ពីព្រោះហ៊ីប៉ូតែក មានអានុភាពលើវត្ថុដែលភ្ជាប់នឹងដីដែលជាកម្មវត្ថុនៃហ៊ីប៉ូតែក ដែលខុសពីចំណុចខាងលើ ដែលជាករណីលើកលែងបានកំណត់ឱ្យតតិយជនក្រៅពីកម្មសិទ្ធិករនៃដី ដែលផ្អែកលើសិទ្ធិដែលនាំឱ្យមានមូលហេតុគតិយុត្ត ដូចជា សិទ្ធិជួលអចិន្ត្រៃយ៍ កម្មសិទ្ធិករនៃអាគារអាចតតាំងសិទ្ធិរបស់ខ្លួនចំពោះម្ចាស់បំណុលហ៊ីប៉ូតែកបាន ។ បកមកក្នុងករណីនេះវិញ អ្នកបង្កើតហ៊ីប៉ូតែក ឬ តតិយជន មិនអាចតតាំងជាមួយនឹងម្ចាស់បំណុលបាននោះទេ។ ហើយបើអាគារនោះត្រូវបានសាងសង់នៅក្រោយពេលដែលហ៊ីប៉ូតែកបង្កើតរួច យោងតាមមាត្រា ៨៥៤ កថាខណ្ឌទី១ មាត្រាបានអនុញ្ញាតឱ្យម្ចាស់បំណុលហ៊ីប៉ូតែករុះរើអាគារដែលបានសង់លើដីហ៊ីប៉ូតែកនោះ ប្រសិនបើចំនួនថ្លៃលក់ដី និងអាគារនោះទាបជាងថ្លៃលក់ដីដែលគ្មានអាគារលើនោះ (ដីទទេ)[58]។ ម្យ៉ាងទៀត ក្នុងករណីដែលអាគារជាកម្មសិទ្ធិរបស់អ្នកបង្កើតហ៊ីប៉ូតែកមានលើដីហ៊ីប៉ូតែកតាំងពីដំបូងមកវិញ បានន័យថា អ្នកបង្កើតហ៊ីប៉ូតែកដែលមានកម្មសិទ្ធិលើដីរួចហើយ នៅពេលបង្កើតហ៊ីប៉ូតែក អានុភាពនៃហ៊ីប៉ូតែកត្រូវមានលើអាគារផងដែរ។ ក្នុងករណីនេះ ម្ចាស់បំណុលលក់ដោយបង្ខំនូវដី និងអាគារដែលមានដែលមានតាំងពីដើមដំបូងជាមួយគ្នា ហើយមិនអាចអាចធ្វើការទាមទារឱ្យរុះរើអាគារទេ។

# កថាភាគទី៤. សិទ្ធិរបស់តតិយជនដែលបានធ្វើលទ្ធកម្ម

តតិយជនដែលជាម្ចាស់អចលនវត្ថុហ៊ីប៉ូតែក ត្រូវបានច្បាប់ទទួលស្គាល់ហើយមានសិទ្ធិសុំទិញ អចលនវត្ថុមកវិញ និងសិទ្ធិទាមទារឱ្យសងសោហ៊ុយ។ យោងតាមមាត្រា ៨៥៥ និង ៨៥៦ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ បានចែងថា តតិយជនដែលបានធ្វើលទ្ធកម្ម នូវអចលនវត្ថុហ៊ីប៉ូតែកអាច

---

[56] មាត្រា ១២៣ ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

[57] មាត្រា ៨៤៦.១ ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

[58] មាត្រា ៨៥៤.១ ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

ក្លាយជាអ្នកទិញក្នុងការលក់ដោយបង្ខំបាន។ មាត្រា នេះបានបើកលទ្ធភាពឱ្យតតិយជនដែលទទួលរងនូវការនូវការលក់ដោយបង្ខំនូវអាគារដែលបានសាងសង់នៅលើដីហ៊ីប៉ូតែក តាមរយៈសិទ្ធិជួលអចិន្ត្រៃយ៍ ផលុបភោគ ឬសិទ្ធិជួលនូវសិទ្ធិស្នើសុំទិញអចលនវត្ថុលក់ដោយបង្ខំបាន។ ហើយតតិយជននោះក៏អាចទាមទារសំណងចំពោះការចំណាយចាំបាច់សម្រាប់ការគ្រប់គ្រង និងថែរក្សាវត្ថុ ឬការបង្កើននូវតម្លៃចំពោះវត្ថុនោះដោយមានអាទិភាពជាងម្ចាស់បំណុលហ៊ីប៉ូតែកទៀតផង[59]។

ឧទាហរណ៍៖

លោក ក គឺជាម្ចាស់បំណុលហ៊ីប៉ូតែកដែលបានធានាសិទ្ធិលើបំណុលចំនួន ៥ ០០០ ដុល្លារ ។ លោក ខ ជាអ្នកបង្កើតហ៊ីប៉ូតែកលើដី (A) ដែលមានតម្លៃចំនួន ៨ ០០០ ដុល្លារ។ លោក ឃ បានទិញដីនោះពី លោក ខ ក្នុងតម្លៃ៧ ០០០ ដុល្លារ។ លោក ឃ បានចេញចំណាយសោហ៊ុយចំនួន ៧០០ ដុល្លារដើម្បីបង្កើនតម្លៃនៃដីនោះ ហើយតម្លៃនៃដីនោះបានកើនឡើងចំនួន ៨ ៧០០ ដុល្លារ។ ក្រោយមក លោក ក ទាមទារឱ្យមានការលក់ដោយបង្ខំនូវដីនោះ។

ឧបមាថា តម្លៃនៃដីដែលត្រូវបានវាយតម្លៃគឺមានចំនួន ៨ ៧០០ ដុល្លារ ហើយ លោក ឃ អាចទិញដីនោះ ប្រសិនបើគាត់ចង់ទិញ។ នៅក្នុងករណីនេះ ថ្លៃលក់ដោយបង្ខំនៃដីនោះមានចំនួន ៨ ៧០០ ដុល្លារ ។ បើសិនជា លោក ឃ ជាអ្នកទិញដីនោះ ពេលនោះសិទ្ធិទាមទារសំណងនឹងត្រូវរលត់ពីអ្នកទិញអចលនវត្ថុដោយការលក់ដោយបង្ខំ តតិយជនដែលបានធ្វើលទ្ធកម្ម និងម្ចាស់បំណុលហ៊ីប៉ូតែក គឺជាមនុស្សតែមួយ។

ក្នុងករណីប្រសិនបើ លោក ឃ មិនទិញទេ លោក ឃ គ្រាន់តែអាចអនុវត្តន៍សិទ្ធិរបស់ខ្លួនដើម្បីទាមទារសំណងចំនួន ៧០០ ដុល្លារ ពីលោក ក ពីព្រោះលោក ឃ បានធ្វើឱ្យកើនតម្លៃដីនោះ។

## កថាខណ្ឌទី៥. ការអនុវត្តដោយបង្ខំករណីម្ចាស់បំណុលហ៊ីប៉ូតែកច្រើននាក់

ពាក់ព័ន្ធនឹងការអនុវត្តដោយបង្ខំ ដែលមានម្ចាស់បំណុលសិទ្ធិហ៊ីប៉ូតែកច្រើននាក់បែបនេះទៅលើអចលនវត្ថុតែមួយ មានសំណួរជាច្រើនត្រូវបានលើកឡើងដូចជា "តើមានតែម្ចាស់សិទ្ធិហ៊ីប៉ូតែកដែលនៅលំដាប់លើគេតែប៉ុណ្ណោះឬ ដែលអាចដាក់ពាក្យសុំឱ្យអនុវត្តហ៊ីប៉ូតែកបាន?" "តើម្ចាស់សិទ្ធិហ៊ីប៉ូតែកដែលឋិតនៅក្នុងលំដាប់ទី ២ ឬ លំដាប់ចុងក្រោយ អាចដាក់ពាក្យសុំឱ្យអនុវត្តហ៊ីប៉ូតែករបស់ខ្លួនមុនមុនម្ចាស់សិទ្ធិហ៊ីប៉ូតែកដែលឋិតនៅក្នុងលំដាប់ទីមួយដែរឬទេ?" តើការដាក់

[59] មាត្រា ៨៥៥ និង ៨៥៦ ,ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

ពាក្យសុំឱ្យអនុវត្តដោយបង្ខំរបស់ម្ចាស់សិទ្ធិហ៊ីប៉ូតែកដែលមានលំដាប់ទីមួយ មានអានុភាពខុសគ្នាយ៉ាងដូចម្តេច?" តើសិទ្ធិហ៊ីប៉ូតែកទាំងនោះ ត្រូវរលត់ព្រមគ្នា ឬ មានសិទ្ធិហ៊ីប៉ូតែកខ្លះត្រូវបន្តអត្ថិភាពក្រោយការលក់ដោយបង្ខំនោះ?" "តើម្ចាស់សិទ្ធិហ៊ីប៉ូតែកម្នាក់ៗ ត្រូវទទួលចំណែកប៉ុន្មានចេញពីថ្លៃលក់ដោយបង្ខំនោះ?"

ឆ្លើយតបទៅសំណួរទាំងនេះ មាត្រា៥១០កថាខណ្ឌទី១និងទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជាបានចែងថា សិទ្ធិប្រាតិភោគប្រត្យក្ស លើអចលនវត្ថុដែលអាចតតាំង នឹងសិទ្ធិប្រាតិភោគរបស់ម្ចាស់បំណុលនៃការអនុវត្តត្រូវនៅបន្តអត្ថិភាព ក្រោយការលក់ដោយបង្ខំដែលជាការអនុវត្តសិទ្ធិប្រាតិភោគនោះ។ ក្រៅពីសិទ្ធិដែលបានកំណត់ខាងលើនេះ សិទ្ធិលើអចលនវត្ថុ ត្រូវរលត់ដោយការលក់។ ម្យ៉ាងវិញទៀតមាត្រា៥៤៩កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណីបានចែងថា អ្នកទិញត្រូវទទួលខុសត្រូវសង នូវសិទ្ធិលើបំណុលដែលត្រូវបានធានាដោយសិទ្ធិប្រាតិភោគដែលអ្នកទិញបានទទួលបន្ត។

គ្មានបញ្ញត្តិណាមួយហាម មិនឱ្យម្ចាស់សិទ្ធិហ៊ីប៉ូតែក ដែលមានលំដាប់ទាបជាងដាក់ពាក្យសុំអនុវត្តដោយបង្ខំមុន ម្ចាស់សិទ្ធិហ៊ីប៉ូតែកដែលមានលំដាប់ខ្ពស់ជាងនោះទេ។ ហេតុនេះបានន័យថា បើសិនជាម្ចាស់សិទ្ធិហ៊ីប៉ូតែកដែលមានលំដាប់អាទិភាពមុនបានដាក់ពាក្យសុំអនុវត្ត នោះសិទ្ធិហ៊ីប៉ូតែកដែលមានលំដាប់បន្តបន្ទាប់ត្រូវរលត់។ តែផ្ទុយមកវិញ ប្រសិនបើម្ចាស់សិទ្ធិលើបំណុលហ៊ីប៉ូតែក ដែលមានលំដាប់បន្ទាប់ដាក់ពាក្យសុំអនុវត្តមុននោះសិទ្ធិហ៊ីប៉ូតែកដែលមានលំដាប់ខ្ពស់ជាងមិនរលត់ទេ។ ចំពោះការទទួលចំណែកដែលចេញពីថ្លៃលក់ដោយបង្ខំនោះ គឺត្រូវទទួលទៅតាមលំដាប់នៃសិទ្ធិជាអាទិភាពមិនមែនទៅតាមសមាមាត្រទេ។

<u>ឧទាហរណ៍៖</u>

ឧបមាថាតម្លៃនៃដី(A) ដែលជាកម្មសិទ្ធិរបស់ B ត្រូវបានគេវាយតម្លៃថាមានតម្លៃចំនួន ១ ០០០ ដុល្លារ ហើយមិនចាំបាច់ គិតពីសោហ៊ុយនៃនីតិវិធីនោះទេដើម្បីងាយស្រួល។

X គឺជាម្ចាស់បំណុលហ៊ីប៉ូតែកលំដាប់ទី ១ ដោយបានធានាបំណុលចំនួន ៥០០ ដុល្លារចំពោះ B ។

Y គឺជាម្ចាស់បំណុលហ៊ីប៉ូតែកលំដាប់ទី ២ ដោយបានធានាបំណុលចំនួន ៤០០ ដុល្លារចំពោះ B ។

Z គឺជាម្ចាស់បំណុលហ៊ីប៉ូតែកលំដាប់ទី ៣ ដោយបានធានាបំណុលចំនួន ៣០០ ដុល្លារ ចំពោះ B ។

១- តើហ៊ីប៉ូតែកអ្វីដែលនៅតែបន្តអត្ថិភាព ហើយហ៊ីប៉ូតែកអ្វីដែលត្រូវរលត់? តើដី (A) ត្រូវបានវាយតម្លៃដើម្បីលក់ចំនួនប៉ុន្មាន? ហើយតើម្ចាស់បំណុលហ៊ីប៉ូតែកនីមួយៗនឹងទទួលបានចំណែកចំនួនប៉ុន្មាន ប្រសិនបើ Xដាក់ពាក្យសុំឱ្យអនុវត្តហ៊ីប៉ូតែករបស់ខ្លួន?

ចម្លើយ  យោងតាមមាត្រា ៥១០ នៃក្រមនីតិវិធីរដ្ឋប្បវេណី បើសិនជា X ដាក់ពាក្យសុំអនុវត្តហ៊ីប៉ូតែករបស់ខ្លួនមុននោះ ហ៊ីប៉ូតែករបស់ Y និង Z ត្រូវរលត់ដោយការលក់ដោយបង្ខំ។ ហើយ Y និង Z អាចចូលរួមក្នុងការចែកចំណែកដោយស្វ័យប្រវត្តិ។ ឧបមាថា តម្លៃនៃដី (A) ត្រូវបានគេវាយតម្លៃថា មានតម្លៃចំនួន ១ ០០០ ដុល្លារ ( តម្លៃនេះត្រូវបានចាត់ទុកថា សមហេតុសមផល ពីព្រោះតម្លៃដើមនៃដី (A) មានចំនួន ១ ០០០ ដុល្លារ ហើយហ៊ីប៉ូតែកទាំងអស់ត្រូវបានរលត់អស់ហើយ)។ ដូច្នេះ X ត្រូវបានចំណែក ៥០០ ដុល្លារ Y ត្រូវបានចំណែក ៤០០ ដុល្លារ និង Z ត្រូវបានចំណែក ១០០ ដុល្លារ ។

២- តើហ៊ីប៉ូតែកអ្វីដែលនៅតែបន្តអត្ថិភាព ហើយហ៊ីប៉ូតែកអ្វីដែលត្រូវរលត់? តើដី (A) ត្រូវបានវាយតម្លៃដើម្បីលក់បានចំនួនប៉ុន្មាន? ហើយតើម្ចាស់បំណុលនីមួយៗនឹងទទួលបានចំណែកចំនួនប៉ុន្មាន ប្រសិនបើ Y ដាក់ពាក្យសុំឱ្យអនុវត្តហ៊ីប៉ូតែករបស់ខ្លួន?

**ចម្លើយ** ប្រសិនបើ Y ដាក់ពាក្យសុំអនុវត្តហ៊ីប៉ូតែករបស់ខ្លួនមុននោះ សិទ្ធិហ៊ីប៉ូតែករបស់ Z ត្រូវរលត់។ ប៉ុន្តែហ៊ីប៉ូតែករបស់ X មិនរលត់ទេ។ Z អាចចូលរួមក្នុងការចែកចំណែកជាមួយ Y ដែរ ។ ប៉ុន្តែ X មិនអាចចូលរួមក្នុងការចែកចំណែកបានទេ ផ្ទុយទៅវិញ X អាចដាក់ពាក្យសុំអនុវត្តហ៊ីប៉ូតែករបស់ខ្លួននៅពេលក្រោយបាន។

ឧបមាថា បើតម្លៃនៃដី (L) ត្រូវបានគេវាយតម្លៃថា មានតម្លៃចំនួន ១ ០០០ ដុល្លារ ( មិនចាំបាច់គិតថ្លៃសោហ៊ុយនៃនីតិវិធីទេ)។ អ្នកដែលទិញអចលនវត្ថុដោយការលក់ដោយបង្ខំនោះ អាចផ្តល់សំណើទិញក្នុងតម្លៃ ៥០០ ដុល្លារ ពីព្រោះអ្នកទិញ នឹងធ្វើលទ្ធកម្មដីនោះដោយមានជាប់បន្ទុកហ៊ីប៉ូតែកដែលបានធានាបំណុលចំនួន ៥០០ ដុល្លារ ។ ជាលទ្ធផល Y ត្រូវបានចំណែក ៤០០ ដុល្លារ ហើយ Z ត្រូវបានចំណែក ១០០ ដុល្លារ។

៣- តើហ៊ីប៉ូតែកអ្វីដែលនៅបន្តអត្ថិភាព ហើយហ៊ីប៉ូតែកអ្វីដែលត្រូវរលត់? ហើយម្ចាស់បំណុលនីមួយៗនឹងទទួលបានចំណែកប៉ុន្មាន ប្រសិនបើ Z ដាក់ពាក្យសុំឱ្យអនុវត្តហ៊ីប៉ូតែករបស់ខ្លួន?

ចម្លើយៈ បើសិន Z ដាក់ពាក្យសុំអនុវត្តហ៊ីប៉ូតែករបស់ខ្លួនមុននោះ ហ៊ីប៉ូតែករបស់ Z ត្រូវរលត់។ ប៉ុន្តែហ៊ីប៉ូតែករបស់ X និង Y មិនរលត់ទេ។ X និង Y មិនអាចចូលរួមក្នុងការចែកចំណែកបានទេ។ ផ្ទុយទៅវិញ X និង Y អាចដាក់ពាក្យសុំអនុវត្តហ៊ីប៉ូតែករបស់ខ្លួនចំពោះអ្នកដែលបានធ្វើលទ្ធកម្មដោយការលក់ដោយបង្ខំចំពោះដី (A) នោះបាន។ ឧបមាថាតម្លៃនៃដី(A) ត្រូវបានគេវាយតម្លៃថា មានតម្លៃចំនួន ១ ០០០ ដុល្លារ ( មិនចាំបាច់គិតពីសោហ៊ុយនីតិវិធីទេ)។ អ្នកដែលទិញអចលនវត្ថុដោយការលក់ដោយបង្ខំនោះ នឹងមិនតម្រូវឱ្យបង់នូវនូវតម្លៃពេញទេ ពីព្រោះដីនោះនៅជាប់បន្ទុក ៩០០ ដុល្លារដែលជាសិទ្ធិរបស់ X និង Y ។ ដូច្នេះ អ្នកទិញបង់ត្រឹមតែតម្លៃ ១០០ ដុល្លារតែប៉ុណ្ណោះ។ មានន័យថា Z មានសិទ្ធិទទួលបានតែ ១០០ តែប៉ុណ្ណោះ។

យោងតាមករណីសិក្សាខាងលើ យើងឃើញថា មិនថា ម្ចាស់បំណុលហ៊ីប៉ូតែកនៅក្នុងលំដាប់ទីប៉ុន្មានដែលបានដាក់ពាក្យសុំអនុវត្តហ៊ីប៉ូតែកមុននោះទេ គឺចំណែកដែលម្ចាស់បំណុលហ៊ីប៉ូតែកម្នាក់ៗត្រូវទទួលបាន នៅតែដូចគ្នាដែលដូចលោក Z នៅក្នុងករណីនេះ គឺនៅតែបានទទួលចំណែក ១០០ ដុល្លារដដែលចេញពីថ្លៃលក់ដោយបង្ខំនៅក្នុងគ្រប់ករណីទាំងបីខាងលើ។

## កថាភាគទី៦. ហ៊ីប៉ូតែករួម

ហ៊ីប៉ូតែករួម គឺជាការបង្កើតហ៊ីប៉ូតែកមួយលើអចលនវត្ថុច្រើន ដើម្បីធានាសិទ្ធិលើបំណុលតែមួយ។ មានន័យថា អ្នកបង្កើតហ៊ីប៉ូតែក បានយកអចលនវត្ថុច្រើនកន្លែងរបស់ខ្លួន ដើម្បីទៅដាក់ធានាបំណុលជាមួយម្ចាស់បំណុលណាម្នាក់[60]។

ឧបមាថា លោក ក គាត់មានដីបីកន្លែង (A B C) គាត់យកដីបីកន្លែងនោះទៅធានាបំណុលជាមួយម្ចាស់បំណុលហ៊ីប៉ូតែក លោក ខ ។ ដូច្នោះ ដីទាំងបីកន្លែង ( A B C ) គឺជាកម្មវត្ថុនៃហ៊ីប៉ូតែក ហៅថា ហ៊ីប៉ូតែករួម។

### ៦.១. ករណីនៃការចែកចំណែកព្រមគ្នា

ក្នុងករណីហ៊ីប៉ូតែករួម ត្រូវបានបង្កើតឡើង នៅពេលអនុវត្តហ៊ីប៉ូតែក ម្ចាស់បំណុលហ៊ីប៉ូតែកអាចលក់ដោយបង្ខំនូវអចលនវត្ថុទាំងអស់ ( A B C ) នៅពេលជាមួយគ្នា ហើយម្ចាស់បំណុលហ៊ីប៉ូ

[60] មាត្រា ៨៥៧ , ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

តែកនឹងទទួលបានចំណែកពីប្រាក់ដែលបានមកពីការលក់ដោយបង្ខំនូវអចលនវត្ថុទាំងអស់នោះទៅតាមសមាមាត្រនៃតម្លៃអចលនវត្ថុនីមួយៗ ករណីនេះ ហៅថា ការចែកចំណែកព្រមគ្នា[61]។

**ឧទាហរណ៍៖**

កូនបំណុល A បានបង្កើតហ៊ីប៉ូតែករួមលើដី L1 និង L2 ដើម្បីធានាបំណុលរបស់ម្ចាស់បំណុល ក ចំនួន USD ២,០០០ នៅថ្ងៃទី ១៩ ខែកុម្ភៈ ឆ្នាំ២០១២។ នៅថ្ងៃទី ០៦ ខែមិថុនា ឆ្នាំ២០១៣ កូនបំណុល A បានបង្កើតហ៊ីប៉ូតែកលើដី L2 ដើម្បីធានាបំណុលរបស់ម្ចាស់បំណុល ខ ចំនួន USD ៣,០០០។ សន្មតថាអចលនវត្ថុត្រូវបានលក់ដោយបង្ខំព្រមគ្នា ដោយដី L1 លក់ក្នុងតម្លៃ USD ១,០០០ និងដី L2 លក់ក្នុងតម្លៃ USD ១,៥០០។

ចម្លើយ

ក្នុងករណីដែលម្ចាស់បំណុលហ៊ីប៉ូតែករួមលំដាប់ទី១ អនុវត្តហ៊ីប៉ូតែក ហើយការចែកចំណែកប្រព្រឹត្តទៅព្រមគ្នា ចំពោះដី L1 និង L2 នោះប្រាក់ដែលបានមកពីការលក់ដីទាំងពីរត្រូវយកមកបែងចែកដូចខាងក្រោម៖

- ម្ចាស់បំណុល ក មានហ៊ីប៉ូតែករួមលើដី L1 និង L2 ត្រូវទទួលចំណែកដូចខាងក្រោម៖

$$\text{ចំណែកពីដី L1} = \text{សិទ្ធិលើបំណុលធានាដោយហ៊ីប៉ូតែករួម} \times \frac{\text{តម្លៃដី L1}}{\text{តម្លៃដី L1} + \text{តម្លៃដី L2}}$$

$$= ២,០០០ \times \frac{១០០០}{១០០០ + ១៥០០}$$

$$= \text{USD } ៨០០$$

$$\text{ចំណែកពីដី L2} = \text{សិទ្ធិលើបំណុលធានាដោយហ៊ីប៉ូតែករួម} \times \frac{\text{តម្លៃដី L2}}{\text{តម្លៃដី L1} + \text{តម្លៃដី L2}}$$

$$= ២,០០០ \times \frac{១៥០០}{១០០០ + ១៥០០}$$

[61] មាត្រា ៨៥៧.១ , ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

= USD ១,២០០

ម្ចាស់បំណុល ខ មានហ៊ីប៉ូតែកលើដី L2 ត្រូវទទួលចំណែកដូចខាងក្រោម៖

ចំណែកពីដី L2 = តម្លៃដី L2 - ចំនួនប្រាក់ដែលសល់ពីការចែកចំណែកឱ្យម្ចាស់បំណុល លំដាប់ទី១

= ១,៥០០ - ១,២០០

= USD ៣០០

ដូច្នេះ ម្ចាស់បំណុល ក ដែលមានហ៊ីប៉ូតែករួមលើដី L1 និង L2 ត្រូវទទួលចំណែកពីដី L1 ចំនួន USD ៨០០ និងពីដី L2 ចំនួន USD ១,២០០។ ចំណែកឯ ម្ចាស់បំណុល ខ ដែលមានហ៊ីប៉ូតែកលើដី L2 ត្រូវទទួលចំណែកចំនួន USD ៣០០ ពីដី L2 ។

## ៦.២. ករណីនៃការចែកចំណែកមិនព្រមគ្នា

ការចែកចំណែកមិនព្រមគ្នា គឺជាស្ថានភាពដែលម្ចាស់បំណុលហ៊ីប៉ូតែករួម អនុវត្តហ៊ីប៉ូតែកតែទៅលើអចលនវត្ថុហ៊ីប៉ូតែកមួយក្នុងចំណោមអចលនវត្ថុហ៊ីប៉ូតែកច្រើន ហើយទទួលការសងចំពោះសិទ្ធិលើបំណុលទាំងអស់ ពីប្រាក់ដែលបានមកពីការលក់ដោយបង្ខំ។ ម្ចាស់បំណុលហ៊ីប៉ូតែកលំដាប់បន្តបន្ទាប់នៃអចលនវត្ថុដែលត្រូវបានលក់ អាចអនុវត្តហ៊ីប៉ូតែករបស់ម្ចាស់បំណុលលំដាប់ខ្ពស់ជាងនោះ ដោយឧបាទេសកម្ម លើអចលនវត្ថុហ៊ីប៉ូតែកដែលមិនត្រូវបានលក់ ហើយអាចទទួលបានការសង ត្រឹមកម្រិតនៃសិទ្ធិលើបំណុលដែលម្ចាស់បំណុលលំដាប់ខ្ពស់ជាងនោះអាចទទួលបានចំពោះអចលនវត្ថុហ៊ីប៉ូតែករួម ដែលមិនត្រូវបានលក់។

<u>ឧទាហរណ៍៖</u>

កូនបំណុល A បានបង្កើតហ៊ីប៉ូតែករួមលើដី L1 និង L2 ដើម្បីធានាបំណុលរបស់ម្ចាស់ ក ចំនួន USD ២,០០០ នៅថ្ងៃទី ១៩ ខែកុម្ភៈ ឆ្នាំ២០១២។ នៅថ្ងៃទី ០៦ ខែមិថុនា ឆ្នាំ២០១៣ កូនបំណុល A បានបង្កើតហ៊ីប៉ូតែកលើដី L2 ដើម្បីធានាបំណុលរបស់ម្ចាស់បំណុល ខ ចំនួន USD ៤,០០០ ។ បន្ទាប់មកនៅថ្ងៃទី ០៧ ខែកក្កដា ឆ្នាំ២០១៤ កូនបំណុល A បានបង្កើតហ៊ីប៉ូតែកលើដី L2 ដើម្បីធានាបំណុលរបស់ម្ចាស់បំណុល គ ចំនួន USD ១,០០០។ សន្មតថាម្ចាស់បំណុល

ហ៊ីប៉ូតែករួមលំដាប់ទី១ បានលក់ដោយបង្ខំនូវដី L1 ហើយប្រាក់ដែលបានមកពីការលក់មានចំនួន USD ៣,០០០។

ចម្លើយ

ក្នុងករណីខាងលើ ដី L1 គឺជាអចលនវត្ថុដែលត្រូវបានលក់។ ហេតុនេះ ទឹកប្រាក់ដែលបានមកពីការលក់អចលនវត្ថុ L1 ត្រូវបែងចែកដូចខាងក្រោម៖

- ម្ចាស់បំណុល ក (ម្ចាស់បំណុលហ៊ីប៉ូតែករួមលំដាប់ទី១) ត្រូវទទួលបានការសងពីដី L1 ចំនួន USD ២,០០០
- ម្ចាស់បំណុល ខ (ម្ចាស់បំណុលហ៊ីប៉ូតែករួមលំដាប់ទី២) ត្រូវទទួលបានការសងពីដី L1 ចំនួន USD ១,០០០

ករណីនេះ ម្ចាស់បំណុល ខ អាចអនុវត្តឧបាទេសកម្មលើដី L2 ដូចខាងក្រោម៖

ចំណែកដែលម្ចាស់បំណុល ខ អាចទទួលបានតាមរយៈឧបាទេសកម្មលើដី L2

$$L2 = ២,០០០ \times \frac{១,៥០០}{៣,០០០ + ១,៥០០}$$

= USD ៦៦៦,៦៦

ចំណែកដែលម្ចាស់បំណុល គ អាចទទួលបានពីដី L2 = ១,៥០០ - ៦៦៦,៦៦

= USD ៨៣៣,៣៤

សរុបមកចំណែកដែលម្ចាស់បំណុលហ៊ីប៉ូតែកទាំងអស់អាចទទួលបានពីដី L1 និង L2 មានដូចខាងក្រោម៖

- ម្ចាស់បំណុលហ៊ីប៉ូតែករួម ក អាចទទួលបានការសងពីដី L1 ចំនួន USD ២,០០០
- ម្ចាស់បំណុលហ៊ីប៉ូតែក ខ អាចទទួលបានការសងពីដី L1 ចំនួន USD ១,០០០ និង ដី L2 ចំនួន USD ៦៦៦,៦៦
- ម្ចាស់បំណុលហ៊ីប៉ូតែក គ អាចទទួលបានការសងពីដី L2 ចំនួន USD ៨៣៣,៣៤

## ផ្នែកទី២. ការចាត់ចែងហ៊ីប៉ូតែកធម្មតា

បញ្ញត្តិច្បាប់ដែលបានកំណត់ឱ្យមានការចាត់ចែងហ៊ីប៉ូតែកធម្មតានេះ បានធ្វើឱ្យមានចម្ងល់យ៉ាងច្រើន ថាតើច្បាប់បានអនុញ្ញាតឱ្យម្ចាស់បំណុលមានសិទ្ធិចាត់ចែងហ៊ីប៉ូតែកដោយវិធីណា បើក្នុងជំពូកដែលចែងពីហ៊ីប៉ូតែកបានបញ្ជាក់យ៉ាងច្បាស់ថាហើយថា កូនបំណុលដែលដាក់ហ៊ីប៉ូតែកមិនត្រូវបានបាត់បង់នូវអានុភាពជាម្ចាស់កម្មសិទ្ធិនៃអចលនវត្ថុរបស់ខ្លួនឡើយ ហើយម្ចាស់បំណុលពុំអាចក្លាយជាម្ចាស់កម្មសិទ្ធិ ឬធ្វើការចាត់ចែងលក់ដូរនូវអចលនវត្ថុនោះបានដែរ។ ការចាត់ចែងហ៊ីប៉ូតែក ជាការផ្លាស់ប្តូរមួយដែលតម្រូវឱ្យធ្វើជាលិខិតយថាភូត និងចុះបញ្ជីបន្ថែមដើម្បីឱ្យមានសុពលភាពត្រឹមត្រូវ[62]។ ហើយដើម្បីអាចតតាំងជាមួយកូនបំណុលដែលមានកាតព្វកិច្ចចម្បង អ្នកធានា អ្នកបង្កើតហ៊ីប៉ូតែក និងប្រតិសិទ្ធិរបស់ជនទាំងនោះបាន លុះត្រាតែម្ចាស់បំណុលហ៊ីប៉ូតែក ជូនដំណឹងទៅកូនបមណុលដែលមានកាតព្វកិច្ចចម្បង ឬ ទទួលការយល់ព្រមពីកូនបំណុលនេះទាក់ទងនឹងការចាត់ចែងខាងលើ[63]។ ពាក់ព័ន្ធនឹងការចាត់ចែងហ៊ីប៉ូតែកខាងលើនេះ យើងខ្ញុំសូមធ្វើការលើកយកបីចំណុចធំៗមកធ្វើការបកស្រាយអំពី ប្រភេទនៃការចាត់ចែងហ៊ីប៉ូតែកធម្មតា ( **កថាខណ្ឌទី១** ) លក្ខខណ្ឌដើម្បីបង្កើតអានុភាព ( **កថាភាគទី២** ) ការរលត់នៃហ៊ីប៉ូតែកធម្មតា ( **កថាខណ្ឌទី៣** )។

### កថាភាគទី១. ប្រភេទនៃការចាត់ចែងហ៊ីប៉ូតែក

ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧ ផ្នែកទី៥ បានចែងអំពី ការចាត់ចែងហ៊ីប៉ូតែកដែលកំណត់ដោយច្បាប់ និងទទួលស្គាល់នូវសិទ្ធិចាត់ចែងរបស់ម្ចាស់បំណុលហ៊ីប៉ូតែកចំពោះអចលនវត្ថុហ៊ីប៉ូតែកដោយធ្វើឡើងតាមរយៈ ការដាក់ហ៊ីប៉ូតែកបន្ត ( **១.១** ) អនុប្បទាន ឬការបោះបង់ហ៊ីប៉ូតែក ( **១.២** ) អនុប្បទាន ឬការបោះបង់ និងការផ្លាស់ប្តូរនូវលំដាប់នៃហ៊ីប៉ូតែក ( **១.៣** )។

---

[62] មាត្រា ៨៦២ ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

[63] មេធាវី អ៊ួរ អៀឡេន "ជំពូកទី២ ៖ យន្តការនៃការអនុវត្តសិទ្ធិហ៊ីប៉ូតែក " ការផ្សព្វផ្សាយរបស់ការិយាល័យមេធាវី អៀឡេន & អាសូស៊ីអេត ខែវិច្ឆិកា ឆ្នាំ២០១៧។

## ១.១. ហ៊ីប៉ូតែកបន្ត

ក្រមរដ្ឋប្បវេណីថ្មី បានអនុញ្ញាតឱ្យម្ចាស់បំណុលហ៊ីប៉ូតែកធ្វើហ៊ីប៉ូតែកបន្តបាន មានន័យថា យកហ៊ីប៉ូតែកនេះមកធ្វើជាប្រាតិភោគសម្រាប់កាតព្វកិច្ចរបស់ខ្លួន ឬ តតិយជននោះ[64]។ ត្រង់ចំណុច នេះច្បាប់ភូមិបាលឆ្នាំ២០០១ ពុំបានបញ្ញត្តិថាយ៉ាងណាទេ តែមាត្រា ២០៥ នៃច្បាប់នេះ បានចែងថា ទ្រព្យដែលកំពុងដាក់បញ្ចាំមិនអាចដាក់ហ៊ីប៉ូតែកបានឡើយ។ ហើយនៅពេលចែកចំណែកនូវប្រាក់ ដែលបានមកពីលក់ដោយបង្ខំនូវអចលនវត្ថុហ៊ីប៉ូតែក ម្ចាស់បំណុលហ៊ីប៉ូតែកបន្ត អាចទទួលបាន ការសងចំពោះសិទ្ធិលើបំណុលទាំងអស់បានត្រឹមកម្រិតនៃចំនួនទឹកប្រាក់នៃចំណែកដែលត្រូវចែក ទៅឱ្យម្ចាស់បំណុលហ៊ីប៉ូតែក ប៉ុន្តែប្រសិនបើសិទ្ធិលើបំណុលនោះ មិនទាន់ដល់កំណត់ពេលត្រូវសង ម្ចាស់បំណុលហ៊ីប៉ូតែកបន្តគ្រាន់តែអាចទាមទារឱ្យតម្កល់នូវចំនួនទឹកប្រាក់ ដែលខ្លួនអាចទទួលបាន ការសងនោះតែប៉ុណ្ណោះ[65]។

ឧទាហរណ៍៖ **ដារ៉ា** ជាម្ចាស់បំណុលហ៊ីប៉ូតែក ដោយមានការធានាបំណុលរបស់ **ធីតា** ចំនួន ៣,០០០ ដុល្លារ ចំពោះដីដែលជាកម្មសិទ្ធិរបស់ **ធីតា**។ **ដារ៉ា** បានជំពាក់ **មង្គល** ចំនួន ១,០០០ ហើយបានយកហ៊ីប៉ូតែរបស់ខ្លួនមកធ្វើជាប្រាតិភោគ ដើម្បីធានាបំណុលរបស់ខ្លួនចំពោះ **មង្គល**។ ដូច្នេះ ក្នុងករណីនេះ **មង្គល** អាចទទួលបានប្រាក់ចំនួន ១,០០០ ដុល្លារ ពីការលក់ដី ដោយមាន អាទិភាព។ មួយវិញទៀត ប្រសិនបើកាលបរិច្ឆេទនៃការកំណត់សងនៃកាតព្វកិច្ចរបស់ **ដារ៉ា** មិនទាន់ បានមកដល់នៅឡើយទេ **មង្គល** អាចទាមទារឱ្យតម្កល់ប្រាក់ចំនួន ១,០០០ ដុល្លារ។

សរុបជារួមមកវិញ ហ៊ីប៉ូតែកបន្ត បានន័យថា ម្ចាស់បំណុលហ៊ីប៉ូតែកដើមគាត់យកហ៊ីប៉ូតែក របស់គាត់នឹងទៅដាក់ឱ្យម្ចាស់បំណុលផ្សេងទៀត ដូច្នេះពេលនោះគាត់ក្លាយទៅជាកូនបំណុលម្តង ហើយ គាត់យកសិទ្ធិហ៊ីប៉ូតែករបស់គាត់នឹងយកទៅដាក់ឱ្យគេក្នុងតម្លៃមួយផ្សេងទៀតប៉ុន្តែដាក់តម្លៃ មួយនឹងគឺមិនអាចលើសពីផលប្រយោជន៍របស់គាត់បានផ្តល់ទៅឱ្យកូនបំណុលទេ។

## ១.២. អនុប្បទាន ឬការបោះបង់ហ៊ីប៉ូតែក

ម្ចាស់បំណុលហ៊ីប៉ូតែកអាចធ្វើអនុប្បទាន ឬបោះបង់ហ៊ីប៉ូតែកបាន ដើម្បីផលប្រយោជន៍ របស់ម្ចាស់បំណុលផ្សេងទៀត ចំពោះកូនបំណុលតែម្នាក់។ អនុប្បទានិកនៃហ៊ីប៉ូតែក អាចអនុវត្តហ៊ីប៉ូ

[64] មាត្រា ៨៥៩.១ ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

[65] មាត្រា ៨៥៩.២ ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

តែកដែលខ្លួនបានទទួល ដោយយកមកធ្វើជាប្រាតិភោគនៃសិទ្ធិលើបំណុលរបស់ខ្លួន[66]។ មានន័យថា ប្រសិនបើហ៊ីប៉ូតែកត្រូវបានធ្វើអនុប្បទាន ម្ចាស់បំណុលហ៊ីប៉ូតែកដែលបានធ្វើអនុប្បទានហ៊ីប៉ូតែកនោះនឹងក្លាយជាម្ចាស់បំណុលដែលគ្មានហ៊ីប៉ូតែក ចំណែកឯម្ចាស់បំណុលដែលបានទទួលអនុប្បទានហ៊ីប៉ូតែកនោះនឹងក្លាយជាម្ចាស់បំណុលថ្មីដែលមានហ៊ីប៉ូតែក។ ជារួម ភាគីនៃអនុប្បទានហ៊ីប៉ូតែកសិទ្ធិលើបំណុលរបស់អនុប្បទានិក មានអាទិភាពជាងសិទ្ធិលើបំណុលរបស់អនុប្បទាយី[67]។

ម្យ៉ាងវិញទៀត បុគ្គលដែលបោះបង់ពុំអាចហ៊ីប៉ូតែក ពុំអាចអះអាងអានុភាពនៃហ៊ីប៉ូតែកនោះចំពោះបុគ្គលដែលបានទទួលនូវការបោះបង់នោះឡើយ មានន័យថា រវាងគូភាគីនៃការបោះបង់ហ៊ីប៉ូតែក ភាគីទាំងសងខាង គឺមិនអាចអះអាងពីសិទ្ធិអាទិភាពទៅវិញទៅមកបានឡើយ[68]។ ត្រង់នេះចង់សំដៅថា ម្ចាស់បំណុលហ៊ីប៉ូតែក អាចធ្វើអនុប្បទាន ឬ បោះបង់នូវហ៊ីប៉ូតែកបាន ដើម្បីជាប្រយោជន៍របស់ម្ចាស់បំណុលផ្សេងទៀត ចំពោះកូនបំណុលតែម្នាក់។ អនុប្បទានិកនៃហ៊ីប៉ូតែក អាចអនុវត្តហ៊ីប៉ូតែកដែលខ្លួនបានទទួលដោយយកមកធ្វើប្រាតិភោគនៃសិទ្ធិលើបំណុលរបស់ខ្លួនបាន។ ចំណែកបុគ្គលដែលបានបោះបង់ហ៊ីប៉ូតែក ពុំអាចអះអាងអានុភាពនៃហ៊ីប៉ូតែកនោះ ចំពោះបុគ្គលដែលបានទទួលនូវការបោះបង់នោះឡើយ។

<u>ឧទាហរណ៍៖</u> លោក ក ជាម្ចាស់បំណុលធម្មតារបស់ លោក គ។ លោក ខ ជាម្ចាស់បំណុលហ៊ីប៉ូតែក របស់លោក គ។ ក្នុងករណីដែលទទួលបានការសងនូវសិទ្ធិលើបំណុល លោក ខ ច្បាស់ជាទទួលបាននូវការសងមុនលោក ក។ ប៉ុន្តែលោក ខ អាចបោះបង់សិទ្ធិជាអាទិភាពរបស់ខ្លួនទៅឱ្យលោក ក ក្រោមរូបភាពជាអនុប្បទានហ៊ីប៉ូតែក ដើម្បីឱ្យលោក ក ទទួលបាននូវការសងជាអាទិភាព។ ដូច្នេះ លោក ខ គឺបាត់បង់នូវសិទ្ធិជាអាទិភាពនោះ ក្រោយពេលធ្វើអនុប្បទានទៅឱ្យលោក ក ហើយក្លាយទៅជាម្ចាស់បំណុលធម្មតា។

ការធ្វើអនុប្បទាន ឬការបោះបង់ហ៊ីប៉ូតែក គឺតម្រូវឱ្យម្ចាស់បំណុលធ្វើការចុះបញ្ជីត្រឹមត្រូវ នៅមន្ទីសុរិយោដី ដោយក្រសួងគឺបានកំណត់ទម្រង់ឯកសារយ៉ាងជាក់លាក់ដើម្បីចុះបញ្ជី ដែលមានដូចជា ពាក្យសុំចុះបញ្ជីអំពីអនុប្បទាន ឬការបោះបង់ហ៊ីប៉ូតែក ដែលក្នុងនោះត្រូវមាន រៀបរាប់ពីគោលបំណង មូលហេតុ បុគ្គលមានសិទ្ធិចុះបញ្ជី បុគ្គលមានកាតព្វកិច្ចចុះបញ្ជី បំណុលដែលត្រូវបានធានា

[66] នីតិប្រាតិភោគ របស់សាស្ត្រាចារ្យ ចាំង ស៊ីណាត ឆ្នាំ ២០១២ ទំព័រ ៣០។
[67] មាត្រា៨៦០ សេចក្តីកំណត់ចំពោះមាត្រានីមួយៗភាគទី៤ ឆ្នាំ២០១០ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។
[68] មាត្រា៨៦០ សេចក្តីកំណត់ចំពោះមាត្រានីមួយៗភាគទី៤ ឆ្នាំ២០១០ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

ដោយហ៊ីប៉ូតែក និងអចលនវត្ថុហ៊ីប៉ូតែក។ ការចុះបញ្ជីទៀតសោត បុគ្គលដែលដាក់ពាក្យសុំត្រូវភ្ជាប់ជាមួយឯកសារតម្រូវដោយក្រសួងដែលមានដូចជា ឯកសារបញ្ជាក់អត្តសញ្ញាណរបស់បុគ្គលដែលដាក់ពាក្យសុំ ក៏ដូចជាប័ណ្ណសម្គាល់កម្មសិទ្ធិច្បាប់ដើម។

សរុបមក អនុប្បទាន និងការបោះបង់ហ៊ីប៉ូតែក គឺជាទស្សនៈដែលមានលក្ខណៈស្រដៀងគ្នា ប៉ុន្តែវាមានភាពខុសគ្នា។ អ្វីដែលត្រូវបានធ្វើអនុប្បទាន ឬបោះបង់នោះ គឺមានអាទិភាពចំពោះគ្នា។

## ១.៣. អនុប្បទាន ឬការបោះបង់ និងការផ្លាស់ប្តូរនូវលំដាប់ហ៊ីប៉ូតែក

ម្ចាស់បំណុលហ៊ីប៉ូតែក អាចធ្វើអនុប្បទាន ឬបោះបង់នូវលំដាប់នៃហ៊ីប៉ូតែកបាន ដើម្បីផលប្រយោជន៍របស់ម្ចាស់បំណុលផ្សេងទៀត ចំពោះកូនបំណុលតែម្នាក់។ ម្ចាស់បំណុលហ៊ីប៉ូតែក ក៏អាចផ្លាស់ប្តូរលំដាប់នៃហ៊ីប៉ូតែកនោះបាន ដោយការព្រមព្រៀងជាមួយម្ចាស់បំណុលហ៊ីប៉ូតែកផ្សេងទៀត។ ប៉ុន្តែ បើមានបុគ្គលដែលមានទំនាក់ទំនងនឹងផលប្រយោជន៍ចំពោះការផ្លាស់ប្តូរនោះ ម្ចាស់បំណុលហ៊ីប៉ូតែក ត្រូវទទួលការយល់ព្រមអំពីបុគ្គលនោះ។ ម្ចាស់បំណុលហ៊ីប៉ូតែក ដែលទទួលបានអនុប្បទាននូវលំដាប់ហ៊ីប៉ូតែក អាចទទួលបានការសងដោយមានអាទិភាពជាងម្ចាស់បំណុលហ៊ីប៉ូតែកដែលបានធ្វើអនុប្បទាននូវលំដាប់នោះ នូវចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុលទាំងអស់ ពីប្រាក់ដែលបានមកពីការលក់ដោយបង្ខំនូវអចលនវត្ថុហ៊ីប៉ូតែកនោះ ត្រឹមកម្រិតនៃចំនួនប្រាក់សរុបនៃចំណែកដែលត្រូវចែកទៅឱ្យម្ចាស់បំណុលហ៊ីប៉ូតែកទាំងពីរនោះ។ ម្ចាស់បំណុលហ៊ីប៉ូតែក ដែលទទួលនូវការបោះបង់លំដាប់ហ៊ីប៉ូតែក អាចទទួលការសងដោយមានសមភាពជាមួយម្ចាស់បំណុលដែលមានការលះបង់លំដាប់ហ៊ីប៉ូតែនោះ តាមសមាមាត្រនៃចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុល ក្នុងទំហំនៃចំនួនទឹកប្រាក់សរុបនៃចំណែកដែលត្រូវចែកទៅឱ្យម្ចាស់បំណុលហ៊ីប៉ូតែកទាំងពីរនោះ។ ម្ចាស់បំណុលហ៊ីប៉ូតែកដែលបានព្រមព្រៀងក្នុងការផ្លាស់ប្តូរលំដាប់ហ៊ីប៉ូតែក អាចអនុវត្តហ៊ីប៉ូតែកបាន តាមការព្រមព្រៀងនោះ។

## កថាភាគទី២. លក្ខខណ្ឌដើម្បីបង្កើតអានុភាព

រាល់ការចាត់ចែងទាំងអស់ដែលបានរៀបរាប់ខាងលើ ហ៊ីប៉ូតែកបន្ត ការធ្វើអនុប្បទាន ឬ ការបោះបង់នូវហ៊ីប៉ូតែក និងការធ្វើអនុប្បទាន ឬ ការបោះបង់ និងការផ្លាស់ប្តូរនូវលំដាប់នៃហ៊ីប៉ូតែក នឹងមានអានុភាពបានលុះត្រាតែបានធ្វើឡើងជា លិខិតយថាភូត និងមានការចុះបញ្ជីបន្ថែមអំពីការចាត់ចែងនោះឱ្យមានភាពត្រឹមត្រូវ ហើយត្រូវមានការបញ្ជូនដំណឹងទៅកូនបំណុលដែលមាន

កាតព្វកិច្ចចម្បង ឬទទួលការយល់ព្រមពីកូនបំណុលដែលមានកាតព្វកិច្ចចម្បងឱ្យបានដឹងអំពីការចាត់ចែងនោះ។ ការជូនដំណឹង ឬការយល់ព្រមនេះ គឺពិតជាមានភាពចាំបាច់ណាស់ ដើម្បីឱ្យពួកគេអាចដឹងថា តើនរណាគឺជាម្ចាស់បំណុលហ៊ីប៉ូតែកពិតប្រាកដ។

ហើយនៅក្នុងករណីដែលកូនបំណុលដែលមានកាតព្វកិច្ចចម្បង ត្រូវបានជូនដំណឹងអំពីការចាត់ចែងហ៊ីប៉ូតែក ឬផ្តល់ការយល់ព្រមចំពោះការចាត់ចែងហ៊ីប៉ូតែក ប៉ុន្តែកូនបំណុលដែលមានកាតព្វកិច្ចចម្បងបានសងកាតព្វកិច្ច ដោយគ្មានការយល់ព្រមពីអ្នកដែលទទួលផលប្រយោជន៍ពីការចាត់ចែងហ៊ីប៉ូតែក កូនបំណុលដែលមានកាតព្វកិច្ចចម្បងមិនអាចតតាំងការសងកាតព្វកិច្ចនោះចំពោះអ្នកដែលទទួលផលប្រយោជន៍បានឡើយ។ ការចែងដូចនេះ គឺដើម្បីការពារអ្នកដែលទទួលផលប្រយោជន៍ពីការខូចខាតដែលមិនអាចព្យាករណ៍បាន ដោយសារការសងកាតព្វកិច្ចដោយកូនបំណុលដោយគ្មានការដឹងមុនដោយអ្នកទទួលផលប្រយោជន៍។

លើសពីនេះទៅទៀត អំពីលំដាប់នៃការចាត់ចែងហ៊ីប៉ូតែក ប្រសិនបើមានបុគ្គលច្រើននាក់ទទួលផលប្រយោជន៍ពីការចាត់ចែងហ៊ីប៉ូតែក លំដាប់នៃសិទ្ធិរបស់បុគ្គលទាំងអស់នោះនឹងត្រូវសម្រេចដោយអនុលោមទៅតាមពេលវេលានៃការចុះបញ្ជីបន្ថែមនៅក្នុងបញ្ជីដែលចុះហ៊ីប៉ូតែកនោះ[69] ការបញ្ញត្តិនេះស្របតាមគោលការណ៍ទូទៅពាក់ព័ន្ធនឹងការចុះបញ្ជីអចលនវត្ថុ ដែលលំដាប់នៃសិទ្ធិត្រូវកំណត់តាមពេលវេលានៃការចុះបញ្ជី។

## កថាភាគទី៣. ការរលត់នៃហ៊ីប៉ូតែក

ការរលត់នៃហ៊ីប៉ូតែក គឺជាស្ថានភាពបាត់បង់បន្ទុកនៅលើកម្មវត្ថុនៃហ៊ីប៉ូតែក តាមលក្ខខណ្ឌច្បាប់ ឬកម្មវត្ថុនៃហ៊ីប៉ូតែកត្រូវបានបាត់បង់តាមស្ថានភាពជាក់ស្តែង។ ជាក់ស្តែង ក្នុងករណីដែលសិទ្ធិលើបំណុលត្រូវបានធានា បានរលត់ដោយការសង ឬ ដោយអាជ្ញាយុកាលនៃការរលត់សិទ្ធិលើបំណុល ឬ ដោយហេតុផលផ្សេងៗទៀត សិទ្ធិប្រាតិភោគប្រត្យក្សក៏ត្រូវរលត់ដែរ ក្នុងករណីនេះ គេហៅថា "លក្ខណៈបន្ទាប់បន្សំនៃសិទ្ធិប្រាតិភោគប្រត្យក្ស"។ ប៉ុន្តែត្រូវកត់សម្គាល់ផងដែរថា សិទ្ធិប្រាតិភោគប្រត្យក្សមិនរលត់ទេ ប្រសិនបើចំនួននៃសិទ្ធិលើបំណុលដែលត្រូវបានធានាទាំងអស់មិនរលត់ នេះគេហៅថា "អវិភាគភាពនៃសិទ្ធិប្រាតិភោគប្រត្យក្ស"។ ជាការពិតណាស់ ក្រមរដ្ឋប្បវេណីបានបញ្ញត្ត ចំពោះការជ្រើសយកប្រព័ន្ធនៃការសងដោយថ្លៃលក់ ដោយហេតុថា ស្ថានភាពអចលនវត្ថុនៃ

[69] មាត្រា ៨៦៣ ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

កម្ពុជាមិនទាន់បានចុះបញ្ជីពេញលេញ ហើយការគ្រប់គ្រងការចុះបញ្ជីក៏មិនទាន់មានលក្ខណៈល្អប្រសើរខ្លាំង និងមិនចង់ដាក់បន្ទុកឱ្យម្ចាស់បំណុលហ៊ីប៉ូតែក ដោយអ្នកទិញ ជាអ្នកទទួលបន្ទុកនោះវិញ និងទុកលទ្ធភាពឱ្យតតិយជនដែលបានធ្វើលទ្ធកម្ម ចំពោះអចលនវត្ថុ ដែលជាកម្មវត្ថុហ៊ីប៉ូតែក និងម្ចាស់បំណុលហ៊ីប៉ូតែកអាចព្រមព្រៀងគ្នា អំពីវិធីរលត់ហ៊ីប៉ូតែកដែលខ្លួនបង្កើត។

## ៣.១. ការរលត់នៃកិច្ចសន្យាបង្កើតហ៊ីប៉ូតែកដោយការទាមទារ

ក្នុងករណីដែលតតិយជនបានទិញកម្មសិទ្ធិ សិទ្ធិជួលអចិន្ត្រៃយ៍ ឬ ផលុបភោគ លើអចលនវត្ថុហ៊ីប៉ូតែក ដោយបានសងថ្លៃលក់ទៅឱ្យម្ចាស់បំណុលហ៊ីប៉ូតែក តាមរយៈការទាមទាររបស់ម្ចាស់បំណុលហ៊ីប៉ូតែកនោះ ដូច្នេះ ហ៊ីប៉ូតែកត្រូវរលត់ចំពោះតតិយជន។ លើសពីនេះ ហ៊ីប៉ូតែកនឹងត្រូវរលត់ប្រសិនបើតតិយជនដែលបានធ្វើលទ្ធកម្មនូវអចលនវត្ថុហ៊ីប៉ូតែក សងថ្លៃលក់អចលនវត្ថុដែលខ្លួនត្រូវបង់ដើម្បីធ្វើលទ្ធកម្មនូវអចលនវត្ថុនោះ តាមការទាមទាររបស់ម្ចាស់បំណុលហ៊ីប៉ូតែក មានន័យថា ហ៊ីប៉ូតែក នឹងត្រូវរលត់ប្រសិនបើម្ចាស់បំណុលហ៊ីប៉ូតែកទាមទារឱ្យតតិយជនដែលបានធ្វើលទ្ធកម្ម នូវអចលនវត្ថុហ៊ីប៉ូតែក នោះសងថ្លៃលក់អចលនវត្ថុ ហើយតតិយជនដែលបានធ្វើលទ្ធកម្មនោះ ត្រូវសងថ្លៃលក់អចលនវត្ថុតាមការទាមទារ[70]។

## ៣.២. ការរលត់ដោយអាជ្ញាយុកាល

ហ៊ីប៉ូតែកមិនរលត់ដោយអាជ្ញាយុកាល ដែលមានលក្ខណៈឯករាជ្យពីសិទ្ធិលើបំណុល ដែលត្រូវបានធានាដោយហ៊ីប៉ូតែកនោះឡើយ។ ប្រសិនបើម្ចាស់បំណុលហ៊ីប៉ូតែក បានធ្វើនីតិវិធីផ្អាកអាជ្ញាយុកាលហ៊ីប៉ូតែកមិនរលត់ឡើយ។ នេះគឺជាបទប្បញ្ញត្តិដែលត្រូវបានបង្កើតឡើង សម្រាប់គ្រប់គ្រងស្ថានភាពដែលកូនបំណុលនៃសិទ្ធិលើបំណុលត្រូវធានា និង អ្នកបង្កើតហ៊ីប៉ូតែកជាបុគ្គលពីរផ្សេងគ្នា។

ហ៊ីប៉ូតែកត្រូវរលត់ ប្រសិនបើតតិយជនក្រៅពីកូនបំណុល ឬ អ្នកបង្កើតហ៊ីប៉ូតែកបានបំពេញលក្ខខណ្ឌនូវលទ្ធកម្មនៃកម្មសិទ្ធិចំពោះអចលនវត្ថុតាមរយៈអាជ្ញាយុកាល។ លទ្ធកម្មដោយអាជ្ញាយុកាលចំពោះអចលនវត្ថុមិនមែនជាលទ្ធកម្មបន្ត គឺជាលទ្ធកម្មដំបូង ហេតុនេះ វាគឺជាកម្មសិទ្ធិពេញលេញដែលគ្មានបន្ទុក។ ចំណែកលទ្ធកម្មបន្ត គឺជាលទ្ធកម្មតាមរយៈការលក់ទិញ ឬ ប្រទានកម្មជាអាទិ៍ ដូច្នេះ អ្នកទិញ គឺធ្វើលទ្ធកម្មបន្តចំពោះកម្មសិទ្ធិរបស់អ្នកលក់ជាអាទិ៍ នាំឱ្យប្រសិនបើដីនោះ

[70] មាត្រា៨៦៤ សេចក្តីកំណត់ចំពោះមាត្រានីមួយៗ ឆ្នាំ២០១០ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

មានបន្ទុកដូចជាហ៊ីប៉ូតែកជាអាទិ៍ អ្នកទិញនោះ គឺទិញដីដែលមានបន្ទុកហ៊ីប៉ូតែក។ មួយវិញទៀត ហ៊ីប៉ូតែក ជាសិទ្ធិប្រាតិភោគប្រត្យក្ស ដែលអាចតតាំងនឹងតតិយជនប្រសិនបើបានចុះបញ្ជី ទោះបីជាអ្នកទិញបានដឹង ឬ មិនបានដឹងក៏ដោយ ក៏លក្ខខណ្ឌតតាំងនៅតែមានសុពលភាពដែរ[71]។

ឧទាហរណ៍៖ ក ខ្ចីប្រាក់ពី ខ ដោយដាក់ហ៊ីប៉ូតែកលើអចលនវត្ថុ ដែលកាន់កាប់ដោយ គ ។ ប្រសិនបើ គ មិនដឹងថាអចលនវត្ថុនោះមានជាប់បន្ទុកហ៊ីប៉ូតែកហើយ គ បានបំពេញលក្ខខណ្ឌនៃការកាន់កាប់ដោយអាជ្ញាយុកាល តាមការកំណត់ក្នុងច្បាប់នោះ គ អាចធ្វើលទ្ធកម្មនៃកម្មសិទ្ធិលើអចលនវត្ថុនោះបាន ក្នុងករណីហ៊ីប៉ូតែកត្រូវរលត់។ ចំណែកឯលទ្ធកម្មបន្ត ដូចជា លទ្ធកម្មសិទ្ធិតាមរយៈការលក់ទិញ ប្រសិនបើអ្នកទិញបានទិញដីដែលមានជាប់បន្ទុក ហ៊ីប៉ូតែកអ្នកទិញនោះ អាចធ្វើលទ្ធកម្មកម្មសិទ្ធិដែលមានបន្ទុកហ៊ីប៉ូតែក។ ម៉្យាងទៀត ហ៊ីប៉ូតែកជា សិទ្ធិ ទោះបីជាយ៉ាងណាក៏ដោយ ប្រសិនបើបុគ្គលដែលបានធ្វើលទ្ធកម្មនៃកម្មសិទ្ធិចំពោះអចលនវត្ថុ ដែលជាកម្មសិទ្ធិនៃហ៊ីប៉ូតែក តាមរយៈអាជ្ញាយុកាល។

[71] មាត្រា៨៦៥ សេចក្តីកំណត់ចំពោះមាត្រានីមួយៗ ឆ្នាំ២០១០ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

# ជំពូកទី៣

# ការរៀបចំឯកសារ និងការចុះបញ្ជី

# អំពីការបង្កើតសិទ្ធិ

# លើហ៊ីប៉ូតែកជម្មតា

# ជំពូកទី៣
# ការរៀបចំឯកសារ និងការចុះបញ្ជីអំពីការបង្កើតសិទ្ធិលើហ៊ីប៉ូតែកធម្មតា

## ផ្នែកទី១. ការរៀបចំឯកសារនៅក្នុងការបង្កើតសិទ្ធិលើហ៊ីប៉ូតែក

រាល់ឯកសារទាំងអស់ដែលបានតាក់តែងឡើងត្រូវមានការដឹងឮ និងយល់ព្រមដោយមានផ្តិតមេដៃ និងចុះហត្ថលេខាភាគីដែលមាននៅក្នុងប្រតិបត្តិការនៃការបង្កើតហ៊ីប៉ូតែក។ ហើយការបង្កើតហ៊ីប៉ូតែកទាមទារឱ្យមានឯកសារមួយចំនួនជាចាំបាច់ទើបអាចបង្កើតបាន។ យើងបានដឹងរួចមកហើយថា ហ៊ីប៉ូតែកអាចបង្កើតបានលើ អចលនវត្ថុ សិទ្ធិជួលអចិន្ត្រៃយ៍ និងផលុបភោគតែប៉ុណ្ណោះ ដែលជាកម្មវត្ថុនៃការបង្កើតហ៊ីប៉ូតែក។ ដូច្នេះ នៅក្នុងជំពូកទី៣ នេះ យើងខ្ញុំនឹងលើកយក ២ ផ្នែក មកធ្វើការបកស្រាយ ( **ផ្នែកទី ១** ) ការរៀបចំឯកសារនៅក្នុងការបង្កើតសិទ្ធិលើហ៊ីប៉ូតែកធម្មតា និង ( **ផ្នែកទី២** ) ដំណាក់កាលនៃការចុះបញ្ជី។

## កថាភាគទី១. ហ៊ីប៉ូតែកលើកម្មសិទ្ធិ

### ១.១. កិច្ចសន្យាខ្ចីបរិភោគ

#### ១.១.១. និយមន័យ

ការខ្ចីបរិភាគ សំដៅទៅលើកិច្ចសន្យាដែលភាគីម្ខាងហៅថា " អ្នកឱ្យខ្ចី " មានករណីយកិច្ចប្រគល់ការប្រើប្រាស់ដោយសេរីនូវប្រាក់ ស្បៀងអាហារ ឬវត្ថុជំនួសផ្សេងទៀតក្នុងអំឡុងពេលដែលកំណត់ឱ្យទៅភាគីម្ខាងទៀតហៅថា " អ្នកខ្ចី " ហើយនៅក្រោយពេលដែលអំឡុងពេលនោះកន្លងផុតអ្នកខ្ចីមានករណីយកិច្ចសងទៅឱ្យអ្នកឱ្យខ្ចីវិញនូវវត្ថុដែលមានប្រភេទ គុណភាព និងចំនួនស្មើគ្នានឹងវត្ថុដែលបានទទួលពីអ្នកឱ្យខ្ចីនោះ។[72] ហើយកិច្ចសន្យាខ្ចីបរិភោគ អាចធ្វើឡើងដោយយកការប្រាក់ ឬ មិនយកការប្រាក់។ ហើយការប្រាក់ អាចជាទឹកប្រាក់ ឬវត្ថុផ្សេងទៀត ដែលត្រូវគណនាដោយយកចំនួនទឹកប្រាក់ ឬវត្ថុដែលបានខ្ចី ( ប្រាក់ដើម ) មកគុណជាមួយនឹង អត្រាដែលបានកំណត់ ( អត្រាការប្រាក់ ) តាមសមាមាត្រនឹងអំឡុងពេលដែលបានប្រើប្រាស់ ( រយៈពេលខ្ចី )។ ដើម្បីធ្វើឱ្យការបង់ប្រាក់ក្លាយទៅជាសិទ្ធិលើបំណុល ជាប្រយោជន៍ដល់អ្នកឱ្យខ្ចី។ លើសពីនេះទៅទៀត គូភាគីអាចព្រមព្រៀងកំណត់អត្រាការប្រាក់បានដោយសេរី ប៉ុន្តែមិនអាចលើសពីអត្រាការប្រាក់អតិបរិមាដែលកំណត់ដោយច្បាប់ ឬបទដ្ឋានគតិយុត្តផ្សេងទៀតឡើយ។ ប្រកាសចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ របស់

[72] មាត្រា ៥៧៨ ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

ក្រសួងយុត្តិធម៌ស្តីពីអត្រាការប្រាក់ដែលត្រូវបានកម្រិត កំណត់យកអត្រាការប្រាក់អតិបរមាត្រឹម ១៨% ក្នុងមួយឆ្នាំ[73]។ សរុបមកវិញ កិច្ចសន្យាខ្ចីបរិភោគ ជាកិច្ចសន្យាឯកជនរវាងកូនបំណុល និងម្ចាស់បំណុល ដែលកើតឡើងឡើងនៅពេលដែលមានប្រតិបត្តិការខ្ចីប្រាក់ ហើយទម្រង់នៃកិច្ចសន្យាមិនមានច្បាប់ ឬបទប្បញ្ញត្តិណាមួយកំណត់ជាក់លាក់អំពីទម្រង់នៃការតាក់តែងនោះទេ ដូច្នេះសាការីអាចធ្វើការតាក់តែងទៅតាមការអនុវត្តជាក់ស្តែង ដោយមិនផ្អែកអំពីច្បាប់។

### ១.១.២. ចំណុចដែលត្រូវសរសេរក្នុងកិច្ចសន្យាខ្ចីបរិភោគ

កិច្ចសន្យាខ្ចីបរិភោគ គឺជាកិច្ចសន្យាឯកជនរវាងម្ចាស់បំណុល និងកូនបំណុល។ នៅក្នុងការអនុវត្តទូទៅ មុននឹងមានការបង្កើតហ៊ីប៉ូតែក សិទ្ធិលើបំណុលចាំបាច់ត្រូវតែកើតមានរវាងម្ចាស់បំណុល និងកូនបំណុលជាមុនសិន។ ហើយសិទ្ធិលើបំណុលអាចត្រូវបានបង្កើតឡើងច្រើនរូបភាព ដែលភាគច្រើនយើងអាចមើលឃើញតាមរយៈការបង្កើតកិច្ចសន្យាខ្ចីបរិភោគ។ ហើយទម្រង់នៃកិច្ចសន្យាខ្ចីបរិភោគ មិនមានលិខិតបទដ្ឋានគតិយុត្តណាកំណត់អំពីទម្រង់នៃការតាក់តែងនូវកិច្ចសន្យានេះទេ ប៉ុន្តែតាមអនុវត្តជាក់ស្តែងកិច្ចសន្យានេះត្រូវបានតាក់តែង និងបានសរសេរតាមទម្រង់ដូចខាងក្រោម[74]៖

**១- ឈ្មោះ និងអាសយដ្ឋានរបស់ភាគីនៃកិច្ចសន្យា**

ក. កូនបំណុល

- ឬ អ្នកធានាដោយវត្ថុ

ខ. ម្ចាស់បំណុល

**២- សិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែករួម**

ក. ឈ្មោះ និងអាសយដ្ឋានរបស់កូនបំណុល

- ចំនួនប្រាក់ដើម ៖.........ដុល្លារអាមេរិក
- ការប្រាក់ ៖.........ក្នុងមួយឆ្នាំ

[73] ប្រកាស១ កាសលេខ ១២៨កយ.ប្រក/១១ ស្តីពីអត្រាការប្រាក់ដែលបានកំណត់ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១។
[74] សូមមើលគំរូ "កិច្ចសន្យាខ្ចីបរិភោគ", ឧបសម្ព័ន្ធទី២។

- សំណងការខូចខាត ៖.........ក្នុងមួយឆ្នាំ

- លក្ខខណ្ឌ

**៣- អត្តសញ្ញាណអចលនវត្ថុ ឬសិទ្ធិដែលជាកម្មវត្ថុនៃហ៊ីប៉ូតែករួម**

ក. ទីតាំងអចលនវត្ថុ

ខ. លេខក្បាលដី

គ. លេខវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ

ក. លេខក្បាលដី

ខ. លេខក្បាលដី

គ. លេខវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ

**៤- ឧបសន្យាផ្សេងទៀត**

## ១.២. កិច្ចសន្យាបង្កើតសិទ្ធិហ៊ីប៉ូតែក

### ១.២.១. និយមន័យ

កិច្ចសន្យាបង្កើតហ៊ីប៉ូតែក[75] នឹងត្រូវបានបង្កើតឡើងបន្ទាប់ពីមាន កិច្ចសន្យាខ្ចីបរិភោគ។ នៅពេលបង្កើតកិច្ចសន្យាខ្ចីបរិភោគរួចរាល់ ប្រសិនបើភាគីឯកភាពគ្នាក្នុងការយកទ្រព្យរបស់កូនបំណុលទៅដាក់ហ៊ីប៉ូតែក ដើម្បីធានាលើបំណុលនោះ គូភាគីត្រូវតែធ្វើកិច្ចសន្យាបង្កើតហ៊ីប៉ូតែក។ ហើយកិច្ចសន្យាបង្កើតហ៊ីប៉ូតែក មិនអាចយកទៅតតាំងបានឡើយជាមួយតតិយជនបានឡើយ បើមិនបានធ្វើឡើងជាទម្រង់លិខិតយថាភូត និងមិនបានចុះបញ្ជីនៅក្នុងសៀវភៅគោលបញ្ជីដីធ្លី។ លិខិតយថាភូតត្រង់ចំណុចនេះ មានន័យថា ជាកិច្ចសន្យាបង្កើតហ៊ីប៉ូតែកត្រូវបានបង្កើតឡើង និងមានបញ្ជាក់ដោយមន្ត្រីមានសមត្ថកិច្ច។ មន្ត្រីមានសមត្ថកិច្ចត្រង់ចំណុចនេះអាចជាមេឃុំ ឬចៅសង្កាត់ ឬជាសារការី។

[75] សូមមើលគំរូ "កិច្ចសន្យាបង្កើតហ៊ីប៉ូតែក" ឧបសម្ព័ន្ធទី៣។

### ១.២.២. ចំណុចដែលត្រូវសរសេរ

នៅពេលដែលបង្កើតកិច្ចសន្យាបង្កើតហ៊ីប៉ូតែក ទម្រង់នៃកិច្ចសន្យាត្រូវសរសេរនូវចំណុចដែលមានដូចខាងក្រោម៖

ម្ចាស់បំណុលហ៊ីប៉ូតែក៖ អត្តសញ្ញាណ.......

អ្នកបង្កើតហ៊ីប៉ូតែក៖ អត្តសញ្ញាណ.......

ក- កម្មវត្ថុនៃកិច្ចសន្យា៖ បង្កើតហ៊ីប៉ូតែកលើអចលនវត្ថុ ទំហំនៃសិទ្ធិលើបំណុលគឺ ប្រាក់ដើម ការប្រាក់សំណងនៃការខូចខាតជាអាទិ៍

ខ- ការធានាអះអាង ៖ អចលនវត្ថុនេះគឺជាកម្មសិទ្ធិរបស់អ្នកបង្កើត

គ- ខសន្យាពិសេស ៖ អ្នកបង្កើតមិនលក់អចលនវត្ថុនេះ ក្នុងអំឡុងពេលនេះទេ ជាអាទិ៍

ឃ- បទប្បញ្ញត្តិរួម ៖ ភាគីទាំងពីរត្រូវអនុវត្តកិច្ចសន្យានេះដោយសុចរិត និងស្មោះត្រង់

ហត្ថលេខាម្ចាស់បំណុលសេចក្ដីបញ្ជាក់មេឃុំ-ចៅសង្កាត់ ហត្ថលេខាកូនបំណុល

## ១.៣. ពាក្យសុំចុះបញ្ជីអំពីការបង្កើតហ៊ីប៉ូតែក

បន្ទាប់ពីបានរៀបចំកិច្ចសន្យាបង្កើតហ៊ីប៉ូតែកជាទម្រង់យថាភូតរួចរាល់ ជំហានបន្ទាប់គឺត្រូវរៀបចំពាក្យសុំចុះបញ្ជីអំពីការបង្កើតហ៊ីប៉ូតែក ដើម្បីស្នើសុំចុះបញ្ជីទៅរដ្ឋបាលសុរិយោដី។ ហើយពាក្យសុំចុះបញ្ជីត្រូវធ្វើឡើងរួមគ្នាដោយបុគ្គលមានសិទ្ធិចុះបញ្ជី និងបុគ្គលមានកាតព្វកិច្ចចុះបញ្ជី។ ពាក្យសុំចុះបញ្ជីហ៊ីប៉ូតែក អំពីការបង្កើតហ៊ីប៉ូតែកធម្មតា មានកំណត់នៅក្នុងប្រកាសអន្តរក្រសួងរវាងក្រសួងយុត្តិធម៌ និងក្រសួងដែនដីនគររូបនីយកម្ម និងសំណង់ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ ២០១៣ ស្ដីពីនីតិវិធីនៃការចុះបញ្ជីសិទ្ធិប្រត្យក្សទាក់ទងនឹងក្រមរដ្ឋប្បវេណី។

មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយាដី បានកំណត់នូវទម្រង់លិខិតរដ្ឋបាលជាក់លាក់មួយនៃ "ពាក្យសុំចុះបញ្ជីអំពីការបង្កើតហ៊ីប៉ូតែក" ដោយអ្នកបង្កើតហ៊ីប៉ូតែកអាច ស្នើសុំសម្រាប់ការចុះបញ្ជីអំពីការបង្កើតហ៊ីប៉ូតែករបស់ខ្លួនទៅកាន់មន្ទីរសុរិយាដី ដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

### ១.៣.១. ទម្រង់នៃពាក្យសុំចុះបញ្ជី

ទម្រង់នៃពាក្យសុំចុះបញ្ជីអំពីការបង្កើតហ៊ីប៉ូតែក មានកំណត់នៅក្នុងប្រកាសអន្តរក្រសួងរវាងក្រសួងយុត្តិធម៌ និងក្រសួងដែនដីនគររូបនីយកម្ម និងសំណង់ នៅទំព័រ ១០៧ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៣ ស្តីពីនីតិវិធីនៃការចុះបញ្ជីសិទ្ធិប្រត្យក្សទាក់ទងនឹងក្រមរដ្ឋប្បវេណី។

### ១.៣.២. ចំណុចដែលត្រូវសរសេរ

នៅពេលបង្កើតហ៊ីប៉ូតែក ពាក្យសុំចុះបញ្ជីអំពីការបង្កើតហ៊ីប៉ូតែក[76] ត្រូវសរសេរនូវចំណុចដែលមានដូចខាងក្រោម៖

- បុគ្គលមានសិទ្ធិទាមទារឱ្យចុះបញ្ជី (ម្ចាស់បំណុលហ៊ីប៉ូតែក) អត្តសញ្ញាណ
- អ្នកមានកាតព្វកិច្ចចុះបញ្ជី (អ្នកបង្កើតហ៊ីប៉ូតែក) អត្តសញ្ញាណ

**ក- គោលបំណងណាមួយដូចខាងក្រោម៖**

- ការបង្កើតហ៊ីប៉ូតែកលើកម្មសិទ្ធិ
- ការបង្កើតហ៊ីប៉ូតែកលើសិទ្ធិជួលអចិន្ត្រៃយ៍
- ការបង្កើតហ៊ីប៉ូតែកលើផលុបភោគ

**ខ- មូលហេតុ និងការបរិច្ឆេទណាមួយដូចខាងក្រោម**

ខ-១ - កិច្ចសន្យាខ្ចីបរិភោគ

- មូលហេតុផ្សេងទៀតដែលមានចែងនៅក្នុងច្បាប់ ឬ បទដ្ឋានគតិយុត្តផ្សេងទៀត។

ខ-២ - កិច្ចសន្យាបង្កើតហ៊ីប៉ូតែក

**គ- បុគ្គលមានសិទ្ធិចុះបញ្ជី**

- ឈ្មោះ
- ថ្ងៃ ខែ ឆ្នាំកំណើត និងទីកន្លែងកំណើត
- អាសយដ្ឋាន

[76] សូមមើលគំរូ "ពាក្យសុំចុះបញ្ជីអំពីការបង្កើតហ៊ីប៉ូតែក", ឧបសម្ព័ន្ធទី៤។

- ឈ្មោះឪពុក និងឈ្មោះម្តាយ

**- បុគ្គលមានកាតព្វកិច្ចចុះបញ្ជី**

- ឈ្មោះ
- ថ្ងៃ ខែ ឆ្នាំកំណើត និងទីកន្លែងកំណើត
- អាសយដ្ឋាន
- ឈ្មោះឪពុក និងឈ្មោះម្តាយ

**ឃ- ចំណុចផ្សេងទៀតដែលត្រូវចុះបញ្ជី**

- ឈ្មោះកូនបំណុល
- ចំនួនប្រាក់ដើម
- ការប្រាក់
- សំណងការខូចខាត
- លក្ខខណ្ឌភ្ជាប់នឹងសិទ្ធិលើបំណុលដែលត្រូវបានធានា ( ប្រសិនបើមាន )

**ង- អត្តសញ្ញាណនៃអចលនវត្ថុ**

- ទីតាំងដី

-លេខក្បាលដី ឬ លេខប័ណ្ណ

ឯកសារភ្ជាប់៖ ដូចមានចែងក្នុងប្រការ ២៧.[77]

## ១.៤. ឯកសារភ្ជាប់សម្រាប់ការចុះបញ្ជី

ឯកសារភ្ជាប់នេះគឺជា ឯកសារបន្ទាប់បន្សំដើម្បីបំពេញលក្ខខណ្ឌរបស់រដ្ឋបាលសុរិយោដី ក្នុងការត្រួតពិនិត្យទៅលើអត្តសញ្ញាណរបស់ភាគីដែលស្នើសុំក្នុងការបង្កើតហ៊ីប៉ូតែក។ ម្យ៉ាងទៀត បុគ្គលដែលមានកាតព្វកិច្ចក្នុងការបង្កើតហ៊ីប៉ូតែកអាចជារូបវន្តបុគ្គល ឬនីតិបុគ្គល ដូចនេះឯកសារភ្ជាប់មានលក្ខណៈខុសគ្នាក្នុងការចុះបញ្ជី។

[77] ប្រការ ២៧ ប្រកាសអន្តរក្រសួងស្តីពី "នីតិវិធីនៃការចុះបញ្ជីអំពីសិទ្ធិប្រក្យក្សទាក់ទងនិងក្រមរដ្ឋប្បវេណី"។

**ក ករណីភាគីនៃអ្នកបង្កើតជារូបវន្តបុគ្គល**

១. ពាក្យសុំចុះបញ្ជីអំពីការបង្កើតហ៊ីប៉ូតែក

២. កិច្ចសន្យាខ្ចីបរិភោគ

៣. ប័ណ្ណកម្មសិទ្ធិអចលនវត្ថុ

៤. អត្តសញ្ញាណប័ណ្ណ៖ កូនបំណុល ។

**ខ ករណីភាគីនៃអ្នកបង្កើតជានីតិបុគ្គល**

១. ពាក្យសុំចុះបញ្ជីអំពីការបង្កើតហ៊ីប៉ូតែក

២. កិច្ចសន្យាខ្ចីបរិភោគ

៣. កិច្ចសន្យាបង្កើតហ៊ីប៉ូតែក

៤. ប័ណ្ណកម្មសិទ្ធិអចលនវត្ថុ

៥. អត្តសញ្ញាណប័ណ្ណ៖ កូនបំណុល និងអ្នកធានាដោយវត្ថុ

៦. លក្ខន្តិកៈក្រុមហ៊ុន

៧. ប័ណ្ណប៉ាតង់

៨. វិញ្ញាបនបត្រចុះបញ្ជីក្រសួងពាណិជ្ជកម្ម

៩. សេចក្តីសម្រេចរបស់ម្ចាស់ភាគហ៊ុន។

បន្ទាប់ពីរៀបចំឯកសារទាំងអស់នេះរួច យើងអាចបន្តនីតិវិធីនៃការចុះបញ្ជីអំពីការបង្កើតហ៊ីប៉ូតែក នៅរដ្ឋបាលសុរិយោដីនៃទីតាំងអចលនវត្ថុសម្រាប់ដាក់ហ៊ីប៉ូតែកនីមួយៗ។

## ផ្នែកទី២. ដំណាក់កាលនៃការចុះបញ្ជី

ពិតណាស់ ហ៊ីប៉ូតែកត្រូវបានបង្កើតឡើងតាមរយៈការព្រមព្រៀង និងធ្វើឡើងដោយលិខិតយថាភូត ប៉ុន្តែទាក់ទងនឹងការតតាំងចំពោះតតិយជនក្នុងក្រមរដ្ឋប្បវេណី សង្កត់ធ្ងន់ទៅលើការចុះបញ្ជីអំពីហ៊ីប៉ូតែកនៅក្នុងសៀវភៅគោលបញ្ជីដីធ្លី។ ការចុះបញ្ជីហ៊ីប៉ូតែក គឺពិតជាបានផ្តល់នូវអត្ថប្រយោជន៍ជាខ្លាំង ពីព្រោះហ៊ីប៉ូតែក គឺជាសិទ្ធិប្រត្យក្សអរូបិយ ( មិនអាចវាយតម្លៃពីខាងក្រៅបាន )

ដែលគ្រប់គ្រងតែទៅលើតម្លៃនៃកម្មវត្ថុតែប៉ុណ្ណោះ។ ហេតុដូច្នេះ ក្រមរដ្ឋប្បវេណី កំណត់យក ត្រឹម អចលនវត្ថុ សិទ្ធិជួលអចិន្ត្រៃយ៍ និងផលុបភោគ មកធ្វើជាកម្មវត្ថុនៃហ៊ីប៉ូតែកដូចមានកំណត់នៅក្នុងច្បាប់ ដែលមានប្រកាសជាសាធារណៈនៅក្នុងសៀវភៅបញ្ជី។

## កថាភាគទី១. ដំណាក់កាលព្រមព្រៀងជាលាយលក្ខណ៍អក្សរ

នៅពេលដែលគូភាគីបានរៀបចំឯកសារកិច្ចសន្យាដូចបានរៀបរាប់ខាងលើរួចរាល់ គូភាគីដែលបានព្រមព្រៀងរួចហើយត្រូវផ្តិតស្នាមម្រាមដៃនៅលើកិច្ចសន្យានេះឱ្យបានត្រឹមត្រូវ ដែលការព្រមព្រៀងត្រូវបានធ្វើឡើងជាលាយលក្ខណ៍អក្សរតាមរយៈ កិច្ចសន្យាខ្ចីបរិភោគ កិច្ចសន្យាបង្កើតហ៊ីប៉ូតែក និងពាក្យសុំចុះបញ្ជីអំពីការបង្កើតហ៊ីប៉ូតែក ដើម្បីបញ្ជាក់ពីការព្រមព្រៀងរបស់ខ្លួន។ ហើយឯកសារដែលត្រូវភ្ជាប់មកជាមួយក្នុងការចុះបញ្ជីក៏មានភាពខុសគ្នាផងដែរ ព្រោះថា បុគ្គលដែលមានកាតព្វកិច្ចក្នុងការបង្កើតហ៊ីប៉ូតែកអាចជារូបវន្តបុគ្គល ឬនីតិបុគ្គល ។ ក្នុងករណី មានគូភាគីណាម្នាក់ជានីតិបុគ្គល គឺតម្រូវឱ្យមានហត្ថលេខារបស់អ្នកតំណាង និងប្រថាប់ត្រារបស់នីតិបុគ្គលនោះផងដែរ។ ជាទូទៅ មេធាវីអាចធ្វើការរៀបចំកិច្ចសន្យា ចុះហត្ថលេខា និងប្រថាប់ត្រា ក្នុងនាមជាសាក្សីរបស់គូភាគីផងដែរ តែមិនមែនមានន័យថា ការណ៍នេះធ្វើឱ្យកិច្ចសន្យាក្លាយជាទៅជាលិខិតយថាភូតដែលជាលក្ខខណ្ឌតតាំងនោះទេ។ សម្រាប់ពាក្យសុំចុះបញ្ជីវិញ គឺតម្រូវឱ្យមានចុះហត្ថលេខា ឬផ្តិតស្នាមមេដៃរួមគ្នារវាង បុគ្គលដែលមានកាតព្វកិច្ចចុះបញ្ជី និងបុគ្គលដែលមានសិទ្ធិចុះបញ្ជីប៉ុណ្ណោះ។

## កថាភាគទី២. ការបញ្ជាក់ពីភាពត្រឹមត្រូវនៃកិច្ចសន្យា

បន្ទាប់ពីបានរៀបចំកិច្ចសន្យា និងការភ្ជាប់ឯកសារបានគ្រប់ចំនួនកំណត់ហើយ គូភាគីនៃកិច្ចសន្យា ត្រូវស្នើសុំហត្ថលេខា និងត្រារបស់ចៅសង្កាត់-មេឃុំ នឹងពិនិត្យទៅលើភាពស្របច្បាប់របស់កម្មសិទ្ធិករ និងត្រួតពិនិត្យពីស្ថានភាពនៃអចលនវត្ថុនោះ ដោយពិនិត្យទៅលើប្រវត្តិដីធ្លីនោះដូចជាមានការជាប់បន្ទុកបញ្ចាំ ឬហ៊ីប៉ូតែកពីមុនមក ឬក៏មានជាប់ក្នុងពាក្យបណ្តឹង ឬដីការក្សាការពារជាដើម។ បើគ្មានពាក់ព័ន្ធនឹងបញ្ហាណាមួយទេ ចៅសង្កាត់នឹងចុះហត្ថលេខា និងប្រថាប់ត្រារបស់សង្កាត់ ដោយមានចុះលេខបញ្ជាក់ ដើម្បីឱ្យកិច្ចសន្យានេះក្លាយទៅជាលិខិតយថាភូតពេញលេញតាមផ្លូវច្បាប់តែម្តង។ បច្ចុប្បន្ន សិទ្ធិអំណាច ក្នុងនាមជាមន្ត្រីមានសមត្ថកិច្ចនេះក៏ត្រូវបានផ្តល់ជូនសារការី ដើម្បីចុះហត្ថលេខា និងប្រថាប់ត្រាលើកិច្ចសន្យារបស់គូភាគី។

## កថាភាគទី៣. ដំណាក់កាលនៅរដ្ឋបាលសុរិយោដី

កិច្ចសន្យាដែលមានទម្រង់ជាលិខិតយថាភូតរួចហើយ គឺត្រូវយកទៅធ្វើការដាក់ពាក្យស្នើសុំចុះបញ្ជីនៅរដ្ឋបាលសុរិយោដី ដែលមានទីតាំងស្ថិតនៅក្នុងមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីថ្នាក់រាជធានី-ខេត្ត ដែលអចលនវត្ថុនោះតាំងនៅ។ ក្នុងការដាក់ពាក្យស្នើសុំនេះ ឯកសារត្រូវតែរៀបចំឱ្យបានគ្រប់ចំនួន និងត្រឹមត្រូវតាមបទដ្ឋានគតិយុត្ត។ មន្ត្រីទទួលបន្ទុកនឹងធ្វើការផ្ទៀងផ្ទាត់ឯកសារ ហើយធ្វើការចុះបញ្ជីចូលក្នុងសៀវភៅគោលបញ្ជីដីធ្លី ត្រង់ខ្ទង់ "បន្ទុកលើអចលនវត្ថុ" និងបោះត្រាលេខាចារឹកនៅខាងក្រោយ វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ឬប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ដីធ្លី ដោយបញ្ជាក់ពី ឈ្មោះរបស់គូភាគី ឱ្យបានច្បាស់លាស់ ប្រាក់ដើម ការប្រាក់ ( គិតជា% ) សំណងការខូចខាត ( គិតជា% ) លក្ខខណ្ឌភ្ជាប់សិទ្ធិលើបំណុលដែលត្រូវបានធានាតាមកិច្ចសន្យា និងកាលបរិច្ឆេទនៃកិច្ចសន្យាជាទឹកខៀវ ឬទឹកខ្មៅ ហើយបោះត្រាលេខាចារឹក និងចុះកាលបរិច្ឆេទនៃការចុះបញ្ជីជាទឹកក្រហម។ មន្ត្រីដែលទទួលបន្ទុកលើកិច្ចការចុះបញ្ជី ត្រូវប្រគល់ប័ណ្ណកម្មសិទ្ធិដែលមានចុះលេខាចារឹកហើយនេះទៅកាន់ម្ចាស់អចលនវត្ថុវិញ បន្ទាប់ពីចុះបញ្ជីរួចរាល់[78]។

[78] ម៉ៅសិលា "ជំនួយស្មារតី៖ និយមន័យ និងការចុះបញ្ជីហ៊ីប៉ូតែកនៅកម្ពុជា",ការផ្សព្វផ្សាយរបស់សមាគមសាលាត្រាជូ ខែមករា ឆ្នាំ២០១៨ http://salatraju.com/post/349 ទំព័រ៥។

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ឆ្លងតាមការបកស្រាយខាងលើ បន្ទាប់ពីបានធ្វើការសិក្សាយ៉ាងក្បោះក្បាយទៅលើប្រធានបទសារណាបញ្ចប់ការសិក្សាឆ្នាំ២០២២ ខាងមុខនេះ ក្រោមចំណងជើងថា "ហ៊ីប៉ូតែកជម្មតា" ។ ក្រុមយើងខ្ញុំបានសង្កេតឃើញថា ហ៊ីប៉ូតែក ពិតជាមានសារៈសំខាន់ណាស់នាពេលបច្ចុប្បន្ន។ ហ៊ីប៉ូតែកបានបង្ហាញឱ្យឃើញថាវាជាវិធីសាស្ត្រមួយដ៏ប្រសើរដែលមនុស្សអាចយកវាទៅប្រើប្រាស់ក្នុងវិស័យពាណិជ្ជកម្ម ដូចជាការពង្រីកអាជីវកម្ម ជួញដូរ ជំនួញ ការខ្ចីឥណទានជាដើម និងការយល់ដឹងទៅលើផ្នែករដ្ឋប្បវេណីដូចជា កាតព្វកិច្ច និងការទទួលខុសត្រូវនានារបស់អ្នកបង្កើតហ៊ីប៉ូតែក និងម្ចាស់បំណុលហ៊ីប៉ូតែកផងដែរ។

តាមរយៈការស្វែងយល់អំពីប្រធានបទនេះ ក្រុមពួកខ្ញុំសង្កេតឃើញថា មិនមែនរាល់អចលនវត្ថុទាំងអស់សុទ្ធតែអាចចុះបញ្ជីហ៊ីប៉ូតែកបាននោះទេ ដែលក្នុងនោះបានបញ្ជាក់យ៉ាងច្បាស់ថាទាល់តែអចលនវត្ថុដែលបានចុះបញ្ជីស្របច្បាប់ចេញដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងបានបំពេញនីតិវិធីចុះបញ្ជីហ៊ីប៉ូតែកទើបអាចអនុវត្តហ៊ីប៉ូតែកបាននិងអាចតតាំងជាមួយតតិយជន។ ដោយសារតែការចុះបញ្ជីនេះហើយ ទើបបង្ហាញឱ្យកាន់តែច្បាស់ទៀតថា ការដាក់ធានាកាតព្វកិច្ចតាមរយៈសិទ្ធិប្រាតិភោគប្រត្យក្សមួយនេះមានលក្ខណៈជាបទដ្ឋានគតិយុត្តដែលបានបង្កើតនូវចំណងគតិយុត្តរវាងអ្នកបង្កើតហ៊ីប៉ូតែក និងម្ចាស់បំណុលហ៊ីប៉ូតែកដែលនាំឱ្យមានភាពងាយស្រួលដល់ដំណើរការនៃការតតាំងរវាងគូភាគី ឬតតិយជនដែលបានធ្វើលទ្ធកម្មលើអចលនវត្ថុហ៊ីប៉ូតែកនោះ។ អ្វីដែលកាន់តែពិសេសពីការសិក្សាលើប្រធានបទសារណាមួយនេះ គឺបានឆ្លុះបញ្ចាំងឱ្យយើងបានឃើញនិងស្វែងយល់ទៅលើការអនុវត្តច្បាប់ យុត្តិសាស្ត្រ និងការប្រព្រឹត្តទៅនៃការចុះបញ្ជីហ៊ីប៉ូតែកជាដើម បច្ចុប្បន្នប្រជាពលរដ្ឋមួយចំនួនតូចពុំទាន់បានដឹងនិងយល់ច្បាស់នៅឡើយទៅលើអ្វីជាហ៊ីប៉ូតែក ហើយការអនុវត្តហ៊ីប៉ូតែកនេះមានលក្ខខណ្ឌបែបណាខ្លះ ផ្ទុយទៅវិញ យើងឃើញថាប្រជាជនភាគច្រើនបានប្រើប្រាស់វាយ៉ាងទូលំទូលាយលើកត្តានានាជាច្រើនដូចជាការខ្ចីឥណទានពីធនាគារ ឬមីក្រូហិរញ្ញវត្ថុជាដើម។

ជារួមយើងឃើញថា ហ៊ីប៉ូតែក គឺជាសិទ្ធិប្រាតិភោគប្រត្យក្សមួយដែលបានផ្តល់ផលប្រយោជន៍ទៅដល់គូភាគីទាំងសងខាងក្នុងកិច្ចសន្យា ទាំងម្ចាស់បំណុល និងកូនបំណុល។ សម្រាប់កិច្ចគតិ

យុត្តពាក់ព័ន្ធនឹងការចុះបញ្ជីបង្កើតសិទ្ធិក៏ដូចជាដំណើរការអនុវត្ត ការចាត់ចែង ការរលត់ ព្រមទាំងអានុភាពនៃហីប៉ូតែកធម្មតាដែលសុទ្ធសឹងជាគោលការណ៍ មានចែងក្នុងបញ្ញត្តិច្បាប់របស់កម្ពុជាដែលតម្រូវឱ្យបុគ្គលដែលមានកាតព្វកិច្ចក្នុងការអនុវត្តត្រូវបំពេញនូវកិច្ចគតិយុត្តខាងលើឱ្យបានពេញលេញ និងត្រូវត្រឹមទើបធានាបាននូវការការពារសិទ្ធិរបស់ខ្លួនស្របតាមវិធានច្បាប់បាន។

# អនុសាសន៍

# អនុសាសន៍

ជាចុងក្រោយ ក្នុងនាមជាអ្នករៀបចំ និងតាក់តែងនូវសារណាដែលពាក់ព័ន្ធនឹងហ៊ីប៉ូតែក ធម្មតានេះ ក្រុមរបស់យើងខ្ញុំបានសង្កេតឃើញពីភាពរីកចម្រើន និងការទទួលបានអត្ថប្រយោជន៍ដ៏សម្បូរបែបពីការដាក់ធានាកាតព្វកិច្ចតាមរយៈហ៊ីប៉ូតែកនេះ តួយ៉ាងហ៊ីប៉ូតែក ជាសិទ្ធិប្រត្យក្សមួយប្រភេទដែលបានផ្តល់ប្រយោជន៍ទៅដល់គូភាគីទាំងសងខាងនៅក្នុងកិច្ចសន្យា ទាំងម្ចាស់បំណុល និងកូនបំណុល។ ជាសំណូមពររបស់យើងខ្ញុំទាំងពីរ ឆ្លងតាមរយៈការស្រាវជ្រាវរបស់ពេលជាច្រើនខែកន្លងមក បញ្ហាដែលពួកខ្ញុំជួបប្រទះ ឃើញថា៖

១. បញ្ហាប្រឈមពាក់ព័ន្ធនឹងការបង្កើតកិច្ចសន្យាហ៊ីប៉ូតែក វាមានលក្ខខណ្ឌតឹងរឹងពេកដែលទាមទារឱ្យធ្វើជាលិខិតយថាភូត ដែលរៀបចំឡើងដោយសាការីជាដើម ហើយចំពោះនីតិវិធីនៃការចុះបញ្ជីហ៊ីប៉ូតែកហាក់នៅមានភាពស្មុគស្មាញនៅឡើយ។

២. ទាក់ទងទៅនឹងកម្មវត្ថុនៃការធានា កាតព្វកិច្ចនោះ នៅស្រុកយើងការចុះបញ្ជីដីធ្លីអត់ទាន់បានអស់នៅឡើយទេ ដែលប្រជាពលរដ្ឋខ្លះមានត្រឹមតែ លិខិតផ្ទេរសិទ្ធិ ហៅប្លង់ទន់ ក្រៅពីនេះគឺ ប្លង់រឹង ដែលជាវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ សម្គាល់សិទ្ធិប្រើប្រាស់ កាន់កាប់ដីធ្លី គឺមានភាគតិច ហើយធ្វើឱ្យការចុះបញ្ជីនឹងវាពិបាកក្នុងការធ្វើទៅរួច ។ ហើយសព្វថ្ងៃនេះ គេអនុញ្ញាតតែចំពោះដីដែលមានប័ណ្ណតែប៉ុណ្ណោះ ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ ឬ ក៏វិញ្ញាបនបត្រសម្គាល់សិទ្ធិកាន់កាប់ម្ចាស់អចលនវត្ថុ ព្រោះវាអាចតតាំងជាមួយតតិយជនបាន នៅពេលដែលចុះបន្ទុកទៅលើដីនឹង ស្មើនឹងប្រកាសផ្សាយជាសាធារណៈឱ្យអ្នកផ្សេងបានដឹងថា ខ្ញុំមានសិទ្ធិលើដីនឹងហើយ។

៣. ទោះបីជាច្បាប់យើងបានចែងពីលក្ខខណ្ឌតតាំងចំពោះតតិយជន និងអានុភាពទាមទារសំណង ពេលធ្វើការបែងចែកចំណែកក៏ពិតមែន ប៉ុន្តែចំពោះការអនុវត្តជាក់ស្តែងវិញ យើងឃើញថាការបង្កើតកិច្ចសន្យាហ៊ីប៉ូតែក ព្រមជាមួយការទទួលយកលិខិតផ្ទេរសិទ្ធិ មកទុកនៅម្ចាស់បំណុលដែលនេះជាអ្វីដែលខុសពីអត្ថន័យនៃហ៊ីប៉ូតែក។

៤. លើសពីនេះទៅទៀត គួរតែមានការផ្សព្វផ្សាយអំពីហ៊ីប៉ូតែក ជាពិសេសទាក់ទងជាមួយនឹងការចុះបញ្ជី ឱ្យមានភាពទូលំទូលាយ ដើម្បីឱ្យសាធារណជនបានយល់ដឹងអំពីនីតិវិធី ក៏ដូចជា

ដំណើរការនៃការចុះបញ្ជីឱ្យបានត្រឹមត្រូវ និងបានដឹងថាស្ថាប័នណាដែលមានសមត្ថកិច្ចទាក់ទងនឹងនីតិវិធីនេះ។

ជាចុងបញ្ចប់ យើងខ្ញុំទាំងពីរដែលជាយុវជនជំនាន់ក្រោយ សង្ឃឹមថា សំណូមពរទាំងបួនខាងលើនេះនឹងអាចជួយដល់ការអនុវត្ត និងប្រព្រឹត្តិទៅនៃការដាក់ធានាកាតព្វកិច្ចតាមរយៈហ៊ីប៉ូតែកនៅក្នុងប្រទេសកម្ពុជា យើងឱ្យកាន់តែល្អប្រសើរ និងមានប្រសិទ្ធិភាព។

# បញ្ជីឯកសារយោង

# បញ្ជីឯកសារយោង

## ១ លិខិតបទដ្ឋានគតិយុត្ត


- ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា លេខ នស/រកម/១២០៧/០៣០, ថ្ងៃទី ខែ ឆ្នាំ ២០០៧។
- ប្រកាសលេខ ១២៨កយ.ប្រក/១១ ស្តីពីអត្រាការប្រាក់ដែលបានកំណត់ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១។
- ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី លេខ នស/រកម/០៥១១/០០៧, ៣១ ឧសភា ២០០៩។
- ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ លេខ នស/រកម/០៧០៦/០២១, ថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦។
- ប្រកាសអន្តរក្រសួងលេខ ៣០កយជនស.ប្រក/១៣ ស្តីពីនិតិវិធីនៃការចុះបញ្ជីអំពីសិទ្ធិប្រត្យក្សទាក់ទងនឹងក្រមរដ្ឋប្បវេណី ចុះថ្ងៃទី ២៩ ខែមករា ឆ្នាំ២០១៣។


## ២ សៀវភៅដែលបានបោះពុម្ពផ្សាយ


- ក្រសួងយុត្តិធម៌, សេចក្តីកំណត់ចំពោះមាត្រានីមួយៗ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០១០, ភាគ៥ គន្លីទី៧។
- មេធាវី អ៊ូរ អេឡែន ,"ជំពូកទី១ ៖ សញ្ញាណទូទៅនៃការបង្កើតហ៊ីប៉ូតែកនៅកម្ពុជា ", ការផ្សព្វផ្សាយរបស់ការិយាល័យមេធាវីអេឡែន & អាសូស៊ីអេត, ខែវិច្ឆិកា ឆ្នាំ២០១៧, ទំព័រ ១១, ថ្ងៃ១៧ ខែមិថុនា ឆ្នាំ២០២១។
- នីតិរដ្ឋប្បវេណី ( មេរៀនសង្ខេប ) បង្រៀនដោយសាស្ត្រាចារ្យ៖ អ៊ីវ ប៉ូលី។


## ៣ ឯកសារដកស្រង់ចេញពី វែបសាយនានា


- ម៉ៅសិលា,"ជំនួយស្មារតី៖ និយមន័យ និងការចុះបញ្ជីហ៊ីប៉ូតែកនៅកម្ពុជា",ការផ្សព្វផ្សាយរបស់សមាគមសាលាត្រាជូ, ខែមករា ឆ្នាំ២០១៨, http://salatraju.com/post/349 , ទំព័រ៥, ថ្ងៃ២០ ខែកក្កដា ឆ្នាំ២០២២។

- ដកស្រង់សម្ដីរបស់លោកមេធាវី មួន សៀងលី តាមរយៈបទសម្ភាសន៍ ក្រោមប្រធានបទនិយាយអំពី ហ៊ីប៉ូតែក។
- "សញ្ញាណទូទៅនៃហ៊ីប៉ូតែក", រៀបរៀងដោយក្រុមការងារ៖ The Share , ខែមករា ឆ្នាំ ២០១៨, ទំព័រ ៣,។
- ដកស្រង់ចេញពីគេហទំព័រ CONSTRUCTION PROPERTY ផ្នែកព័ត៌មានអចលនទ្រព្យ https://construction-property.com/km/hypotec-in-cambodia-under-the-civil-code/។

# បញ្ជីឧបសម្ព័ន្ធ

# បញ្ជីឧបសម្ព័ន្ធ

| | |
|---|---|
| **ឧបសម្ព័ន្ធ១ ៖** | គំរូ ប័ណ្ណសម្គាល់កម្មសិទ្ធិ។ ( ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ, វិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុ, ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី ឬ វិញ្ញាបនបត្រសម្គាល់ម្ចាស់ចំណែកឯកជន )។ |
| **ឧបសម្ព័ន្ធ២ ៖** | គំរូ កិច្ចសន្យាខ្ចីបរិភោគ។ |
| **ឧបសម្ព័ន្ធ៣ ៖** | គំរូ កិច្ចសន្យាបង្កើតហ៊ីប៉ូតែក។ |
| **ឧបសម្ព័ន្ធ៤ ៖** | គំរូ ពាក្យសុំចុះបញ្ជីអំពីការបង្កើតហ៊ីប៉ូតែក។ |
| **ឧបសម្ព័ន្ធ៥ ៖** | ប្រកាសលេខ ១២៨កយ.ប្រក/១១ ស្ដីពីអត្រាការប្រាក់ដែលបានកំណត់ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១។ |

# ឧបសម្ព័ន្ធ១

**ឧបសម្ព័ន្ធ១.ក**

ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ

## 2- ឈ្មោះហៅក្រៅ ប្លង់ដាច់ដោយដុំ (ខាងមុខ)



ក្រដាសពុម្ពលេខ.៥

ឈ្មោះដី :............ ឈ្មោះភូមិ.ពោធិ៍ធំ...........

ព្រំប្រទល់ :

ខាងជើង :..............

ខាងត្បូង :..............

ខាងកើត :..............

ខាងលិច :..............

..........,ថ្ងៃទី..29......ខែ..........ឆ្នាំ.2007.....

ប្រធានការិយាល័យ រៀបចំដែនដី នគរូបនីយកម្ម សំណង់ និង ភូមិបាល.

COPY

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ

លេខ : ក.ណ 013807

ឃុំ-សង្កាត់ :..............

ស្រុក-ខណ្ឌ :..............

ខេត្ត-ក្រុង :..............

ភ្នំពេញ ,ថ្ងៃទី..24..ខែ..........ឆ្នាំ..2007......

ក.ប គេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់

## 2- ឈ្មោះហៅក្រៅ ប្លង់ដាច់ដោយដុំ (ខាងក្រោយ)



លេខ : J 0211

COPY

អក្សរសញ្ញាខ្ទង់ F

| កិនភាគក្បាលដី | | | | អត្តសញ្ញាណអ្នកកាន់កាប់ | | | | ការផ្លាស់ប្ដូរ | | លេខរៀងរៀង |
|---|---|---|---|---|---|---|---|---|---|---|
| ប្រភេទដី | ទំហំ | | | នាមត្រកូល និងនាមខ្លួន ទាំងប្ដី ប្រពន្ធ | ថ្ងៃ ខែ ឆ្នាំ និងស្រុកកំណើត | សាវតារ | | លេខាធិការដោយសង្ខេបនៃលិខិត សញ្ញា និងសាលក្រមតុលាការ | បន្ទុកលើអចលនវត្ថុ | |
| | ហ | អ | ស | | | | | | | |
| ឌ.ក | 04 | 15 | 23 | | ✓ | ✓ | ✓ | | | [illegible] 1345/04 [illegible] 13.12.04 [illegible] |

**ឧបសម្ព័ន្ធ១.ខ**

វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ

# 1. ឈ្មោះហៅក្រៅ ប្លង់ L-MAP (ខាងមុខ និងខាងក្រោយ)






**ឧបសម្ព័ន្ធ១.គ**

ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី

# 3- ឈ្មោះហៅក្រៅ ប្លង់ស្លាបមាន់ (ខាងមុខ)



ប័ណ្ណសំគាល់សិទ្ធិ

កាន់កាប់ប្រើប្រាស់ដីធ្លី

# 3- ឈ្មោះហៅក្រៅ ប្លង់ស្លាបមាន់ (ខាងក្រោយ)



[redacted]

**ឧបសម្ព័ន្ធ១.ឃ**

វិញ្ញាបនបត្រសម្គាល់ម្ចាស់ចំណែកឯកជន

# 5- ឈ្មោះហៅក្រៅ ប្លង់ចំណែកឯកជន (ខាងមុខ និងក្រោយ)



# ឧបសម្ព័ន្ធ២

## ឧបសម្ព័ន្ធ២

គំរូ កិច្ចសន្យាខ្ចីបរិភោគ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

### កិច្ចសន្យាខ្ចីបរិភោគ

**១. ឈ្មោះ និងអាសយដ្ឋានរបស់ភាគីនៃកិច្ចសន្យា**

(១) **កូនបំណុល** ឈ្មោះ .................... ភេទ........ ថ្ងៃខែឆ្នាំកំណើត....................... សញ្ជាតិ........ កាន់អត្តសញ្ញាណប័ណ្ណលេខ.............................. ចុះថ្ងៃទី...................... និង ឈ្មោះ .......................... ភេទ...... ថ្ងៃខែឆ្នាំកំណើត..................... សញ្ជាតិ.......... កាន់អត្តសញ្ញាណប័ណ្ណលេខ............................ ចុះថ្ងៃទី........................ មានអាស័យដ្ឋានផ្ទះលេខ........ ផ្លូវលេខ........ ភូមិ.......... សង្កាត់.......... ខណ្ឌ ............ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា (តទៅនេះហៅថា **ភាគី "ក"**) ។

(២) **អ្នកបង្កើតហ៊ីប៉ូតែក** ឈ្មោះ .................... ភេទ...... ថ្ងៃខែឆ្នាំកំណើត................. សញ្ជាតិ...... កាន់អត្តសញ្ញាណប័ណ្ណលេខ........................... ចុះថ្ងៃទី...................... និង ឈ្មោះ ............................ ភេទ...... ថ្ងៃខែឆ្នាំកំណើត..................... សញ្ជាតិ.......... កាន់អត្តសញ្ញាណប័ណ្ណលេខ........................... ចុះថ្ងៃទី.................... មានអាស័យដ្ឋានផ្ទះលេខ........ ផ្លូវលេខ........ ភូមិ......... សង្កាត់........ ខណ្ឌ.......... រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា (តទៅនេះហៅថា **ភាគី "ក"**) ។

(៣) **ម្ចាស់បំណុល** ឈ្មោះ ..................... ភេទ...... ថ្ងៃខែឆ្នាំកំណើត................... សញ្ជាតិ.......... កាន់អត្តសញ្ញាណប័ណ្ណលេខ........................... ចុះថ្ងៃទី........................ មានអាស័យដ្ឋានផ្ទះលេខ........ ផ្លូវលេខ......... ភូមិ............ សង្កាត់............. ខណ្ឌ........... រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា (តទៅនេះហៅថា **ភាគី "ខ"**) ។

**២. សិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែក**

កូនបំណុលឈ្មោះ ...................... ភេទ........ ថ្ងៃខែឆ្នាំកំណើត.......................... សញ្ជាតិ.......... កាន់អត្តសញ្ញាណប័ណ្ណលេខ........................... ចុះថ្ងៃទី....................... និង ឈ្មោះ ............................ ភេទ...... ថ្ងៃខែឆ្នាំកំណើត..................... សញ្ជាតិ......... កាន់អត្តសញ្ញាណប័ណ្ណលេខ............................. ចុះថ្ងៃទី.........................មានអាស័យដ្ឋានផ្ទះលេខ......... ផ្លូវលេខ......... ភូមិ............ សង្កាត់............. ខណ្ឌ............ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ។

(១). ចំនួនប្រាក់ដើម ៖ XXXX ដុល្លាឬរៀល (សរសេជាអក្សរ)

(២). អត្រាការប្រាក់ ៖ XX% ក្នុងមួយឆ្នាំ (សរសេរជាអក្សរ)

(៣). សំណងការខូចខាត ៖ XX% ក្នុងមួយឆ្នាំ (សរសេរជាអក្សរ)

(៤). លក្ខខណ្ឌផ្សេងៗ (ប្រសិនបើមានលក្ខខណ្ឌដូចមានចែកក្នុងមាត្រា ៣២៥ នៃក្រមរដ្ឋប្បវេណី) ដូចមានមានចែងក្នុងកិច្ចសន្យាខ្ចីបរិភោគ។

ភាគី "ក" និងភាគី "ខ" បានព្រមព្រៀងគ្នាបង្កើតកិច្ចសន្យាខ្ចីបរិភោគដែលមានចែងនៅក្នុងចំណុច២ ខាងលើ។

ភាគី "ក" និងភាគី "ខ" បានព្រមព្រៀងគ្នាបង្កើតកិច្ចសន្យាហ៊ីប៉ូតែកលើសិទ្ធិនៃចំណុច៣ ដើម្បីធានាសិទ្ធិលើបំណុលរបស់ភាគី "ក" ចំពោះភាគី "ខ" ដូចមានចែងក្នុងចំណុចទី២ នៃកិច្ចសន្យាខ្ចីបរិភោគខាងលើ។

**៣. អត្តសញ្ញាណអចលនវត្ថុ ឫសិទ្ធិដែលជាកម្មវត្ថុនៃហ៊ីប៉ូតែក**

កម្មសិទ្ធិករៈ ឈ្មោះ...........................

(១) ប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុ ឫវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ................. ចុះថ្ងៃទី...... ខែ........ ឆ្នាំ.......... មានទីតាំងស្ថិតនៅ ក្បាលដីលេខ........ ភូមិ......... សង្កាត់....... ខណ្ឌ......... រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

**៤. ខសន្យាផ្សេងទៀត (ប្រសិនបើមាន)**

ភាគី "ក" និងភាគី "ខ" បានព្រមព្រៀងគ្នាកំណត់អំពីលក្ខខណ្ឌផ្សេងៗទៀតដូចមានចែងនៅក្នុង **ឧបសម្ព័ន្ធ (ក)**នៃកិច្ចសន្យានេះ។

ធ្វើជា...... ច្បាប់ នៅថ្ងៃទី ........ ខែ....... ឆ្នាំ.........

**បានអានសេចក្តីនៃលិខិតនេះអោយគូភាគីស្តាប់ចំពោះមុខសាក្សី**

ឈ្មោះ..........................អាយុ................ឆ្នាំ ទីលំនៅ សង្កាត់..............ខណ្ឌ...............រាជធានីភ្នំពេញ ។

ឈ្មោះ...........................អាយុ..............ឆ្នាំ ទីលំនៅ សង្កាត់..............ខណ្ឌ...............រាជធានីភ្នំពេញ ។

| **ស្នាមមេដៃ** | **ស្នាមមេដៃ** | **បានឃើញ និងបញ្ជាក់ថា** |
|---|---|---|
| ភាគី "ក" | ភាគី "ខ" | គូភាគីបានផ្តិតមេដៃចំពោះមុខមេធាវីជាសាក្សី |

# ឧបសម្ព័ន្ធ៣

## ឧបសម្ព័ន្ធ៣

គំរូ កិច្ចសន្យាបង្កើតហ៊ីប៉ូតែក

**កិច្ចសន្យាបង្កើតហ៊ីប៉ូតែក**

អ្នកតែងលិខិត............

លេខ........................

មន្ទីរ ឧ.ឧ.ស.ស រាជធានីភ្នំពេញ

ក្រដាសពុម្ពលេខ...............

ទីទុកឯកសារ

# កិច្ចសន្យាបង្កើតហ៊ីប៉ូតែក

១. ឈ្មោះ និង អាសយដ្ឋានរបស់ភាគីនៃកិច្ចសន្យា

(១) កូនបំណុលឈ្មោះ[១]...........................................ភេទ.........ថ្ងៃខែឆ្នាំកំណើត[២] .................. សញ្ជាតិ................ទីលំនៅភូមិ...................... សង្កាត់....................... ខណ្ឌ....................... រាជធានីភ្នំពេញ [៣] (តទៅហៅថាភាគី-ក-) ។

កូនបំណុលឈ្មោះ[១]...............................................ភេទ.........ថ្ងៃខែឆ្នាំកំណើត[២]................. សញ្ជាតិ................ទីលំនៅភូមិ...................... សង្កាត់....................... ខណ្ឌ....................... រាជធានីភ្នំពេញ [៣] (តទៅហៅថាភាគី-ក-) ។

ឬអ្នកធានាដោយវត្ថុឈ្មោះ[១]...................................ភេទ.........ថ្ងៃខែឆ្នាំកំណើត[២] ............... សញ្ជាតិ................ទីលំនៅភូមិ...................... សង្កាត់....................... ខណ្ឌ....................... រាជធានីភ្នំពេញ [៣] (តទៅហៅថាភាគី-ក-) ។

អ្នកធានាដោយវត្ថុឈ្មោះ[១]......................................ភេទ.........ថ្ងៃខែឆ្នាំកំណើត[២] ................ សញ្ជាតិ................ទីលំនៅភូមិ...................... សង្កាត់....................... ខណ្ឌ....................... រាជធានីភ្នំពេញ [៣] (តទៅហៅថាភាគី-ក-) ។

(២) ម្ចាស់បំណុលឈ្មោះ[១].......................................ភេទ.........ថ្ងៃខែឆ្នាំកំណើត[២]................ សញ្ជាតិ................ទីលំនៅភូមិ...................... សង្កាត់....................... ខណ្ឌ....................... រាជធានីភ្នំពេញ [៣] (តទៅហៅថាភាគី-ខ-) ។

---

ក្នុងករណីនីតិបុគ្គល ត្រូវសរសេរ:

[១]នាមករណ៍របស់នីតិបុគ្គល

[២]ថ្ងៃ ខែ ឆ្នាំ នៃការបង្កើតនីតិបុគ្គល

[៣]អាសយដ្ឋានដែលជាទីស្នាក់ការរបស់នីតិបុគ្គល។

២.សិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែក

កូនបំណុលឈ្មោះ[១]........................................ភេទ..........ថ្ងៃខែឆ្នាំកំណើត[២] ..................
សញ្ជាតិ..........ទីលំនៅភូមិ.................... សង្កាត់...................... ខណ្ឌ...................... រាជធានីភ្នំពេញ[៣] ។

(១) មូលហេតុ និងកាលបរិច្ឆេទនៃកិច្ចសន្យា...................................................................

(២)ចំនួនប្រាក់ដើម.........................(ដុល្លារឬរៀល) សរសេរជាអក្សរ.....................................

(៣)អត្រាការប្រាក់.........................% ក្នុងមួយឆ្នាំ សរសេរជាអក្សរ.......................................

(៤))សំណងការខូចខាត..................% ក្នុងមួយឆ្នាំ សរសេរជាអក្សរ.........................................

(៥) លក្ខខណ្ឌ (ប្រសិនបើមានលក្ខខណ្ឌផ្សេងមានចែងនៅក្នុងមាត្រា ៣២៥ នៃក្រមរដ្ឋប្បវេណី).............

...........................................................................................................................

...........................................................................................................................

ភាគី ក និង ភាគី ខ បានព្រមព្រៀងគ្នាបង្កើតហ៊ីប៉ូតែក...................(ហ៊ីប៉ូតែកធម្មតា ឬ ហ៊ីប៉ូតែករួម) លើសិទ្ធិនៃចំនុច ៣ ដើម្បីធានា សិទ្ធិលើបំណុលដែលមានចែងនៅចំណុចទី ២ ខាងលើ ។

៣.អត្តសញ្ញាណអចលនវត្ថុ ឬ សិទ្ធិ ដែលជាកម្មវត្ថុនៃហ៊ីប៉ូតែក

(១) ទីតាំងអចលនវត្ថុ:ភូមិ...................... សង្កាត់.............................ខណ្ឌ......................
រាជធានីភ្នំពេញ ។

(២)លេខក្បាលដី:..........................................................................................

(៣)លេខប័ណ្ណ:................................................................................................

(លេខវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុ ឬ ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ ឬ ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី ឬ វិញ្ញាបនប័ត្រសម្គាល់សិទ្ធិជួលអចិន្ត្រៃយ៍ ឬ វិញ្ញាបនប័ត្រសម្គាល់ផលុបភោគ)

(១) ទីតាំងអចលនវត្ថុ:ភូមិ...................... សង្កាត់.............................ខណ្ឌ......................
រាជធានីភ្នំពេញ ។

(២)លេខក្បាលដី:..........................................................................................

(៣)លេខប័ណ្ណ:................................................................................................

(លេខវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុ ឬ ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ ឬ ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី ឬ វិញ្ញាបនប័ត្រសម្គាល់សិទ្ធិជួលអចិន្ត្រៃយ៍ ឬ វិញ្ញាបនប័ត្រសម្គាល់ផលុបភោគ)

៨ ខសន្យាផ្សេងទៀត (ប្រសិនបើមាន) ៖

........................................................................................................................................................................

........................................................................................................................................................................

........................................................................................................................................................................

កិច្ចសន្យានេះធ្វើជា ០៣ ច្បាប់ នៅថ្ងៃទី.................ខែ...............ឆ្នាំ............ ចំពោះមុខយើងជា

.............................. (ចៅសង្កាត់ ឬ អភិបាលខណ្ឌ ឬ សារការី)

បានអានសេចក្តីនៃកិច្ចសន្យានេះឲ្យគូភាគីស្តាប់ចំពោះមុខសាក្សី

ឈ្មោះ..................................អាយុ.........ឆ្នាំ ទីលំនៅ សង្កាត់............................ខណ្ឌ..........................

រាជធានីភ្នំពេញ ។

ឈ្មោះ..................................អាយុ.........ឆ្នាំ ទីលំនៅ សង្កាត់............................ខណ្ឌ..........................

រាជធានីភ្នំពេញ ។

លេខបញ្ជាក់.................

ស្នាមមេដៃស្តាំ ស្នាមមេដៃស្តាំ ហត្ថលេខានិងត្រាមន្ត្រីដែលបញ្ជាក់

ភាគី-ក- ភាគី-ខ- សាក្សី សាក្សី

# ឧបសម្ព័ន្ធ៤

## ឧបសម្ព័ន្ធ៤

គំរូ ពាក្យសុំចុះបញ្ជីអំពីការបង្កើតហ៊ីប៉ូតែក

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ពាក្យសុំចុះបញ្ជីអំពីការបង្កើតហ៊ីប៉ូតែក**

ខ្ញុំបាទឈ្មោះ.................................... កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ:..................................... ចុះថ្ងៃទី ............... ខែ............... ឆ្នាំ............... ដែលមានអាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ...... ផ្លូវលេខ ...... ភូមិ...... សង្កាត់...... ខណ្ឌ...... រាជធានីភ្នំពេញ (បុគ្គលមានសិទ្ធិចុះបញ្ជី) និងលោក............................ ជនជាតិ...... សញ្ជាតិ...... កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ...................................... ចុះថ្ងៃទី...... ខែ...... ឆ្នាំ...... និងលោកស្រី........................... ជនជាតិ...... សញ្ជាតិ...... កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ...................................... ចុះថ្ងៃទី...... ខែ...... ឆ្នាំ...... ដែលមានអាសយដ្ឋានបច្ចុប្បន្ននៅផ្ទះលេខ...... ផ្លូវ...... ក្រុម...... ភូមិ...... សង្កាត់...... ខណ្ឌ...... រាជធានីភ្នំពេញ (បុគ្គលមានកាតព្វកិច្ចចុះបញ្ជី) ។

**សូមគោរពជូន**
**លោកប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានីភ្នំពេញ**

**កម្មវត្ថុ:** - សំណើសុំចុះបញ្ជីអំពីការបង្កើតហ៊ីប៉ូតែក

**យោង:** - កិច្ចសន្យាខ្ចីបរិភោគ និងកិច្ចសន្យាបង្កើតហ៊ីប៉ូតែក ចុះថ្ងៃទី.......ខែ................ឆ្នាំ.........

តាមកម្មវត្ថុ និងយោងខាងលើ យើងខ្ញុំសូមស្នើសុំចុះបញ្ជីអំពីការបង្កើតសិទ្ធិលើការបញ្ចាំដូចក្រោម:

**ក. គោលបំណងនៃការចុះបញ្ជី**

– កិច្ចសន្យាខ្ចីបរិភោគ និងកិច្ចសន្យាបង្កើតហ៊ីប៉ូតែកលើកម្មសិទ្ធិ

**ខ. មូលហេតុ**

– កិច្ចសន្យាខ្ចីបរិភោគ និងកិច្ចសន្យាបង្កើតហ៊ីប៉ូតែក ចុះថ្ងៃទី...........ខែ............ឆ្នាំ...............

បុគ្គលមានសិទ្ធិចុះបញ្ជី

ខ្ញុំបាទឈ្មោះ.................................... កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ:..................................... ចុះថ្ងៃទី ............... ខែ............... ឆ្នាំ............... ដែលមានអាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ...... ផ្លូវលេខ ...... ភូមិ...... សង្កាត់...... ខណ្ឌ...... រាជធានីភ្នំពេញ។

## គ. បុគ្គលមានកាតព្វកិច្ចចុះបញ្ជី

លោក............................ ជនជាតិ...... សញ្ជាតិ...... កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ.................. ចុះថ្ងៃទី...... ខែ...... ឆ្នាំ...... និងលោកស្រី............................ ជនជាតិ...... សញ្ជាតិ...... កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ...................................... ចុះថ្ងៃទី...... ខែ...... ឆ្នាំ...... ដែលមានអាសយដ្ឋានបច្ចុប្បន្ននៅផ្ទះលេខ...... ផ្លូវ...... ក្រុម...... ភូមិ...... សង្កាត់...... ខណ្ឌ...... រាជធានីភ្នំពេញ។

## ឃ.ចំនុចផ្សេងទៀតដែលត្រូវចុះបញ្ជី

លោក............................ ជនជាតិ...... សញ្ជាតិ...... កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ.................. ចុះថ្ងៃទី...... ខែ...... ឆ្នាំ...... និងលោកស្រី............................ ជនជាតិ...... សញ្ជាតិ...... កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ...................................... ចុះថ្ងៃទី...... ខែ...... ឆ្នាំ...... ដែលមានអាសយដ្ឋានបច្ចុប្បន្ននៅផ្ទះលេខ...... ផ្លូវ...... ក្រុម...... ភូមិ...... សង្កាត់...... ខណ្ឌ...... រាជធានីភ្នំពេញ។

— ចំនួនប្រាក់ដើម USD .................. សរសេរជាអក្សរ ..................ដុល្លារអាមេរិកគត់។

— ការប្រាក់ ២៤% ក្នុងមួយឆ្នាំ សរសេរជាអក្សរ ម្ភៃបួនភាគរយក្នុងមួយឆ្នាំ។

— សំណងការខូចខាត ២៤ % ក្នុងមួយឆ្នាំ សរសេរជាអក្សរ ម្ភៃបួនភាគរយក្នុងមួយឆ្នាំ។

— អំឡុងពេល ០២ ឆ្នាំ សរសេរជាអក្សរ ពីរឆ្នាំ។

— លក្ខខណ្ឌភ្ជាប់នឹងសិទ្ធិលើបំណុលដែលត្រូវបានធានា (ប្រសិនបើមាន)

លោក............................ ជនជាតិ...... សញ្ជាតិ...... កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ.................. ចុះថ្ងៃទី...... ខែ...... ឆ្នាំ...... និងលោកស្រី............................ ជនជាតិ...... សញ្ជាតិ...... កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ...................................... ចុះថ្ងៃទី...... ខែ...... ឆ្នាំ...... ដែលមានអាសយដ្ឋានបច្ចុប្បន្ននៅផ្ទះលេខ...... ផ្លូវ...... ក្រុម...... ភូមិ...... សង្កាត់...... ខណ្ឌ...... រាជធានីភ្នំពេញ ដែលជាកម្មសិទ្ធិផ្ទាល់ខ្លួន ក្នុងការដាក់បញ្ចាំ។

## ង.អត្តសញ្ញាណនៃអចលនវត្ថុ

(១) ទីតាំងអចលនវត្ថុ: ដី ដែលស្ថិតនៅសង្កាត់...... ខណ្ឌ...... រាជធានីភ្នំពេញ

(២) លេខក្បាលដី: ...................

(៣) លេខប័ណ្ណ: ប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ភព .................. ចុះថ្ងៃទី
...... ខែ...... ឆ្នាំ......

អាស្រ័យហេតុនេះ សូមលោកប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានីភ្នំពេញ មេត្តាពិនិត្យ និងសម្រេចអនុញ្ញាតអោយចុះបញ្ជីតាមសំណើខាងលើ ដោយក្តីអនុគ្រោះ។

រាជធានីភ្នំពេញ ថ្ងៃទី........ ខែ........... ឆ្នាំ..............

| | |
|---|---|
| **អ្នកមានសិទ្ធិចុះបញ្ជី ឬ តំណាង** | **អ្នកមានកាតព្វកិច្ចចុះបញ្ជី ឬ តំណាង** |
| **(ស្នាមមេដៃស្តាំ)** | **(ស្នាមមេដៃស្តាំ)** |
| ................... | ................... ................... |

ឯកសារភ្ជាប់: - កិច្ចសន្យាខ្ចីបរិភោគ និងកិច្ចសន្យាហ៊ីប៉ូតែក ចុះថ្ងៃទី..........ខែ................ឆ្នាំ..................
- វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ:.......................ចុះថ្ងៃទី.......ខែ.........ឆ្នាំ............០១ច្បាប់ដើម

# ឧបសម្ព័ន្ធ៥

**ឧបសម្ព័ន្ធ៥**

ប្រកាសលេខ ១២៨កយ.ប្រក/១១ ស្តីពីអត្រាការប្រាក់ដែលបានកំណត់ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្តីការក្រសួងយុត្តិធម៌**

លេខ: ១២៨ កយ. ប្រក/១១

រាជធានីភ្នំពេញ,ថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០១១

**ប្រកាស**

**ស្តីពី**

**អត្រាការប្រាក់ដែលត្រូវបានកម្រិត**

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងយុត្តិធម៌

-បានឃើញអនុក្រឹត្យលេខ ៤៧ អនក្រ.បក ចុះថ្ងៃទី ១១ ខែឧសភា ឆ្នាំ ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌

-បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី ០៨ ខែធ្នូ ឆ្នាំ ២០០៧ ដែលប្រកាសឲ្យប្រើក្រមរដ្ឋប្បវេណី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៥១១/០០៧ ចុះថ្ងៃទី ៣១ ខែឧសភា ឆ្នាំ ២០១១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី

**សម្រេច**

ប្រការ ១.-

អត្រាការប្រាក់ដែលត្រូវបានកម្រិតដែលបានកំណត់ក្នុងកថាខណ្ឌទី ១ នៃមាត្រា ១៧ (អត្រាការប្រាក់ដែលត្រូវបានកម្រិត ជាអាទិ៍) នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ត្រូវបានកំណត់មិនឲ្យលើសពី ១៨% (ដប់ប្រាំបីភាគរយ) ក្នុង ១ (មួយ) ឆ្នាំ។

ប្រការ ២.-

អត្រាការប្រាក់ ដែលព្រមព្រៀងជាមុនក្នុងការសងសំណងក្នុងកិច្ចសន្យាខ្ចីបរិភោគដែលមានកម្មវត្ថុជាប្រាក់ ដែលបានកំណត់ក្នុងកថាខណ្ឌទី ៣ នៃមាត្រា ១៧ (អត្រាការប្រាក់ដែលត្រូវ

ផ្លូវសម្តេចសុធារស.ខ័ណ្ឌដូនពេញ.ក្រុងភ្នំពេញ ទូរស័ព្ទ : 023 216 322 , 023 215 638

បានកម្រិត ជាអាទិ៍) នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ត្រូវបានកំណត់មិនឲ្យលើសពីចំនួន ១,៥ (មួយក្បៀសប្រាំ) ដង នៃអត្រាការប្រាក់ដែលបានកំណត់ក្នុងប្រការ ១ ខាងលើ។

**ប្រការ ៣.-**

ប្រកាសនេះ មានអានុភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រដ្ឋមន្ត្រី

អង្គ-វង្សវឌ្ឍានា

ចម្លងជូន៖

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
-ក្រសួង រដ្ឋលេខាធិការដ្ឋាន និងស្ថាប័នពាក់ព័ន្ធ
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-តុលាការ និងមហាអយ្យការ -អយ្យការអមតុលាការគ្រប់ជាន់ថ្នាក់
-ឯកសារ-កាលប្បវត្តិ។